# ក្រសួងអប់រំ យុវជន និងកីឡា

*Ministry of Education, Youth and Sports*

## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

ROYAL UNIVERSITY OF LAW AND ECONOMICS

ឆ្នាំសិក្សាមូលដ្ឋាន

FOUNDATION YEAR

# កិច្ចការស្រាវជ្រាវ

## មុខវិជ្ជា: សេចក្តីផ្តើមនីតិរដ្ឋធម្មនុញ្ញ

## ប្រធានបទ: ការបង្កើតរដ្ឋធម្មនុញ្ញ

ណែនាំដោយ:សាស្ត្រាចារ្យ ជុំ អ៊ឹម


ក្រុមនិស្សិត: $L_1A_4$

-ឡោ ក្រឹម -ផន្នា និមល

-ហុង រ័ត្នបុត្នី -ស ច័ន្ទរស្មី


ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន(*Foundation Year*) ២០១០-២០១១

# ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth and Sports

# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
ROYLAL UNIVERSITY OF LAW AND ECONOMICS

## ឆ្នាំសិក្សាមូលដ្ឋាន
Foundation Year

## កិច្ចការស្រាវជ្រាវ

មុខវិជ្ជា: **សេចក្តីផ្តើមនីតិរដ្ឋធម្មនុញ្ញ**

ប្រធានបទ:

# ការបង្កើតរដ្ឋធម្មនុញ្ញ

ណែនាំដោយ: សាស្ត្រាចារ្យ ជុំ អ៊ុម

ក្រុមស្រាវជ្រាវ:

-ឡេង ក្រឹម012884441,069255525 -បាន្ថា នីមល0979520500

-ហុង រ័ត្នមុនី0979999152 -ស ច័ន្ទរស្មី0889995524

-ឈុន សៀកវ៉ា0972659322

ភ្នំពេញ-២០១១

# អារម្ភកថា

ជាកិច្ចបើកទំព័រ យើងខ្ញុំទាំងអស់គ្នា សូមស្វាគមន៍ដល់មិត្តអ្នកអានគ្រប់រូបជាពិសេស សិស្ស-និស្សិត ព្រមទាំងសាស្ត្រាចារ្យជាទីគោរព ។

យើងខ្ញុំទាំងអស់គ្នា ជាក្រុមនិស្សិតដែលកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងរាជធានីភ្នំពេញ។ បានរៀបចំបង្កើតឡើងនូវកិច្ចការស្រាវជ្រាវនេះ ដោយប្រព្រឹត្តទៅក្រោមការណែនាំ និងបង្ហាត់បង្ហាញដោយផ្ទាល់របស់សាស្ត្រាចារ្យ **ជុំ អ៊ឹម** ដែលបានផ្តល់ឱកាសអោយយើងខ្ញុំស្រាវជ្រាវសៀវភៅនេះ។

ដើម្បីជាកិច្ចស្តារនិងអភិវឌ្ឍន៍ប្រទេសជាតិអោយរីកចម្រើន យើងខ្ញុំដែលជានិស្សិតបានដាក់ចិត្ត ដាក់កាយចូលរួមចំណែកក្នុងវិស័យច្បាប់ នេះដោយធ្វើការសម្រិតសម្រាំងអោយកាន់តែច្បាស់ថែមទៀត ។

គោលបំណងក្នុងការស្រាវជ្រាវនេះឡើងដើម្បីចង់បង្ហាញអោយឃើញអំពី:

- ការបង្កើតរដ្ឋធម្មនុញ្ញ
- ប្រវត្តិនៃការបង្កើតរដ្ឋធម្មនុញ្ញខ្មែរ
- ប្រភពនៃរដ្ឋធម្មនុញ្ញ
- ស្វែងយល់ពីរដ្ឋធម្មនុញ្ញនៃបណ្តាប្រទេសមួយចំនួននៅលើពិភពលោក
- ផ្តល់នូវចំណេះដឹងទូទៅផ្នែកនីតិសាស្ត្រ

ជាទីអវសាននេះ សូមជូនពរដល់អ្នកអានគ្រប់រូបអោយជួបប្រទះតែនឹងភាពសុខដុម្បរមនា រុងរឿងចុំច្រើង និងមានសុភមង្គលជានិរន្តន៍កុំបីឃ្លៀងឃ្លាតឡើយ។

ម៉្យាងវិញទៀតយើងខ្ញុំទាំងអស់គ្នាសូមអភ័យទោសផងដែរ ចំពោះកង្វះខាតទាំងឡាយដែល មាននៅក្នុងសៀវភៅនេះ ព្រមជាមួយនោះ យើងខ្ញុំនឹងរងចាំទទួលការរិះគន់ដើម្បីស្ថាបនាពីសំណាក់ មិត្តអ្នកអានទាំងអស់គ្នាគ្រប់វិនាទី។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃច័ន្ទ ទី២០ ខែមិថុនា ឆ្នាំ២០១១

ក្រុមនិស្សិត

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងអស់គ្នា ដែលជានិស្សិតថ្នាក់បរិញ្ញាប័ត្រនៃសាលកវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមសំដែងនូវកតញ្ញូតាធម៌ និងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតៈ

សូមលើកអញ្ជលីលំឱនកាយវាចារចិត្តគោរពដល់លោកអ្នកដ៏មានគុណទាំងពីរមាន មាតាបិតា ដែលបានផ្តល់កំណើតចិញ្ចឹមថ្នាក់ថ្នមបីបាច់ថែរក្សា ផ្តល់នូវសេចក្តីស្រលាញ់ប្រកបដោយព្រហ្មវិហារធម៌ អប់រំទូន្មានប្រៀនប្រដៅ និងទំនុកបំរុងគ្រប់បែបយ៉ាងទាំងសម្ភារៈ ទាំងស្មារតី និងថវិកាអោយកូនបានសិក្សារៀនសូត្រចាប់តាំងពីថ្នាក់បឋមសិក្សារហូតដល់ថ្នាក់មហាវិទ្យាល័យ។

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហាមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា

សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា

ជាប្រមុខដឹកនាំដ៏ឈ្លាវៃ ដែលបានពុះពារគ្រប់ឧបសគ្គក្នុងការដឹកនាំប្រទេសជាតិទទួលបានជោគជ័យលើគ្រប់វិស័យ ។ ជាពិសេសយុទ្ធសាស្ត្រ**ឈ្នះ-ឈ្នះ** របស់សម្តេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីដ៏ឆ្នើម នៃព្រះរាជាណាចក្រកម្ពុជា និងជាទីសង្ឃឹមនៃប្រជារាស្ត្រកម្ពុជាដែលកន្លងមកសម្តេចបានបូជា ដោយភាពដឹកនាំប្រទេសជាតិតាមទស្សនវិស័យដ៏ត្រឹមត្រូវប្រកបដោយសមត្ថភាពដ៏បរិបូរណ៍ និងមានការទទួលខុសត្រូវខ្ពស់បំផុត។

ឯកឧត្តម **យក់ ឌ៉ុយ** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាតអោយយើងខ្ញុំទាំងអស់គ្នាបានចូលរៀននៅសាកលវិទ្យាល័យនេះ និងបង្កលក្ខណៈងាយស្រួលដល់ការសិក្សារបស់យើងខ្ញុំថែមទៀតផង។

លោកសាស្ត្រាចារ្យ **ជុំ អ៊ីម** ដែលបានឆ្លៀតឱកាសដ៏មានតម្លៃនិងដ៏មមាញឹកក្នុងការបង្ហាត់បង្រៀនផ្តល់ការណែនាំ និងផ្តល់ឯកសារសម្រាប់អោយយើងខ្ញុំបានស្រាវជ្រាវ ។

សូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុតថែមទៀត ចំពោះអ្នកនិពន្ធ និងអ្នកប្រាជ្ញព្រមទាំងទស្សនៈវិទូល្បីៗក្នុងលោកដែលយើងខ្ញុំបានសិក្សាស្រាវជ្រាវ ពីស្នាដៃរបស់លោកក្នុងការបំពេញកិច្ចការស្រាវជ្រាវនៅពេលកន្លងមក។

សូមមេត្តាទទួលនូវអំណរគុណដ៏ជ្រាលជ្រៅបំផុត និងមិនអាចបំភ្លេចបានអំពីយើងខ្ញុំ ចំពោះឧបការគុណដ៏ធំធេងចំពោះយើងខ្ញុំទាំងអស់គ្នា។ សូមអ្នកទាំងអស់ទទួលបាននូវបរមសុខដ៏បរិបូរណ៍នៅគ្រប់ពេលវេលា។

ជាទីបញ្ចប់នេះ សូមជូនពរដល់ អ្នកមានគុណ សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោកលោកស្រី និងសាស្ត្រាចារ្យទាំងអស់អោយជួបតែពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

***សូមអរគុណ!***

# មាតិកា

ចំណងជើង ទំព័រ


អារម្ភកថា.....I
សេចក្តីថ្លែងអំណរគុណ.....II
១.សេចក្តីផ្តើម.....១
២.ប្រវត្តិដើមនៃរដ្ឋធម្មនុញ្ញ.....២
២.១.សញ្ញាណរដ្ឋធម្មនុញ្ញ.....២
២.២.និយមន័យ.....២
២.៣.ប្រវត្តិដើមនៃរដ្ឋធម្មនុញ្ញ.....៣
៣.ប្រភពនៃរដ្ឋធម្មនុញ្ញ.....៤
៣.១.រដ្ឋធម្មនុញ្ញអត្ថបទសរសេរ និងរដ្ឋធម្មនុញ្ញឥតសរសេរ.....៤
៣.២.កម្រងរដ្ឋធម្មនុញ្ញតែមួយ និងរដ្ឋធម្មនុញ្ញដែលពុំបានចងក្រងជាអត្ថបទរដ្ឋធម្មនុញ្ញតែមួយ.....៥
៣.៣.រដ្ឋធម្មនុញ្ញរាជានិយម និងរដ្ឋធម្មនុញ្ញសាធារណរដ្ឋនិយម.....៦
៣.៤.រដ្ឋធម្មនុញ្ញឯកត្តរដ្ឋ និងរដ្ឋធម្មនុញ្ញសហព័ន្ធ.....៦
៣.៥. រដ្ឋធម្មនុញ្ញសភានិយម និងរដ្ឋធម្មនុញ្ញប្រធានាធិបតីនិយម.....៦
៣.៦.រដ្ឋធម្មនុញ្ញតឹងរឹង និងរដ្ឋធម្មនុញ្ញងាយបត់បែន.....៦
៤.ប្រភេទរដ្ឋធម្មនុញ្ញ.....៦
៥.ពលរដ្ឋត្រូវការរដ្ឋធម្មនុញ្ញថ្មី.....៨
៦.ទម្រង់នៃបង្កើតរដ្ឋធម្មនុញ្ញ.....៩
៧.នីតិវិធីសម្រាប់បង្កើតរដ្ឋធម្មនុញ្ញថ្មី.....៩
៨.ខ្លឹមសារសំខាន់ៗចែងត្រូវក្នុងរដ្ឋធម្មនុញ្ញ.....១១
៩.ឧត្តមភាពនៃរដ្ឋធម្មនុញ្ញ.....១២
១០.ករណីការសិក្សារដ្ឋធម្មនុញ្ញ បណ្តាប្រទេសនីមួយៗ.....១២
១០.១.រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣.....១២
១០.២.រដ្ឋធម្មនុញ្ញប្រទេសស្វីស(ប្រជាមតិ).....១៤
១០.៣.រដ្ឋធម្មនុញ្ញបារាំង.....១៥
១០.៤.រដ្ឋធម្មនុញ្ញសហព័ន្ធរុស្សី.....១៧
១០.សេចក្តីសន្និដ្ឋាន.....១៨
ឯកសារយោង
ឧបសម្ព័ន្ធ

## ១.សេចក្ដីផ្ដើម

ប្រទេសជាតិមួយមានការរីចចំរើនលូតលាស់ និងទទួលបាននូវឈ្មោះអារ្យប្រទេសលើឆាកអន្តរជាតិបាន លុះត្រាតែប្រទេសនោះមានដំណើរការគ្រប់គ្រង និងរៀបចំស្ថាប័ននយោបាយព្រមទាំងរដ្ឋបាលប្រកបដោយដំណើរការប្រព្រឹត្តទៅបានល្អជាប្រក្រតី និងមានប្រសិទ្ធិភាព មានការគោរពម៉ឺងម៉ាត់ និងឈរលើគោលការណ៍ច្បាប់ជាធំនៅក្នុងបេសកកម្មរបស់ខ្លួនក្នុងការដឹកនាំប្រទេសដោយឈរលើការដំកល់ផលប្រយោជន៍ជាតិខ្ពស់ជាងផលប្រយោជន៍បុគ្គល ឬបក្សរបស់ខ្លួន។ ដើម្បីធ្វើយ៉ាងនេះបានលុះត្រាតែប្រទេសជាតិ មានប្រព័ន្ធច្បាប់សម្រាប់គ្រប់គ្រងប្រទេសខ្លួនអោយបានគ្រប់គ្រាន់ និងសុក្រឹតភាព ជាពិសេសត្រូវមានច្បាប់កំពូលមួយ ដែលសម្រាប់រៀបចំអំណាចសាធារណៈព្រមទាំងទិសដៅអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកំណត់អំពីស្ថាប័នកំពូលៗរបស់រដ្ឋ និងសិទ្ធិករណីកិច្ចរបស់ប្រជាពលរដ្ឋជាមុនសិន។

បទពិសោធន៍ក្នុងការអនុវត្តនូវទ្រឹស្ដីនៃរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជាជាច្រើន បានផ្ដល់នូវលទ្ធផលនោះថា យន្តការរដ្ឋធម្មនុញ្ញមួយដ៏ប្រសើរវាមានតម្លៃជាអមតៈ និងជាផែនទីវិថីមួយសម្រាប់បោះជំហានឈានឆ្ពោះទៅរកភាពរុងរឿង។ លើសពីនេះទៅទៀតបទពិសោធន៍នេះបង្ហាញថាវិបត្តិនយោបាយភាគច្រើននឹងនាំទៅរកវិបត្តិរដ្ឋធម្មនុញ្ញ ក៏ជាបុព្វហេតុចំបងដែលនឹងនាំទៅរកវិបត្តិនយោបាយផង។

ច្បាប់កំពូលនោះគឺ ***រដ្ឋធម្មនុញ្ញ*** រដ្ឋធម្មនុញ្ញនេះតែងតែមានាការផ្លាស់ប្ដូរកែប្រែខ្លឹមសារ និងការរៀបចំអំណាចសាធារណៈខុសៗគ្នា ពីរបបនយោបាយមួយ ទៅរបបនយោបាយមួយទៀត ដែលមាននៅក្នុងប្រទេសនីមួយៗ។

ក្នុងលក្ខណៈជារដ្ឋ ប្រទេសកម្ពុជាមានរដ្ឋធម្មនុញ្ញដូចបណ្ដារដ្ឋឯទៀត តែរដ្ឋធម្មនុញ្ញបច្ចុប្បន្នហៅថា រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ មិនមែនជារដ្ឋធម្មនុញ្ញលើកដំបូងរបស់កម្ពុជាទេ។ អ្នកប្រវត្តិសាស្ត្រខាងផ្នែកច្បាប់ខ្មែរបានធ្វើការសិក្សាស្រាវជ្រាវទៅលើសិលាចារឹកតែមួយប៉ុណ្ណោះ តួយ៉ាងដូចជាសិលាចារឹក ស្ដីពីឥទ្ធិពលផ្នែកសាសនាតែងតែបញ្ញត្តិដាក់ទោសមុនគេបង្អស់ដើម្បីរក្សារបៀបរៀបរយសង្គមអោយបានល្អ មុននឹងមានការផ្ដួចផ្ដើមគំនិតធ្វើច្បាប់សម្រាប់រក្សារបៀបរៀបរយសង្គមមែនទែននោះ នេះបានសេចក្ដីថា រដ្ឋមួយប្រកបដោយច្បាប់គ្រប់គ្រងយ៉ាងត្រឹមត្រូវនោះ ត្រូវមានក្បួនខ្នាតជាក់លាក់ដែលបានចាប់កកើតនៅក្នុងប្រទេសខ្មែរតាំងពីសម័យអង្គរមកម្លេះ។ ខ្មែរយើងក្រោយមកបានយកលំនាំច្បាប់សម័យអង្គរមកគួបផ្សំបញ្ចូលជាមួយច្បាប់របស់បច្ចឹមប្រទេសពិសេសគឺច្បាប់ប្រទេសបារាំង ដើម្បីកសាងច្បាប់របស់ខ្លួនផ្ទាល់ជាបន្តបន្ទាប់រហូតដល់បច្ចុប្បន្ននេះ យើងមានច្បាប់រដ្ឋធម្មនុញ្ញ៦ ដែលរដ្ឋធម្មនុញ្ញនីមួយៗបានកំណត់នូវសម័យកាលមួយខុសៗគ្នា ចាប់តាំងពីឆ្នាំ១៩៤៧មកដល់បច្ចុប្បន្ននេះ។ មូលហេតុដែលនាំអោយមានរដ្ឋធម្មនុញ្ញដល់ទៅ៦លើកនោះ ដោយសារសភាពការណ៍នយោបាយនៅក្នុងប្រទេសកម្ពុជាមានការវិវត្ត និងប្រែប្រួលទៅតាមសភាពការណ៍សង្គម និងសភាពការណ៍ពិភពលោក ដែលផ្ដើមចេញក្រោយពីសង្គ្រាមលោកលើកទី២ ពេលនោះពិភពលោកទាំងមូលបានធ្លាក់ចូលទៅក្នុងសង្គ្រាមត្រជាក់ ហើយដែលបានបែងចែកជាពីរប្លុកគឺ ប្លុកសេរី និងប្លុកកុម្មុយនីស្ត។

## ២.ប្រវត្តិដើមនៃរដ្ឋធម្មនុញ្ញ

២.១.សញ្ញាណរដ្ឋធម្មនុញ្ញ

ជាទូទៅនៅក្នុងការគ្រប់គ្រងរដ្ឋ ឬគ្រប់គ្រងសង្គមអោយមានរបៀបរៀបរយសណ្តាប់ធ្នាប់ល្អត្រូវតែមានច្បាប់ជាមូលដ្ឋានគ្រឹះមួយទោះបីរដ្ឋនោះប្រកាន់នូវរបបនយោបាយអ្វីក៏ដោយ ម្ល៉ោះហើយបានជាអ្នកច្បាប់មួយចំនួនគេទាមទារអោយបង្កើត ***រដ្ឋធម្មនុញ្ញ*** ។ ព្រោះរដ្ឋធម្មនុញ្ញជាលក្ខន្តិកៈ គតិយុត្តិនៃរដ្ឋ។ រដ្ឋធម្មនុញ្ញទាំងអស់អាចជារដ្ឋធម្មនុញ្ញតាមទំនៀមទំលាប់ "***ឥតសរសេរ***" ដូចជានៅប្រទេសអង់គ្លេស។ ឬអាចជា "**រដ្ឋធម្មនុញ្ញសរសេរ**" ដូចដែលមាននៅក្នុងប្រទេសភាគច្រើនក្នុងសកលលោក។

២.២.និយមន័យ

តាមន័យទស្សនៈសំភារៈ គឺជាច្បាប់គ្រឹះ និងជាច្បាប់កំពូលនៃរដ្ឋដែលជាទូទៅកំណត់នូវរចនាសម្ព័ន្ធ និងមុខងារសំខាន់ៗជាមូលដ្ឋាននៃរដ្ឋ និងជាអង្គការរដ្ឋសំខាន់ៗ ព្រមទាំងកំណត់នូវសិទ្ធិ និងកាតព្វកិច្ចជាមូលដ្ឋានរបស់ពលរដ្ឋ។

តាមន័យទម្រង់ៈ រដ្ឋធម្មនុញ្ញ គឺជាកម្រងឯកសារមួយដែលនិយាយអំពីស្ថាប័ននយោបាយ ដែលគេបានរៀបចំតាក់តែងឡើង និងធ្វើវិសោធនកម្មគោរពទៅតាមនីតិវិធី ដែលមានលក្ខណៈខុសពីធ្វើច្បាប់ធម្មតា។[១]

គ្រប់រដ្ឋទាំងអស់នៅក្នុងពិភពលោក គឺត្រូវមានរដ្ឋធម្មនុញ្ញរបស់ខ្លួន។ គ្រឿងឧបករណ៍គរុភ័ណ្ឌសម្រាប់គ្រប់គ្រងរដ្ឋទំនើបតាមបែបប្រជាធិបតេយ្យដ៏សំខាន់ជាងគេគឺ រដ្ឋធម្មនុញ្ញ។ រដ្ឋធម្មនុញ្ញតែងតែបង្ហាញអោយឃើញជាញឹកញាប់នូវតម្លៃជានិមិត្តរូប តម្លៃខាងទស្សនវិជ្ជា និងតម្លៃគតិយុត្តិ។

ដោយរដ្ឋមួយអាចមានរដ្ឋធម្មនុញ្ញច្រើនក្នុងប្រវត្តិនយោបាយរបស់ខ្លួន គេតែងតែបញ្ជាក់ថា រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំនេះ ឬឆ្នាំនោះ ទើបគ្មានការភ័ន្តច្រឡំ។ កាលណាមានរដ្ឋធម្មនុញ្ញថ្មីកើតឡើង រដ្ឋធម្មនុញ្ញត្រូវចាស់ចូលនិវត្តន៍ ព្រោះគោលដៅនៃរដ្ឋធម្មនុញ្ញថ្មី គឺសម្រាប់ជំនួសរដ្ឋធម្មនុញ្ញចាស់ដែលគេលែងត្រូវការ។ គេបង្កើតថ្មីមិនមែនសម្រាប់ប្រើទាំងពីរទាំងបីក្នុងដំណាលគ្នានោះទេគឺ មានន័យថាគេបំបាត់រដ្ឋធម្មនុញ្ញចាស់ ដែលមិនស្របនឹងការវិវត្តន៍នៃរបបនយោបាយថ្មី។ ការបំបាត់រដ្ឋធម្មនុញ្ញចាស់ចោលមិនមានន័យថា បណ្តាបទដ្ឋានច្បាប់ដទៃទៀតដូចជា ក្រម ក្រឹត្យ អនុក្រឹត្យ ប្រកាស ដីកា រាជធានី/ខេត្ត សេចក្តីសម្រេច . . . ត្រូវលុបចោលទាំងនោះទេ។

តម្លៃជានិមិត្តរូបរបស់រដ្ឋធម្មនុញ្ញ គឺមានន័យថារដ្ឋធម្មនុញ្ញគឺជានិមិត្តរូបមុនច្បាប់ដទៃទៀត លើសពីនេះទៀត រដ្ឋធម្មនុញ្ញបានដើរតួនាទីជាអ្នកបង្កើតរដ្ឋ និងជាច្រកទ្វារ ដែលធ្វើអោយមានលទ្ធភាពឈានជើងចូលក្នុងសហគមន៍អន្តរជាតិ ជាក់ស្តែងដូចជានៅសហរដ្ឋអាមេរិកជាដើម។ និមិត្តរូបរបស់រដ្ឋធម្មនុញ្ញមិនត្រូវបានកំណត់ដោយអត្ថិភាពរបស់រដ្ឋទេ ហើយនិមិត្តរូបរបស់រដ្ឋធម្មនុញ្ញតែងតែបង្ហាញអោយឃើញនៅពេលមានការផ្លាស់ប្តូររបបគ្រប់គ្រងរបស់ប្រទេសម្តងៗ។ ក្នុងន័យនេះ រដ្ឋធម្មនុញ្ញជាមូលដ្ឋានគ្រឹះនៃរបបគ្រប់គ្រងរដ្ឋ។ នៅក្នុងកាលៈទេសៈពិសេសគេប្រាថ្នាចង់អោយរដ្ឋធម្មនុញ្ញមានតួនាទីបញ្ចប់នូវរយៈពេលដែលមិនមានភាពច្បាស់លាស់ និងពុំមានសណ្តាប់ធ្នាប់ ហើយជានិមិត្តរូបមួយសម្រាប់ធ្វើប្រក្រតីកម្មអោយមកសភាពធម្មតាវិញការបែងចែកអំណាចរដ្ឋ និងដំណើរការរដ្ឋប្រកបដោយភាពត្រឹមត្រូវ។

---

[១] អត្ថបទមេរៀនសាស្ត្រាចារ្យ ជុំ អ៊ីម នៃសាកលវិ.ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

រដ្ឋធម្មនុញ្ញ បង្ហាញជាតម្លៃទស្សនវិជ្ជា "នីតិរដ្ឋ" នៅក្នុងផ្នែកទស្សនវិជ្ជានយោបាយដែលពាក់ព័ន្ធទៅនឹងដែនកំណត់អំណាចរដ្ឋ ហើយតម្លៃខាងទស្សនវិជ្ជានៃទ្រឹស្តីនៃការកំណត់អំណាច គឺជាមូលដ្ឋានគ្រឹះនៅការតាក់តែងរដ្ឋធម្មនុញ្ញ។

រដ្ឋធម្មនុញ្ញ មានតម្លៃជាប្រព័ន្ធគតិយុត្តិ គឺមានន័យថារដ្ឋធម្មនុញ្ញគឺជាបណ្តុំនៃវិធានគតិយុត្តិ សម្រាប់រៀបចំជីវភាពសង្គម និងនយោបាយ និងតម្រូវការអោយច្បាប់សង្គមទាំងអស់ត្រូវគោរពតាមទម្រង់នៃរដ្ឋធម្មនុញ្ញ។

សរុបសេចក្តីមក រដ្ឋធម្មនុញ្ញ គឺជាសេចក្តីថ្លែងការណ៍ជាផ្លូវការនៃកាតព្វកិច្ចជាមូលដ្ឋាន ការកម្រិតសិទ្ធិអំណាចនីតិវិធី និងស្ថាប័នរបស់រដ្ឋាភិបាល។ រដ្ឋធម្មនុញ្ញ ជាច្បាប់កំពូលតម្រូវអោយសមាជិកទាំងអស់នៅក្នុងសង្គមត្រូវគោរពតាមជាដាច់ខាត។ រដ្ឋធម្មនុញ្ញជាទូទៅប្រមូលចងក្រងលាយលក្ខណ៍អក្សរ ប្រកាសបង្កើតអំណាចរបស់រដ្ឋ ដើម្បីផ្តល់ការធានាដល់សិទ្ធិមនុស្សជាមូលដ្ឋាន និងកំណត់ឡើងនូវនីតិវិធីជាមូលដ្ឋានសម្រាប់ដំណើរការរដ្ឋ។

២.៣.ប្រវត្តិដើមនៃរដ្ឋធម្មនុញ្ញ

តាំងពីយូរលង់ណាស់មកហើយ ដោយសារមនុស្សពុំទាន់ចេះប្រើអត្ថបទច្បាប់សម្រាប់កំណត់នៅឡើយ គឺការគ្រប់គ្រងសង្គមពុំមានអ្វីកំណត់អំពីនៃអំណាចបានឡើយ។ ដូច្នោះរបៀបវិធាននៃការគ្រប់គ្រងសង្គម និងការដំណើរការនូវស្ថាប័ននានារបស់រដ្ឋ គឺដោយផ្អែកជាសំខាន់ទៅលើទំនៀមទំលាប់ ប្រពៃណីជាខ្នាតរង្វាស់រង្វាល់ និងជាឧបករណ៍កំណត់នូវរបៀបនៃការគ្រប់គ្រងរដ្ឋ។ ក្នុងន័យនេះយើងអាចនិយាយបានថា ប្រភពដើមរបស់រដ្ឋធម្មនុញ្ញ គឺជាប្រពៃណី ទំនៀមទំលាប់នេះឯង។

ប៉ុន្តែស្របពេលជាមួយគ្នានេះដែរ អត្ថបទសរសេរត្រូវបានគេបញ្ចូលបន្តិចម្តងៗចូលទៅក្នុងរដ្ឋធម្មនុញ្ញ ដែលមានលក្ខណៈជាទំនៀមទំលាប់ ដើម្បីមានភាពងាយស្រួលក្នុងការគ្រប់គ្រងរដ្ឋ និងការកំណត់នូវគោលការណ៍នៃការប្រព្រឹត្តទៅនៃអំណាចរដ្ឋ។ ដូច្នោះនាពេលនោះសមាសធាតុនៃរដ្ឋធម្មនុញ្ញ គឺផ្អែកលើការសរសេរផង និងផ្អែកលើធាតុប្រពៃណីទំនៀមទំលាប់ផង។

រដ្ឋធម្មនុញ្ញជាអត្ថបទដំបូងគេបំផុត គឺមានកំណើតនៅប្រទេសក្រិច ក្នុងរវាងសតវត្សទី៨ និងសតវត្សទី៧ មុនគ្រិស្តសករាជ ហើយបន្ទាប់មកទៀតនៅទីក្រុងរ៉ូម បានបង្កើតឡើងនូវអត្ថបទរដ្ឋធម្មនុញ្ញរបស់ខ្លួនដោយបានចែងយ៉ាងលំអិតអំពី ការដំណើរការ និងការប្រព្រឹត្តទៅរបស់ស្ថាប័ននយោបាយរបស់រដ្ឋ។

ឆ្លងកាត់នូវរយៈពេលជាច្រើនសតវត្សកន្លងមក ទើបមានការចាប់កំណើតនូវរដ្ឋធម្មនុញ្ញទំនើបនៅចុងសតវត្សទី១៨ នៃគ្រិស្តសករាជ។ ហើយកំណើតរដ្ឋធម្មនុញ្ញទំនើបដំបូងបង្អស់ ត្រូវបានបង្កើតឡើងដោយសហរដ្ឋអាមេរិចនៅឆ្នាំ១៧៧៦ រហូតដល់ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៧៨៧ គម្រោងរដ្ឋធម្មនុញ្ញនេះដែលក្លាយជារដ្ឋធម្មនុញ្ញរបស់សហព័ន្ធ។ នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ១៧៩១ ប្រទេសប៉ូឡូញបានប្រកាសអោយប្រើនូវរដ្ឋធម្មនុញ្ញរបស់ខ្លួន ហើយចំណែកឯប្រទេសបារាំងបានអនុម័តរដ្ឋធម្មនុញ្ញ និងប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៧៩១។ ហើយប្រទេសនានាដែលមានការរីកលូតលាស់ បានរៀបរៀងនូវរដ្ឋធម្មនុញ្ញរបស់ខ្លួនជាបន្តបន្ទាប់រួមមានៈ ប្រទេសស៊ុយអែត នៅឆ្នាំ១៨០៩ ប្រទេសវេណេស៊ុយអេឡា នៅឆ្នាំ១៨១១ និងប្រទេសអេស្ប៉ាញ នៅឆ្នាំ១៨១២ជាដើម។

បន្តិចម្តងៗគោលគំនិតវិធាននៃការគ្រប់គ្រងរដ្ឋ ត្រូវភ្ជាប់ទៅនឹងរដ្ឋធម្មនុញ្ញដែលមានចែង និងចារឹកទុកយ៉ាងច្បាស់លាស់សម្រាប់អនុវត្ត។ ហើយទ្រឹស្តីគោលការណ៍ជាមូលដ្ឋាន និងតួនាទីរបស់រដ្ឋធម្មនុញ្ញកាន់តែមានការរីកចម្រើន និងធ្វើបដិវត្តកម្មឈានឡើងជាលំដាប់ចាប់ពីឆ្នាំ១៨៣០ និងឆ្នាំ១៨៤៨ និងបន្ទាប់ពីការបញ្ចប់នូវសង្គ្រាមលោកលើកទី២ និងការបញ្ចប់នូវរបបអាណានិគមនិយមនៅលើពិភពលោក។ តាមរយៈនេះបណ្តារដ្ឋជា

ច្រើនដែលទើបតែទទួលបានឯករាជ្យ បានរៀបចំអោយមានយន្តការដំណើរការស្ថាប័នរបស់ខ្លួនតាមរយៈការតាក់តែងរដ្ឋធម្មនុញ្ញរបស់ខ្លួនជាមូលដ្ឋានគ្រឹះសម្រាប់គ្រប់គ្រងរដ្ឋរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។ ទន្ទឹមនឹងនេះដែរ បណ្តារដ្ឋទាំងឡាយដែលមានរដ្ឋធម្មនុញ្ញតាមបែបបុរាណ បានធ្វើទំនើបកម្មលើរដ្ឋធម្មនុញ្ញរបស់ខ្លួនដើម្បីសម្របតាមទិដ្ឋភាពថ្មីរបស់ពិភពលោកដែរ។

ជាក់ស្តែងនៅប្រទេសបារាំងគេបានប្តូររដ្ឋធម្មនុញ្ញជាច្រើនលើច្រើនសារស្ទើររាប់មិនអស់។ ប៉ុន្តែមានព្រះរាជក្រមតាំងពីសតវត្សទី១៧ មួយចំនួននៅតែមានប្រសិទ្ធភាពអនុវត្តរហូតដល់សព្វថ្ងៃ។ បើតាមការសង្កេតយើងឃើញថា មានតែបដិវត្តទេដែលតែងលុបគ្រប់បទដ្ឋានច្បាប់ទាំងអស់ចោល ជាក់ស្តែងដូចជា កម្ពុជាប្រជាធិបតេយ្យ។ ក្រោយពេលរបបនេះត្រូវបានផុតជីវិតទៅរបបថ្មីតែងស្តារយកបទដ្ឋានចាស់ទាំងអស់មកប្រើដដែល លើកលែងតែរដ្ឋធម្មនុញ្ញមួយចេញប៉ុណ្ណោះ នេះអាចបញ្ជាក់បានថា រដ្ឋធម្មនុញ្ញគ្មានការទាក់ទងដាច់ខាតជាមួយបណ្តាលច្បាប់ផ្សេងៗទៀតទេ។ ទិដ្ឋភាពដែលបានបង្ហាញខាងលើ ធ្វើអោយយល់បានថា ***រដ្ឋធម្មនុញ្ញ*** ជាបទដ្ឋានដាច់ដោយឡែកពីបទដ្ឋានច្បាប់នានា។

ម្យ៉ាងវាប្លែកពីច្បាប់ផ្សេងទៀតត្រង់ថា រដ្ឋធម្មនុញ្ញត្រូវបានគេ **ចែងតាមវិធីឱឡារិក** ជាងច្បាប់ឯទៀត។ រីឯការធ្វើវិសោធនកម្មនៃរដ្ឋធម្មនុញ្ញ ក៏ត្រូវតាមវិធីឱឡារិក ជាងវិសោធនកម្មនៃច្បាប់សាមញ្ញ។

មួយវិញទៀតវាខុសប្លែកពីបទដ្ឋានច្បាប់ផ្សេងទៀត ព្រោះគេតែងចែងក្នុងរដ្ឋធម្មនុញ្ញតែចំណុចធំៗ ដូចជាអ្នកម្ចាស់អធិបតេយ្យក្នុងរដ្ឋ(**តើម្ចាស់នេះជាព្រះមហាក្សត្រ ឬជាពលរដ្ឋ?**) តើរដ្ឋរាជាណាចក្រ ឬជាសាធារណរដ្ឋ? តើជារដ្ឋសហព័ន្ធ ឬជារដ្ឋទោល? ហើយបើគេចែងក្នុងរដ្ឋធម្មនុញ្ញទេ (ឧ. ច្បាប់ស្តីពីសហាយស្មន់ ច្បាប់ឯកពន្ធភាព ជាដើម) ឬច្បាប់ដែលមានចារឹករដ្ឋបាលមកចែងក្នុងរដ្ឋធម្មនុញ្ញទេ។

បើត្រូវចែងពីសិទ្ធិសេរីភាពប្រជាពលរដ្ឋ គេចែងក្នុងរដ្ឋធម្មនុញ្ញចំពោះសិទ្ធិសេរីភាពណាដែលជាគ្រឹះមិនមែនយកសិទ្ធិសេរីភាពតូចតាច ដូចជា សិទ្ធិចតរថយន្តតាមថ្នល់មកចែងនោះទេ ព្រោះវាតូចតាចពេក។

ជាទីបញ្ចប់រដ្ឋធម្មនុញ្ញជាច្បាប់ដាច់ដោយឡែក ដែលរដ្ឋសន្មត់ថាមានឧត្តមភាពលើច្បាប់នានា ដែលទាមទារការការពារមិនអោយច្បាប់ឯទៀតរំលោភបាន។

អាស្រ័យដោយការអធិប្បាយដូចខាងលើ គេអាចអោយនិយមន័យរដ្ឋធម្មនុញ្ញថា ជាច្បាប់ដោយឡែកពីបណ្តាច្បាប់ឯទៀត ដែលចែងតែអំពីស្ថាប័ន និងគោលការណ៍សំខាន់ៗដែលត្រូវបានបង្កើតឡើងនឹងកែប្រែតាមនីតិវិធីឱឡារិក ហើយរដ្ឋធម្មនុញ្ញគេចាត់ទុកថា ជាច្បាប់កំពូល។ ដូច្នេះ បានជានៅប្រទេសមួយចំនួន គេមិនអោយឈ្មោះរដ្ឋធម្មនុញ្ញតែគេហៅថា"ច្បាប់គ្រឹះ" ទៅវិញ ដូចជានៅប្រទេសអាឡឺម៉ង់ ជាដើម (Fundamental law) ។[២]

## ៣.ប្រភេទនៃរដ្ឋធម្មនុញ្ញ

ដោយយើងផ្អែកលើការវិវត្តខាងផ្នែកទ្រឹស្តី និងការអនុវត្តជាក់ស្តែងរបស់បណ្តារដ្ឋទាំងអស់ រួមទាំងជាមួយនឹងតួនាទីជាសារវន្តរបស់រដ្ឋធម្មនុញ្ញ រហូតមកទល់នឹងពេលនេះ គេអាចសិក្សាឃើញនូវប្រភេទរដ្ឋធម្មនុញ្ញសកលលោកនេះរួមមាន៖

### ៣.១.រដ្ឋធម្មនុញ្ញអត្ថបទសរសេរ និងរដ្ឋធម្មនុញ្ញឥតសរសេរ

តាមគោលការណ៍រដ្ឋធម្មនុញ្ញសរសេរ គឺត្រូវបានតំកល់ទុកក្នុងច្បាប់ ហើយរដ្ឋធម្មនុញ្ញពុំមានកំណត់ដោយអត្ថបទសរសេរ គឺត្រូវបានតំណាងដោយទំនៀមទំលាប់ ប្រពៃណី។ នៅក្នុងការអនុវត្តជាក់ស្តែងនៅក្នុងពិភពលោក

[២] ថោង ស៊ីម នីតិរដ្ឋធម្មនុញ្ញៈ បណ្ឌិត្យសភានគរបាលកម្ពុជា,ឆ្នាំ២០១១,ទំព័រទី១៦

យើងនេះ មានប្រទេសជាច្រើនដែលនិយមកំណត់រដ្ឋធម្មនុញ្ញរបស់ ជាអត្ថបទសរសេរដូចជា សហរដ្ឋអាមេរិកជាដើម។ ប៉ុន្តែប្រទេសអង់គ្លេស អ៊ីស្រាអែល និងញូវហ្សេឡែន ដែលរដ្ឋធម្មនុញ្ញរបស់ខ្លួនពុំបានតាក់តែងជាអត្ថបទសរសេរ។ រដ្ឋដែលពុំបានសរសេររដ្ឋធម្មនុញ្ញជាអត្ថបទ ពុំមែនមានន័យថារដ្ឋនោះពុំមានរដ្ឋធម្មនុញ្ញនោះដែរ។ ប៉ុន្តែក៏ពុំមានរដ្ឋធម្មនុញ្ញណាមួយដែលពុំបានសរសេរអ្វីសោះនោះដែរ។

ភាពដោយឡែករវាងរដ្ឋធម្មនុញ្ញទាំងពីរប្រភេទនេះ គឺផ្អែកលើចំណុចពិសេសត្រង់ថា រដ្ឋធម្មនុញ្ញសរសេរគឺមានការសរសេរច្បាស់លាស់ និងជាអត្ថបទដែលមានពាក្យពេចន៍ ឃ្លោងឃ្លាច្រើន និងវែងជាង។ ជាក់ស្តែងរដ្ឋធម្មនុញ្ញរបស់សហរដ្ឋអាមេរិក មានចំនួន ៧០០០ពាក្យ (រដ្ឋធម្មនុញ្ញរបស់រដ្ឋនីមួយៗវែងជាងរដ្ឋធម្មនុញ្ញសហព័ន្ធ) ដែលមានចែងអំពីគោលការណ៍យ៉ាងទូលំទូលាយអំពីរាជរដ្ឋាភិបាល ទោះបីជាបានចែងយ៉ាងច្បាស់លាស់អំពីបញ្ញត្តិនៃការបោះឆ្នោតដោយសមធម៌ និងពុំបានសង្កត់ធ្ងន់អោយបានច្បាស់លាស់នូវចំណុចមួយចំនួន(ការរៀបចំការប្រព្រឹត្តទៅ និងចំនួនចៅក្រមក្នុងតុលាការកំពូល)។ ដោយឡែករដ្ឋធម្មនុញ្ញដទៃទៀតដូចជា ចក្រភពអង់គ្លេសជាដើម គឺដំណើរការដោយផ្អែកលើអនុសញ្ញាធម្មនុញ្ញ(Conventions) ជាពិសេសវិធាននៃដំណើរការប្រព្រឹត្តទៅដោយឈរលើទំនៀមទំលាប់ និងការអនុវត្តដែលមានពីមុនមក ហើយវិធានណែនាំជាទូទៅគឺមានភាពមិនច្បាស់លាស់ មិនពេញលេញ គេឈប់និយមប្រើ ឬពុំមានអត្ថិភាព។

### ៣.២.កម្រងរដ្ឋធម្មនុញ្ញតែមួយ និងរដ្ឋធម្មនុញ្ញដែលពុំបានចងក្រងជាអត្ថបទរដ្ឋធម្មនុញ្ញតែមួយ

កម្រងរដ្ឋធម្មនុញ្ញតែមួយ(Condified Constitrution) គឺជារដ្ឋធម្មនុញ្ញដែលប្រមូលចងក្រងនូវវិធានទាំងអស់របស់រដ្ឋធម្មនុញ្ញ ជាអត្ថបទច្បាប់រួមមួយហើយរដ្ឋធម្មនុញ្ញនេះគឺជាច្បាប់ការពារការកែប្រែរបស់រាជរដ្ឋាភិបាលក្នុងពេលវេលាណាមួយ។ រដ្ឋធម្មនុញ្ញនេះ គឺមានការពិបាកណាស់ក្នុងការធ្វើវិសោធនកម្ម។ ជាក់ស្តែងដូចជា រដ្ឋធម្មនុញ្ញរបស់សហរដ្ឋអាមេរិក ក្នុងរយៈពេលជា២០០ឆ្នាំនេះ បានធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញរបស់ខ្លួនតែ ២៧លើកប៉ុណ្ណោះ។ កម្រងរដ្ឋធម្មនុញ្ញតែមួយ គឺជានិមិត្តរូបនៃច្បាប់កំពូលនៅលើផែនដីនេះ និងច្បាប់កំពូលរបស់ជាតិនីមួយៗទាមទារអោយមានការប្រកាន់ខ្ជាប់នូវគោលការណ៍ទាំងអស់ដែលបានចែង និងកម្រិតព្រំដែននៃអំណាចរបស់ស្ថាប័នទាំងអស់ និងបង្កើតអោយមាននូវឋានានុក្រមគតិយុត្តិ។

ដោយឡែករដ្ឋធម្មនុញ្ញដែលពុំបានចងក្រងជាអត្ថបទរដ្ឋធម្មនុញ្ញតែមួយ គឺជារដ្ឋធម្មនុញ្ញដែលពុំបានធ្វើការប្រមូលចងក្រងនូវវិធានធម្មនុញ្ញទាំងអស់ធ្វើជាអត្ថបទរដ្ឋធម្មនុញ្ញតែមួយ ឬអាចនិយាយបានថា ជារដ្ឋធម្មនុញ្ញដែលមានប្រភពជាច្រើនដូចជា Starue Law, Common Low, អនុសញ្ញា, យុត្តិសាស្ត្ររបស់តុលាការ និងការអនុវត្តរបស់អាជ្ញាធរ។ ជាក់ស្តែងដូចជាចក្រភពអង់គ្លេស ប្រភពរដ្ឋធម្មនុញ្ញ គឺរួមមានៈ លក្ខន្តិកៈMegna Carta 125 និងច្បាប់លេខ១៧០១(Act of settlement of 1701) និងច្បាប់ និងទំនៀមទំលាប់របស់សភា(Laws and Customs of Parliament) អនុសញ្ញានយោបាយ(Political Convention) រួមជាមួយនឹងច្បាប់យុត្តិសាស្ត្រ(Case Law)ពាក់ព័ន្ធនឹងរដ្ឋធម្មនុញ្ញដែលសម្រេចដោយតុលាការ និងការចងក្រងរបស់អ្នកជំនាញខាងរដ្ឋធម្មនុញ្ញដូចជាលោក Walter Bagehot និងលោក A. V Dicey ជាដើម។

### ៣.៣.រដ្ឋធម្មនុញ្ញរាជានិយម និងរដ្ឋធម្មនុញ្ញសាធារណរដ្ឋនិយម

រដ្ឋធម្មនុញ្ញរាជានិយម គឺជារដ្ឋធម្មនុញ្ញដែលនៅក្នុងរដ្ឋធម្មនុញ្ញនេះបានចែងនូវគោលការណ៍នៃការគ្រប់គ្រងដោយព្រះមហាក្សត្រ ជាវិធានដ៏ខ្ពង់ខ្ពស់បំផុតរបស់រដ្ឋធម្មនុញ្ញ។ ដោយឡែករដ្ឋធម្មនុញ្ញសាធារណរដ្ឋនិយម អំណាចនយោបាយទាំងអស់កើតចេញពីការព្រមព្រៀងរបស់ប្រជាពលរដ្ឋទាំងមូល។

រដ្ឋធម្មនុញ្ញរាជានិយម កើតមានឡើងនៅពេលណាដែលបុព្វសិទ្ធិរបស់ព្រះមហាក្សត្រ ឬមហាក្សត្រីយានី ត្រូវបានផ្តល់អោយដោយលក្ខន្តិកៈច្បាប់ និងរដ្ឋធម្មនុញ្ញ ហើយបុព្វសិទ្ធិនេះត្រូវបានអនុវត្តដោយសភា និងរាជរដ្ឋាភិបាលក្នុងនាមព្រះមហាក្សត្រ ឬមហាក្សត្រីយានី។

៣.៤.រដ្ឋធម្មនុញ្ញឯកត្តរដ្ឋ និងរដ្ឋធម្មនុញ្ញសហព័ន្ធ

រដ្ឋធម្មនុញ្ញឯកត្តរដ្ឋ អធិបតេយ្យរបស់ជាតិគឺ ត្រូវប្រមូលផ្តុំមកតែមួយនៅថ្នាក់ជាតិ ដូចជាករណីនៃសភាចក្រភពអង់គ្លេសជាដើម។

នៅក្នុងប្រព័ន្ធរដ្ឋធម្មនុញ្ញសហព័ន្ធអធិបតេយ្យជាតិត្រូវបានបែងចែកជាពីរ ឬច្រើនកម្រិតនៅក្នុងរដ្ឋាភិបាលទាំងមូល ដែលត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ។ ក្នុងគោលការណ៍នេះរដ្ឋសហព័ន្ធមិនអាចរំលោភបំពានលើអំណាចរបស់រដ្ឋាភិបាលជាសមាជិកបានទេ។ ក្នុងន័យនេះគោលបំណងសហព័ន្ធនិយមគឺដើម្បីសង្គ្រោះនូវឯកភាពជាតិដោយរក្សានូវភាពទីទៃពីគ្នាតាមតំបន់នីមួយៗ។

៣.៥. រដ្ឋធម្មនុញ្ញសភានិយម និងរដ្ឋធម្មនុញ្ញប្រធានាធិបតីនិយម

នៅក្នុងរដ្ឋធម្មនុញ្ញសភានិយម រដ្ឋាភិបាលដែលតំណាងអោយអំណាចនីតិប្រតិបត្តិ ត្រូវកើតចេញពីសភា និងត្រូវទទួលខុសត្រូវចំពោះមុខរដ្ឋសភា។ ដូចជានៅប្រទេសអង់គ្លេស គឺរដ្ឋាភិបាលត្រូវទទួលខុសត្រូវចំពោះមុខរដ្ឋសភា ហើយនាយករដ្ឋមន្ត្រីទាំងអស់សុទ្ធតែជាសមាជិកនៃ The house of common or the House of Lords។

នៅក្នុងរដ្ឋធម្មនុញ្ញប្រធានាធិបតីនិយម គឺជាប្រមុខរដ្ឋនៃអំណាចតំណាងអោយអង្គការនីតិប្រតិបត្តិ ហើយប្រធានាធិបតីមិនមែនជាសមាជិកនៃអំណាចនីតិប្រតិបត្តិឡើយ និងត្រូវបានបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា។

៣.៦.រដ្ឋធម្មនុញ្ញតឹងរឹង និងរដ្ឋធម្មនុញ្ញងាយបត់បែន

រដ្ឋធម្មនុញ្ញតឹងរឹង គឺជារដ្ឋធម្មនុញ្ញដែលបានដាក់កំហិតយ៉ាងតឹងរឹងចំពោះការប៉ុនប៉ងធ្វើការកែប្រែលុបចោល វិសោធនកម្មលើស្មារតីនៃរដ្ឋធម្មនុញ្ញដែលបានចែងពីមុនមករួចហើយ ហើយថែមទាំងមានការហាមឃាត់មិនអាចកែប្រែ ឬវិសោធនកម្មបាននូវមាត្រាខ្លះៗទៀតផង។

ចំណែកឯរដ្ឋធម្មនុញ្ញងាយបត់បែន គឺជារដ្ឋធម្មនុញ្ញដែលមានលក្ខណៈទន់ភ្លន់ ងាយបត់បែន មានន័យថាខ្លឹមសារដែលមានចែងក្នុងរដ្ឋធម្មនុញ្ញរួចហើយ ងាយស្រួលក្នុងការធ្វើការកែប្រែ និងងាយស្រួលក្នុងការអនុវត្ត ដូចជា ច្បាប់ធម្មតាពុំមានដាក់កម្រិតចំនួនភាគច្រើនធំៗដូចជា ពីរភាគបី(២/៣) ឬបីភាគបួន(៣/៤) ឬដាក់បំរាមធ្វើអ្វីផ្សេងថែមទៀត។

## ៤.ប្រភេទរដ្ឋធម្មនុញ្ញ

ប្រភេទរដ្ឋធម្មនុញ្ញមានពីរគឺ រដ្ឋធម្មនុញ្ញលាយល័ក្ខអក្សរ និងរដ្ឋធម្មនុញ្ញប្រពៃណី

រដ្ឋធម្មនុញ្ញកម្ពុជាទាំង៦ ជាឧបករណ៍នៃរដ្ឋធម្មនុញ្ញសរសេរជាលាយល័ក្ខអក្សរដូចជា បណ្តារដ្ឋឯទៀតលើពិភពលោកសព្វថ្ងៃដែរ។ រដ្ឋដែលនាំមុខសរសេររដ្ឋធម្មនុញ្ញ ជាលាយល័ក្ខអក្សរមុនគេគឺ **សហរដ្ឋអាមេរិក** ក្រោយពីសង្គ្រាមបង្រួបបង្រួមរវាងរដ្ឋតូចៗនានា បង្កើតបានជាសហរដ្ឋនៅឆ្នាំ១៧៨៧។ ប៉ុន្មានឆ្នាំបន្ទាប់មក ប្រទេសបារាំង ក៏បានជួបប្រទះនឹងបដិវត្តទម្លាក់រាជានិយម ហើយពួកបដិវត្តក៏បានតាក់តែងរដ្ឋធម្មនុញ្ញសរសេរលើកទីមួយ

ដូចជាសហរដ្ឋអាមេរិក គឺឆ្នាំ១៧៩១។ បន្ទាប់មកបណ្តាប្រទេសនៃទ្វីបអឺរ៉ុប ក៏យកតម្រាប់តាមនេះដូចជាៈ ស៊ុយអែដ រដ្ឋធម្មនុញ្ញឆ្នាំ១៨០៩ , អេស្បាញ ឆ្នាំ១៨១២ , ន័រវេ ឆ្នាំ១៨១៤ , ហូឡង់ ឆ្នាំ១៨១៥ ។ល។

សព្វថ្ងៃនេះ មានតែរដ្ឋធម្មនុញ្ញអង់គ្លេសមួយគត់ ដែលមិនមានរដ្ឋធម្មនុញ្ញសរសេរ។ ដូច្នេះជាការខាតពេលវេលា បើនរណាម្នាក់ចង់ស្គាល់របៀបគ្រប់គ្រងរដ្ឋអង់គ្លេស ហើយដើរតាមបណ្ណាគាររកទិញរដ្ឋធម្មនុញ្ញប្រទេសនោះ។ ជាក់ស្តែងបើគេស្រាវជ្រាវរកបទដ្ឋានច្បាប់ ទាក់ទងនឹងការគ្រប់គ្រងប្រទេសអង់គ្លេស គេនឹងជួបតែព្រះរាជក្រមពីរគឺ Parliament Act ឆ្នាំ១៩១១ និង ឆ្នាំ១៩៤៩ ស្តីពីការកាត់បន្ថយអំណាចសភាជាន់ខ្ពស់អោយតូចជាងអំណាចសភាជាន់ទាប។ ព្រះរាជក្រមទាំងពីរនេះ មានទ្រង់ទ្រាយជាក្រមធម្មតា វាមិនមែនជា "**រដ្ឋធម្មនុញ្ញ**" ទេ។ ផ្ទុយទៅវិញរាល់ស្ថាប័នដូចជា ព្រះមហាក្សត្រ សភា រដ្ឋាភិបាល វិធីបោះឆ្នោត មិនដែលត្រូវបានចែងដោយអត្ថបទសរសេរណាមួយទេ។ ប៉ុន្តែប្រការគួរអោយឆ្ងល់បំផុត ស្ថាប័នទាំងនោះមានដំណើរការយ៉ាងរលូន និងទៀងទាត់ មិនដែលមានភាពរកាំរកូសប្រៀបបានជាសង្វាក់ផលិតកម្មនៃឧស្សាហកម្មទំនើបថ្មីស្រឡាងមួយ បើធ្វើការប្រៀបធៀបទៅនឹងស្ថាប័ននយោបាយនៅបណ្តាប្រទេសនានា ដែលមានចែងយ៉ាងលំអិតក្នុងរដ្ឋធម្មនុញ្ញ តែត្រូវថ្នាក់ដឹកនាំ ទុកចោល មិនសូវចាប់អារម្មណ៍ ដែលធ្វើអោយឃ្លាតឆ្ងាយខ្លឹមសារដែលបានអនុម័តរួច។ ជាក់ស្តែងប្រទេសអង់គ្លេស បានទទួលស្គាល់សិទ្ធិមួយចំនួនដល់ពលរដ្ឋ ហើយការវិវត្តនេះចេះតែមានដំណើរការមួយជំហានម្តងៗ បង្កើតជាទំនៀមទំលាប់ច្បាស់លាស់ ដោយពុំទាន់មានជនជាតិអង់គ្លេសណាម្នាក់នឹកឃើញចង់ចងក្រងជាច្បាប់រដ្ឋធម្មនុញ្ញសរសេរនៅឡើយទេ។ តើគេសរសេរធ្វើអ្វី? បើជនជាតិអង់គ្លេសម្នាក់ៗ គេគោរពទំនៀមទំលាប់គ្រប់ៗគ្នា ព្រោះពួកគេចិត្តជាអ្នកកីឡា មិនមានទំលាប់ដើរខ្សែរលើគ្នា។ បើសរសេរនាំតែបង្កើតអោយមានបាតុភាព ដោយហេតុថា ការសរសេរមិនដែលឆ្លុះបញ្ចាំងអំពីតថភាព ១០០ភាគរយទេ ហើយបើមានការសរសេរនឹងតម្រូវអោយមានការធ្វើវិសោធនកម្មជាលាយល័ក្ខអក្សរ ដែលនៅពេលដែលសភាពការណ៍ផ្លាស់ប្តូរ។ ផ្ទុយទៅវិញទំនៀមទំលាប់មិនដែលទាមទារវិសោធនកម្មអ្វីទេ គឺគ្រាន់តែយកទំលាប់ថ្មីមកជំនួសទំលាប់ចាស់ ហើយទាំងអស់គ្នានាំគ្នាគោរពទំលាប់ថ្មីជាការស្រេច។

អ្នកវិភាគច្បាប់មិននិយាយថា អង់គ្លេសគ្មានរដ្ឋធម្មនុញ្ញនោះទេ គេនិយាយថា **អង់គ្លេសគ្មានរដ្ឋធម្មនុញ្ញសរសេរ តែពិតជាមានរដ្ឋធម្មនុញ្ញប្រពៃណីច្បាស់លាស់**។ តែកុំយល់ច្រឡំថា រដ្ឋនានាអាចយកគំរូតាមអង់គ្លេសបាន ព្រោះលើពិភពលោកនេះគ្មានជនជាតិណាមានចរឹកដូចជនជាតិអង់គ្លេស ដែលមានចរិយាសម្បត្តិមួយខុសគេ ហើយដែលអង់គ្លេសគ្នាគេអោយឈ្មោះថា " Fair play" ប្រៀបបាននឹងកីឡាប្រដាល់អង់គ្លេស ដែលភាគីប្រដាល់មិនលេងស្នៀតអ្វីដែលហាមឃាត់។

រដ្ឋធម្មនុញ្ញសរសេរ ភាសាបារាំងហៅថា Constitution écrite ឯរដ្ឋធម្មនុញ្ញប្រពៃណីភាសាបារាំងហៅថា Constitution contumiére ដែលយើងមិនត្រូវច្រឡំជាមួយ Constitution's Custom ទេ។ ពាក្យនេះ អាចបកថា ទំនៀមទំលាប់ ចារិករដ្ឋធម្មនុញ្ញ ដែលកើតឡើងត្រួតលើរដ្ឋធម្មនុញ្ញសរសេរដែលកំពុងអនុវត្ត។ ហេតុអ្វី? ព្រោះថា ទោះជាអ្នកតែងសេចក្តី ខិតខំប្រិតព្រៀងយ៉ាងហ្មត់ចត់ក៏ដោយ ក៏រដ្ឋធម្មនុញ្ញសរសេរនៅតែខ្វះចន្លោះ ដូច្នេះចង់មិនចង់ទំនៀមទំលាប់ត្រូវតែផុសឡើង ដើម្បីបំពេញបន្ថែមរដ្ឋធម្មនុញ្ញដែលខ្វះខាត។ ជាទូទៅ ទាំងថ្នាក់ដឹកនាំគ្រប់មជ្ឈដ្ឋានទាំងអ្នកវិភាគច្បាប់ គេទទួលស្គាល់ថា ទំនៀមទំលាប់បន្ថែមលើរដ្ឋធម្មនុញ្ញសរសេរ ជាករណីជៀសមិនផុត តែបញ្ហានៅត្រង់ថា មានទំនៀមទំលាប់ខ្លះវាបញ្ច្រាសនឹងពាក្យពេចន៍ នៃបទបញ្ញត្តិរបស់រដ្ឋធម្មនុញ្ញ។ តើករណីនេះ ត្រូវចាត់ថា ជាការរំលោភបំពានរដ្ឋធម្មនុញ្ញ ឬជាទំនៀមទំលាប់មកធ្វើវិសោធនកម្មដោយប្រយោល?។ មតិអ្នកវិភាគច្បាប់មិនស្របគ្នាលើករណីនេះទេ តែចង់មិនចង់នៅក្នុងរដ្ឋជាច្រើន ទំនៀមទំលាប់ដែលផ្ទុយនឹងអ្វីដែលរដ្ឋធម្មនុញ្ញបានចែងតែងតែកើតជាញឹកញយ លុបបំបាត់បទបញ្ញត្តិខ្លះនៃរដ្ឋធម្មនុញ្ញដោយស្ងៀមស្ងាត់។

## ៥.ពេលរដ្ឋត្រូវការរដ្ឋធម្មនុញ្ញថ្មី

ជាធម្មតារដ្ឋត្រូវការ **រដ្ឋធម្មនុញ្ញថ្មី** ក្នុងករណីដូចខាងក្រោម៖

**•ខណៈដែលរដ្ឋថ្មីមួយកើតឡើង**

រដ្ឋថ្មីមួយកើតឡើងត្រូវការរដ្ឋធម្មនុញ្ញមួយ ដើម្បីបង្ហាញអោយគេដឹងថា រដ្ឋថ្មីនេះមានអំណាចគ្រប់គ្រងច្បាស់លាស់ មានធាតុផ្សំជារដ្ឋពេញលក្ខណៈច្បាប់ មានស្ថាប័ននយោបាយអ្វីខ្លះ? ដែលអាចប្រាស្រ័យទាក់ទងជាទូទៅបាន។

**•ខណៈរបបមួយត្រូវបានដួលរលំតាមរយៈការឈ្នះសង្គ្រាម ឬការធ្វើបដិវត្តន៍ ឬការសម្រេចបានរដ្ឋប្រហារ**

មូលហេតុមកពីគេមិនពេញចិត្តនឹងរបបចាស់ ដែលមានរដ្ឋធម្មនុញ្ញជាច្បាប់កំពូលមិនផ្តល់ផលប្រយោជន៍ដល់ក្រុមរបស់គេ ឬរដ្ឋធម្មនុញ្ញមិនបម្រើផលប្រយោជន៍ទូទៅ។

-អ្វីទៅហៅថា **រដ្ឋប្រហារ**? រដ្ឋប្រហារគឺ ជាការដណ្តើមអំណាចដោយប្តូររដ្ឋធម្មនុញ្ញ ដោយសន្តិវិធីក៏បានដែរ ដោយការបង្ហូរឈាម(ការប្រើកំម្លាំងយោធា)ក៏បានដែរ។ ប៉ុន្តែនាសម័យទំនើបអ្វីដែលហៅថា រដ្ឋប្រហារនោះមិនចាំបាច់ជាថ្វីដៃនៃពួកយោធាទើបហៅថារដ្ឋប្រហារទេ ជួនកាលអ្នកដឹកនាំធ្វើរដ្ឋប្រហារខ្លួនឯងក៏មាន ដើម្បីបន្តការដឹកនាំក្នុងករណី ដែលរដ្ឋធម្មនុញ្ញមិនអនុញ្ញាតអោយបន្តកាន់(ឧ. ប្រធានាធិបតី ម៉ាកូស Marcos នៅប្រទេសហ្វីលីពីន ឬលោក Park Chung Hee នៅកូរ៉េខាងត្បូង) ឬដើម្បីកំចាត់បក្សប្រឆាំង ពេលដែលថ្នាក់ដឹកនាំនេះយល់ឃើញថា ខ្លួនមុខជាចាញ់ឆ្នោតបក្សប្រឆាំងអាណត្តិបោះឆ្នោតខាងមុខ គេក៏រៀបចំធ្វើរដ្ឋប្រហារ (ឧ. នៅអាហ្វ្រិក)។

**•ករណីជួបប្រទះភាពទាល់ច្រក**

ភាពទាល់ច្រកដែលខ្លឹមសារនៃរដ្ឋធម្មនុញ្ញដោះស្រាយបញ្ហាអាយុជីវិតជាតិលែងរួច បណ្តាលមកពីរបបនោះអស់មានប្រសិទ្ធភាពដើម្បីដោះស្រាយ ហើយយល់ថាគ្មានជម្រើសក្រៅពីជំនួសដោយរបបថ្មី។

ឧទាហរណ៍ៈ ឆ្នាំ១៩៥៨ ពេលដែលបារាំង កំពុងចាញ់សង្គ្រាមនៅអាល់ហ្សេរី(Algeria) ក្រោយដែលបានចាញ់នៅវៀតណាម សភាបារាំងបានសម្រេចរំលាយខ្លួនចោល ដោយលុបរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៦ចោល ដើម្បីអញ្ជើញលោកឧត្តមសេនីយ៍ Charles De Gaulle អោយមកកាន់អំណាច។ បន្ទាប់មកទើបគេតាក់តែងថ្មីឆ្នាំ១៩៥៨។

យោងតាមព្រឹត្តការណ៍ដូចដែលរៀបរាប់ខាងលើ គេអាចយល់បានថា បណ្តាប្រទេសជាច្រើនដូចជា កម្ពុជា ថៃឡង់ដ៏ បារាំង ដែលបានឆ្លងកាត់រដ្ឋប្រហារ បដិវត្តលើបដិវត្តន៍ជាញឹកញាប់ ក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន បានស្គាល់រសជាតិនៃរដ្ឋធម្មនុញ្ញរាប់មិនអស់។ រដ្ឋធម្មនុញ្ញនីមួយៗប្រើការបានត្រឹមតែរយៈពេលយ៉ាងខ្លីបំផុត ជាធម្មតាការតាក់តែងរដ្ឋធម្មនុញ្ញគេធ្វើសម្រាប់រយៈពេលវែង(ពី២០ឆ្នាំទៅ៤០ឆ្នាំ) សភាធម្មនុញ្ញដែលមានតួនាទីចែងខ្លឹមសារក្នុងច្បាប់កំពូលនេះតែងតែយល់អោយបានស៊ីជម្រៅ ទាំងកត្តាភូមិសាស្ត្រ ទំនៀមទំលាប់ ប្រពៃណី ចរិតលក្ខណៈច្បាប់ធម្មជាតិ... និងជាពិសេសដំណើរវិវត្តនយោបាយ និងចលនាសង្គមក្នុងរយៈពេលវែង ដោយឈរលើមូលដ្ឋានវិទ្យាសាស្ត្រជាត្រីវិស័យ។ យ៉ាងណាមិញ បើយើងពិនិត្យមើលរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិកដែលជារដ្ឋធម្មនុញ្ញសរសេរ និងរដ្ឋធម្មនុញ្ញប្រពៃណីនៃប្រទេសអង់គ្លេសមានអាយុរាប់សតវត្សមកហើយៗ បានរស់រានមានជីវិតរហូតដល់សព្វថ្ងៃ។[៣]

[៣] ថោង ស៊ីម នីតិរដ្ឋធម្មនុញ្ញៈ បណ្ឌិត្យសភានគរបាលកម្ពុជា,ឆ្នាំ២០១១,ទំព័រទី២១

## ៦.ឧម្រង់នៃបង្កើតរដ្ឋធម្មនុញ្ញ

អំណាចបង្កើតរដ្ឋធម្មនុញ្ញដើម គឺជាអំណាចក្នុងការបង្កើតនូវអត្ថបទរដ្ឋធម្មនុញ្ញដែលឈរលើមូលដ្ឋាន សណ្តាប់ធ្នាប់គតិយុត្តិថ្មី ពីព្រោះសណ្តាប់ធ្នាប់គតិយុត្តិមុនត្រូវបាត់បង់ ឬក្លាយទៅជាមោឃៈ និង ដែលគេជួបប្រទះនូវភាពគ្មានច្បាប់។

ការបង្កើតរដ្ឋធម្មនុញ្ញដើមនេះ អាចធ្វើឡើងទៅតាមកាលៈទេសៈផ្សេងៗពីគ្នា គឺ:

- នៅពេលរដ្ឋថ្មីទើបនឹងកើត
- នៅក្រោយបដិវត្ត(ដែលបានបំផ្លិចបំផ្លាញនូវសណ្តាប់ធ្នាប់រដ្ឋធម្មនុញ្ញ)
- នៅពេលដែលសង្គមជាតិមួយបានឯករាជ្យភាព រួបរួមគ្នាឡើងវិញ

ការបង្កើតរដ្ឋធម្មនុញ្ញនេះ ត្រូវស្ថិតនៅលើស្ថាប័នដែលកាន់អំណាចបង្កើតរដ្ឋធម្មនុញ្ញដើម។ តាមគតិវិជ្ជាប្រជាធិបតេយ្យ អំណាចបង្កើតរដ្ឋធម្មនុញ្ញដើម ជាអំណាចរបស់ប្រជាពលរដ្ឋ។

បញ្ហាសំខាន់មិនមែនស្ថិតនៅលើការដែលដឹងថា អ្នកណាជាម្ចាស់អំណាចនេះច្រើនជាងការដែលដឹងថា អ្នកណាជាអ្នកអនុវត្តអំណាចនេះនោះទេ។

រដ្ឋធម្មនុញ្ញដើមបង្កើតដោយៈ

- ប្រជាមតិ
- សភាធម្មនុញ្ញ(ឈរលើគោលការណ៍ ២ភាគ៣)

ករណីដូចជា រដ្ឋធម្មនុញ្ញកម្ពុជាអនុម័តដោយសភាធម្មនុញ្ញ ដោយមតិភាគច្រើនពីរភាគបី។

ភារកិច្ចរបស់សភាធម្មនុញ្ញគឺ រៀបចំសេចក្តីព្រមព្រៀងរដ្ឋធម្មនុញ្ញ អនុម័តរដ្ឋធម្មនុញ្ញ ហើយក្លាយជាសភានីតិបញ្ញត្តិ(ក្រោយពេលរដ្ឋធម្មនុញ្ញនេះចូលជាធរមាន សភាធម្មនុញ្ញត្រូវក្លាយជារដ្ឋធម្មនុញ្ញ)។

"មាត្រា១៥៤ ថ្មី.-(១៣៥ចាស់)" នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាចែងថាៈ រដ្ឋធម្មនុញ្ញនេះក្រោយពីបានទទួលការអនុម័តត្រូវបានប្រកាសឱ្យចូលជាធរមានភ្លាម ដោយព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា។ រដ្ឋធម្មនុញ្ញនេះ ក្រោយពីបានទទួលការអនុម័តត្រូវបានប្រកាសឱ្យចូលជាធរមានភ្លាមដោយ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា។

"មាត្រា១៥៥ ថ្មី.-(មាត្រា ១៣៦ ចាស់)"នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាចែងថាៈ "ក្រោយពេលរដ្ឋធម្មនុញ្ញនេះចូលជាធរមាន សភាធម្មនុញ្ញត្រូវក្លាយទៅជារដ្ឋសភា។ បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា ត្រូវចូលជាធរមានក្រោយទទួលបានការអនុម័តពីរដ្ឋសភា។ ក្នុងករណី ដែលរដ្ឋសភាមិនទាន់ចាប់ដំណើរការបាន ប្រធាន អនុប្រធានទីមួយ និងអនុប្រធានទីពីរនៃសភាធម្មនុញ្ញ នឹងចូលរួមបំពេញភារកិច្ច ក្នុងក្រុមប្រឹក្សារាជសម្បត្តិបើសភាពការណ៍ក្នុងប្រទេសទាមទារ។"[៤]

## ៧.នីតិវិធីសម្រាប់បង្កើតរដ្ឋធម្មនុញ្ញថ្មី

ដើម្បីតាក់តែងរដ្ឋធម្មនុញ្ញថ្មី គេប្រើនីតិវិធីមានលក្ខណៈខុសៗគ្នាទៅតាមករណីជាក់ស្តែងៈ

- **បើក្នុងរដ្ឋនោះ ព្រះមហាក្សត្រជាម្ចាស់អធិបតេយ្យ** ដូចសម័យសង្គមរាស្ត្រនិយម គឺព្រះមហាក្សត្រជាអ្នកប្រទាននូវរដ្ឋធម្មនុញ្ញ(Octrol) ដល់ពលរដ្ឋរបស់ព្រះអង្គតាមព្រះរាជហរទ័យរបស់ព្រះអង្គតែម្នាក់គត់។

[៤] អត្ថបទមេរៀនសាស្ត្រាចារ្យ ជុំ អ៊ីម នៃសាកលវិ.ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

នេះបើតាមខ្លឹមសាររដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ ដែលព្រះមហាក្សត្រ នរោត្តម សីហនុ ប្រទានដល់ពលរដ្ឋខ្មែរលើកទី១។

- បើក្នុងរបបនយោបាយមាន ព្រះមហាក្សត្រផង និងពលរដ្ឋផង នោះមានន័យថា របបនោះជាសហម្ចាស់អធិបតេយ្យនៃរដ្ឋធម្មនុញ្ញ។ ដូច្នេះការតាក់តែងរដ្ឋធម្មនុញ្ញត្រូវមាន ការឯកភាពរវាងម្ចាស់អធិបតេយ្យទាំងសងខាង(Parties)។ នេះជាស្ថានភាពនយោបាយនៃប្រទេសនេប៉ាល់សព្វថ្ងៃ ដែលព្រះមហាក្សត្រត្រូវបានទទួលសំពាធស្ម័គ្រចិត្តយករដ្ឋធម្មនុញ្ញមួយថ្មី ប្តូរពីរាជានិយមអំណាចផ្តាច់មុខ មកជារាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ។
- បើនៅក្នុងនោះពលរដ្ឋជាម្ចាស់អធិបតេយ្យ(របបប្រជាធិបតេយ្យ) ពលរដ្ឋនោះឯងជាអ្នកសម្រេចលើរដ្ឋធម្មនុញ្ញថ្មី(La Constitution, oeuvre du peuple souverain)។

<u>សម្គាល់</u>

អ្នកមានអំណាចបង្កើតរដ្ឋធម្មនុញ្ញថ្មី ត្រូវគេអោយឈ្មោះថា Pouvoir Constituant originaire ប្រែថា **អំណាចធ្វើរដ្ឋធម្មនុញ្ញដើមខ្សែ** ។

ចំពោះកម្ពុជា រដ្ឋសភាដែលចេញពីការបោះឆ្នោតឆ្នាំ១៩៩៣ ជាសភាធម្មនុញ្ញ (Constituent Assembly) ផ្អែកលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស មានន័យថា ពលរដ្ឋខ្មែរដែលជាម្ចាស់អធិបតេយ្យនៃកម្ពុជា បានប្រគល់ Pouvoir Constituant Originaire មកជូនសភាធម្មនុញ្ញក្នុងការតាក់តែងរដ្ឋធម្មនុញ្ញផ្តាច់មុខ។ ក្រោយពីការអនុម័តរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ រួចសភាធម្មនុញ្ញនេះ បានក្លាយខ្លួនមកជាសភា(សាមញ្ញ) (Legistative Assembly) ដែលមានអំណាចត្រឹមអនុម័តលើសេចក្តីព្រៀងច្បាប់ និងធ្វើសេចក្តីស្នើច្បាប់ធម្មតា(ព្រះរាជក្រម) ព្រះអង្គលែងមានអំណាចតាក់តែងរដ្ឋធម្មនុញ្ញថ្មីបានទៀតឡើយ។ ព្រោះលែងមានអំណាច Pouvoir Constituant Originaire ហើយ **អំណាចធ្វើរដ្ឋធម្មនុញ្ញដើមខ្សែនេះ** វិលទៅពលរដ្ឋវិញ ព្រោះពលរដ្ឋជាម្ចាស់។

បច្ចេកទេសនៃការបង្កើតរដ្ឋធម្មនុញ្ញថ្មីត្រូវការឆ្លងកាត់ពីដំណាក់កាលគឺៈ

ដំណាក់កាលធ្វើសេចក្តីព្រៀងរដ្ឋធម្មនុញ្ញ និងដំណាក់កាលអនុម័តសេចក្តីព្រៀងរដ្ឋធម្មនុញ្ញស្ថាពរ។

•**ដំណាក់កាលទី១**: ចំពោះច្បាប់មិនចោទជាបញ្ហាទេ ព្រោះការធ្វើសេចក្តីរួច ត្រូវដាក់ឆ្លងអំណាចរដ្ឋធម្មនុញ្ញដើមខ្សែ(Pouvoir Constituant Originaire) ដែលមានតួនាទីផ្តាច់មុខទទួលយក ឬទាត់ចោលបាន បើយល់ឃើញថាមិនពេញចិត្ត អាចបង្គាប់អោយតាក់តែងជាថ្មីនូវសេចក្តីព្រៀងនោះឡើងវិញ។ កន្លងមកពិភពលោកគេធ្លាប់ពើបប្រទះករណីរបៀបនេះម្តងម្កាលដែរ។ ប៉ុន្តែករណីបែបនេះកម្ររកើតមានណាស់ ព្រោះថាពលរដ្ឋដែលគេហៅមកបោះឆ្នោតធ្វើប្រជាមតិភាគច្រើនគាត់ពុំសូវយល់ស៊ីជម្រៅអំពីខ្លឹមសារនៃសេចក្តីព្រៀងរដ្ឋធម្មនុញ្ញ ដែលបានដាក់អោយអនុម័តនោះទេ គឺមានន័យថាគាត់ចេះតែបោះឆ្នោតតាមការឃោសនារបស់ថ្នាក់ដឹកនាំ ដែលមានគំនិតផ្តួចផ្តើមប្រឌិតរដ្ឋធម្មនុញ្ញស្របតាមគំនិតគេចង់បាន។ ជាទូទៅនៅប្រទេសកាន់លទ្ធិប្រជាធិបតេយ្យគេតែងអនុញ្ញាតអោយគណបក្ស ឬក្រុមបញ្ញវ័ន្តណា ដែលមិនពេញចិត្តនឹងសេចក្តីព្រៀងធ្វើការឃោសនាប្រឆាំងសេរី។ តែទោះយ៉ាងណាក៏ដោយប្រជាមតិអាចត្រឹមបោះឆ្នោតយល់ព្រម ឬមិនយល់ព្រមប៉ុណ្ណោះ។ គេមិនអាចសុំកែលើចំណុចអ្វីមួយដែលពលរដ្ឋមិនសូវពេញចិត្តបានទេ។

សរុបសេចក្តីទៅ សេចក្តីព្រៀងរដ្ឋធម្មនុញ្ញមានសារៈសំខាន់ណាស់ ហាក់បីដូចជាសម្លដែលគេបានស្លរួចហើយ ចំណែកឯពលរដ្ឋគ្រាន់តែ បរិភោគ ឬមិនបរិភោគនោះក៏មិនអាចថែមថយគ្រឿងតាមអំពើចិត្តបានទេ។

ល្គឹកណាមានការប្រគល់សិទ្ធិតាក់តែងដល់សភាធម្មនុញ្ញមួយ ដែលត្រូវបានរដ្ឋបាលជ្រើសរើសមានអ្នកឯកទេសច្បាស់លាស់ នោះធម្មានុរូប(Legitimate) វានឹងមានប្រសិទ្ធិភាពខ្ពស់។ ប៉ុន្តែបើក្នុងសមាសភាពសភា

ធម្មនុញ្ញនោះ មិនសូវមានអ្នកជំនាញផ្នែកច្បាប់ ដែលមានសមត្ថភាពបច្ចេកទេសក្នុងវិស័យនេះគ្រប់គ្រាន់ទេនោះ ការតាក់តែងនេះ មិនបានល្អប្រសើរស្របតាមអ្វីដែលប្រជាពលរដ្ឋចង់បាននោះទេ។

ដូច្នេះគេត្រូវថ្លឹងថ្លែងយ៉ាងណា ដើម្បីអោយគណៈកម្មការតែងសេចក្ដីមានធម្មានុរូប (Legitimate) ផង និងមានជំនាញខាងផ្លូវច្បាប់ផង។ ចំពោះការស្វែងរកតុល្យភាពរវាងចំណុចទាំងពីរនេះ វាមិនមែនជាការងាយស្រួលប៉ុន្មានទេ ព្រោះពលរដ្ឋមិនសូវបោះឆ្នោតអោយអ្នកចេះទេ ច្រើនបោះឆ្នោតយកអ្នកប្រសប់វោហារសាស្ត្រ។

•**ដំណាក់កាលទី២**: ជាដំណាក់កាលអនុម័តសេចក្ដីព្រៀងរដ្ឋធម្មនុញ្ញ ដោយពលរដ្ឋដែលជាម្ចាស់អធិបតេយ្យ តាមរយៈការធ្វើប្រជាមតិ ឬតាមការអនុម័តដោយសភាធម្មនុញ្ញ ដែលពលរដ្ឋបានជ្រើសរើសជាពិសេសសម្រាប់ការអនុម័តនៃសេចក្ដីព្រៀងនេះ តាមរយៈការធ្វើប្រតិភូកម្មអំណាចជូនអំណាចរដ្ឋធម្មនុញ្ញដើម្បីខ្សែប្រគល់ដល់សភាធម្មនុញ្ញ។

បើការអនុម័តធ្វើឡើងតាមរយៈប្រជាមតិនោះ ពលរដ្ឋគ្មានសមត្ថភាព និងលទ្ធភាពកែប្រែខ្លឹមសារអ្វីបានទេ មានតែអនុម័តយក ឬច្រានចោលប៉ុណ្ណោះ។ ជាធម្មតាបើប្រជាពលរដ្ឋច្រានចោល គេនឹងតាក់តែងសេចក្ដីព្រៀងមួយទៀត ដែលធ្វើឡើយដោយគណៈកម្មការដដែល ឬគណៈកម្មការមួយផ្សេងក៏បាន បន្ទាប់មកគេដាក់ធ្វើប្រជាមតិមួយទៀត រហូតដល់សម្រេចបានរដ្ឋធម្មនុញ្ញថ្មីមួយ។ ជាទូទៅ បើសភាធម្មនុញ្ញជាអ្នកអនុម័តលើសេចក្ដីព្រៀងរដ្ឋធម្មនុញ្ញ នោះសភានេះអាចកែច្នៃតាមការចង់បានមុននឹងអនុម័តជាស្ថាពរ។[៥]

## ៨.ខ្លឹមសារសំខាន់ៗចែងត្រូវក្នុងរដ្ឋធម្មនុញ្ញ

ជាទូទៅកម្មវត្ថុនៃរដ្ឋធម្មនុញ្ញ គឺចែងអំពីស្ថាប័នកំពូលៗ ហើយស្ថាប័នទាំងនោះមានៈ

ស្ថាប័ននយោបាយ និងមុខនាទីនៃស្ថាប័ននោះ ហើយស្ថាប័ននេះមានតួនាទីក្នុងការដឹកនាំរដ្ឋគេមិនចែងកិច្ចការប្រចាំថ្ងៃ **ដូចជាកិច្ចការរដ្ឋបាល** នោះទេ។ ប៉ុន្តែគេមិនអាចកាត់ផ្ដាច់រវាងអ្វី ដែលជានយោបាយ និងអ្វីដែលជារដ្ឋបាលបានទេ។

**ឧទាហរណ៍**: ការរៀបចំការបោះឆ្នោត និងការគ្រប់គ្រងការបោះឆ្នោតនៅតាមបណ្ដាប្រទេសជឿនលឿន គេចាត់ទុកថាវាជារឿងសាមញ្ញ លែងជាបញ្ហាស្មុគស្មាញនៃជម្លោះរវាងគណបក្ស និងគណបក្សទៀតហើយ។ ការបោះឆ្នោត ត្រូវបានគេចាត់ទុកជាកិច្ចការរដ្ឋបាលធម្មតា។

ដូច្នេះគេមិនចាំបាច់ចែងអំពីស្ថាប័ន ដែលមានធម្មានុរូបទទួលខុសត្រូវក្នុងការរៀបចំ ការគ្រប់គ្រងការបោះឆ្នោតក្នុងរដ្ឋធម្មនុញ្ញទៀតទេ។ ដោយឡែកនៅកម្ពុជាយើង ភារកិច្ចនេះត្រូវផ្ដល់ធម្មានុរូបដល់គណកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលដើរតួនាទីសំខាន់បំផុត ដើម្បីប្រតិបត្តិការ និងដោះស្រាយវិវាទបោះឆ្នោត។ ក្នុងបរិបទនេះគួរតែចែងក្នុងរដ្ឋធម្មនុញ្ញ ដើម្បីកុំអោយគណបក្សនាំមុខណាមួយអាចឆ្លៀតឱកាសប្ដូរនីតិវិធីបានដោយងាយស្រួលមុនពេលបោះឆ្នោតម្ដងៗ។

ជាមួយនឹងស្ថាប័ននយោបាយ រដ្ឋធម្មនុញ្ញសម័យនេះ តែងមានចែងអំពីសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋជាពិសេសចាប់តាំងពីរបបកុម្មុយនីស្តឡើងកាន់អំណាច ដូចជា នៅសហភាពសូវៀត បណ្ដាប្រទេសកុម្មុយនីស្តនៃអឺរ៉ុបខាងកើត គេតែងសរសេរក្នុងរដ្ឋធម្មនុញ្ញខ្លួនច្រើនរយមាត្រា **ស្ដីពីសិទ្ធិសេរីភាព** ក្នុងរដ្ឋធម្មនុញ្ញដែលគេហៅថា ***វណ្ណៈអធន*** នោះ។ រដ្ឋធម្មនុញ្ញទាំងអស់នេះ មិនត្រឹមតែរៀបរាប់អំពីបណ្ដាសិទ្ធិសេរីភាពរបស់ពលរដ្ឋ ដូចជា

[៥] ថោង ស៊ីម នីតិរដ្ឋធម្មនុញ្ញៈ បណ្ឌិត្យសភានគរបាលកម្ពុជា,ឆ្នាំ២០១១,ទំព័រទី២៤

ប្រទេសសេរីនិយមទេ គេតែងសេចក្តីជាហូរហែរអំពីមធ្យោបាយ ដែលរដ្ឋត្រូវអនុវត្តដើម្បីអោយសម្រេចបានជាក់ស្តែង។

**ឧទាហរណ៍:** រដ្ឋធម្មនុញ្ញ មិនត្រឹមតែនិយាយថា ពលរដ្ឋម្នាក់មានសិទ្ធិទទួលការរៀនសូត្រ តែចែងថា រដ្ឋត្រូវសាងសង់សាលារៀន ការផ្តល់សម្ភារៈសិក្សា ផ្តល់អាហាររូបករណ៍។ល។ សិទ្ធិកំសាន្ត ត្រូវបញ្ជាក់ពីមធ្យោបាយ ដើម្បីអោយពលរដ្ឋទទួលបានការកំសាន្ត មិននិយាយតែមាត់ទទេ។ល។ ប៉ុន្តែការទទួលបន្ទុកច្រើនយ៉ាងបែបនេះ បណ្តាលអោយរដ្ឋអនុវត្តមិនបានតាមអ្វីដែលបានចែង ហើយរដ្ឋធម្មនុញ្ញត្រូវក្លាយជាអត្ថបទដែលគ្មានន័យអ្វីទាំងអស់។ ទីបំផុតប្រទេសកុម្មុយនីស្តទាំងនោះត្រូវរលំរលាយប្រហែល ៥០ឆ្នាំក្រោយមក។

ដូច្នេះសារសំខាន់ វាមិនមែនស្ថិតនៅត្រង់ចែង ឬមិនចែងលំអិតអំពីសិទ្ធិសេរីភាពក្នុងរដ្ឋធម្មនុញ្ញនោះទេ កត្តាចាំបាច់ គឺសំខាន់លើឆន្ទៈនយោបាយរបស់អ្នកដឹកនាំប្តេជ្ញាថា ខ្លួនពិតជាធានាសិទ្ធិសេរីភាពនៃពលរដ្ឋខ្លួនបែបណា។[៦]

## ៩.ឧត្តមភាពនៃរដ្ឋធម្មនុញ្ញ

យោងទៅលើកិច្ចព្រមព្រៀងក្រុងប៉ារីស ស្តីពីការដោះស្រាយវិវាទកម្ពុជាតាមផ្លូវនយោបាយបានចែងថា រដ្ឋធម្មនុញ្ញជាច្បាប់កំពូល។ ប្រយោគនេះ មានន័យថា រដ្ឋនីមួយៗមានបទដ្ឋានច្បាប់ច្រើនប្រភេទដូចជា ព្រះរាជក្រម ក្រឹត្យច្បាប់ និងលិខិតបទដ្ឋានក្រោមច្បាប់ផ្សេងទៀតមាន: អនុក្រឹត្យ ប្រកាស សេចក្តីសម្រេច ដីកា...។ ដែលជាវិធានតម្រូវអោយមានការគោរពប្រតិបត្តិតាមច្បាប់គ្រប់ៗគ្នា(ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់)។ សូមបញ្ជាក់ថា រាល់បណ្តា ច្បាប់ លិខិតបទដ្ឋានទាំងនោះ មានឋានុក្រមរបស់វា ដែលតម្រូវអោយបទដ្ឋានថ្នាក់ក្រោមគោរពបទដ្ឋានថ្នាក់លើជានិច្ច។ ឋានានុក្រមនៃបទដ្ឋានទាំងនោះ មានតែរដ្ឋធម្មនុញ្ញទេដែលស្ថិតនៅថ្នាក់កំពូល គេនិយាយម្យ៉ាងទៀតថា រដ្ឋធម្មនុញ្ញ មានឧត្តមភាពលើបទដ្ឋាននានាទាំងអស់។[៧]

## ១០.ករណីការសិក្សារដ្ឋធម្មនុញ្ញ បណ្តាប្រទេសនីមួយៗ

### ១០.១.រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

ក្រោយពេលដែលទទួលបានជ័យជំនះនៅក្នុងការបោះឆ្នោតថ្ងៃទី២៣-២៨ ខែឧសភា ឆ្នាំ១៩៩៣ គណបក្សនយោបាយចំនួន៤ គឺគណបក្សហ៊្វុន ស៊ិនប៉ិច គណបក្សប្រជាជនកម្ពុជា គណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា គណបក្សម៉ូលីណាការ បានប្រមូលផ្តុំគ្នាបើសម័យប្រជុំសភាធម្មនុញ្ញជាលើកដំបូងនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៩៣ ក្រោមព្រះរាជអធិបតីភាពសម្តេចនរោត្តម សីហនុ និងលោក Yasushu Akashi ដែលជាអ្នកទទួលខុសត្រូវរបស់អង្គការសហប្រជាជាតិនៅក្នុងប្រទេសកម្ពុជា។ វត្តមាននៃលោក Akashi ក្នុងពេលនោះជាសញ្ញានៃការផ្ទេរសិទ្ធិ ក្នុងការគ្រប់គ្រងប្រទេសពេញលេញទាំងមូលអោយខ្មែរ ក្នុងឋានៈជាម្ចាស់ប្រទេសលើគ្រប់វិស័យ។

សភាធម្មនុញ្ញមានបេសកកម្មត្រូវតាក់តែងរដ្ឋធម្មនុញ្ញមួយអោយហើយក្នុងរយៈពេល ៣ខែ ដើម្បីអោយស្របទៅតាមកិច្ចព្រមព្រៀងទីក្រុងប៉ារីស។ សភាធម្មនុញ្ញដែលមានលោក សឺន សាន ជាប្រធាន លោកជា ស៊ីម ជាអនុប្រធាន បានរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន និងធ្វើការតែងតាំងគណៈកម្មាធិការអចិន្ត្រៃយ៍មួយ ដើម្បីរៀបចំតែងតាំងគម្រោងរដ្ឋធម្មនុញ្ញ។ គម្រោងរដ្ឋធម្មនុញ្ញមួយត្រូវបានរៀបចំឡើងដែលមានលក្ខណៈរាជានិយម

[៦] ចោង ស៊ីម នីតិរដ្ឋធម្មនុញ្ញ: បណ្ឌិត្យសភានគរបាលកម្ពុជា,ឆ្នាំ២០១១,ទំព័រទី២៨

[៧] ចោង ស៊ីម នីតិរដ្ឋធម្មនុញ្ញ: បណ្ឌិត្យសភានគរបាលកម្ពុជា,ឆ្នាំ២០១១,ទំព័រទី២៨

ពាក់កណ្តាល និងសាធារណរដ្ឋពាក់កណ្តាល។ ដោយសារមានជំហរពីរមិនទាន់ដាច់ស្រាច របស់សម្តេច នរោត្តម សីហនុ ដែលប្រកាន់យកជំហរកណ្តាល គឺមិនមែនជាសាធារណរដ្ឋ ហើយក៏មិនមែនជារាជានិយមដែរ។ ដោយយកតាមលំនាំរដ្ឋធម្មនុញ្ញឆ្នាំ១៩៦០ ដែលប្រកាន់យករបបរាជានិយមដដែល តែគ្មានព្រះមហាក្សត្រគ្រងរាជ្យ គឺមានតែប្រមុខរដ្ឋជាអ្នកកាន់អំណាចនីតិប្រតិបត្តិ ហើយគ្រប់គ្រងប្រទេសជាមួយរដ្ឋាភិបាល។

នៅដំណាច់ខែសីហា ឆ្នាំ១៩៩៣ គណៈប្រតិភូរបស់រដ្ឋសភា បានអញ្ជើញទៅទីក្រុងព្យុងយ៉ាង នៃសាធារណរដ្ឋប្រជាមានិតកូរ៉េ ដើម្បីសុំព្រះរាជយោបល់ ពីសម្តេច នរោត្តម សីហនុ ហើយព្រះអង្គក៏ទ្រង់សព្វព្រះរាជហឫទ័យយករូបមន្ត របបរាជានិយម អាស្រ័យរដ្ឋធម្មនុញ្ញ។

ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ សេចក្តីព្រាងរបស់គណៈកម្មាធិការរៀបចំរដ្ឋធម្មនុញ្ញបានត្រូវសភាធម្មនុញ្ញអនុម័ត ដោយមាន១១៣សំឡេង គាំទ្រ៥សំឡេងជំទាស់ និង ២សំឡេងអនុប្បវាទ។ ក្រោយការអនុម័តរដ្ឋធម្មនុញ្ញហើយ រដ្ឋធម្មនុញ្ញនេះ ក៏ត្រូវបានប្រកាសអោយប្រើជាផ្លូវការ ដោយសម្តេច ព្រះប្រមុខរដ្ឋ នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ គឺនៅរយៈពេល៤ខែ បន្ទាប់ពីថ្ងៃបោះឆ្នោត គឺស្របតាមកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ដែលពុំមានគម្រោងអនុម័តតាមនីតិវិធីប្រជាមតិជាបន្ថែមទៀតឡើយ។

ក្រោយពីការប្រកាសអោយប្រើរដ្ឋធម្មនុញ្ញ សភាធម្មនុញ្ញក៏បានក្លាយទៅជារដ្ឋសភា ចាប់ពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ហើយដែលនឹងត្រូវបង្កើតរដ្ឋាភិបាលកម្ពុជាថ្មីមួយឡើង។[៨]

គួរកត់សម្គាល់ថា ក្នុងការតាក់តែងរដ្ឋធម្មនុញ្ញនេះ សភាធម្មនុញ្ញបានៈ

- ស្រង់ការពិសោធន៍ ពីរដ្ឋធម្មនុញ្ញមុន លើកលែងតែរដ្ឋធម្មនុញ្ញ កម្ពុជាប្រជាធិបតេយ្យ
- ស្រង់មតិពីសេចក្តីណែនាំរបស់អង្គការសហប្រជាជាតិ ក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីស ត្រង់ឧបសម្ព័ន្ធទី៥ នៅចំណុចគោលការណ៍ជាមូលដ្ឋាន ស្តីពីសិទ្ធិមនុស្ស កម្មសិទ្ធិឯកជនការបង្កើតអោយមានតុលាការឯករាជ្យ និងការអនុវត្តន៍ប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស។

រដ្ឋធម្មនុញ្ញខ្មែរសព្វថ្ងៃគឺ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ កែប្រែនៅក្នុងឆ្នាំ១៩៩៤ម្តង និងក្នុងឆ្នាំ១៩៩៩ ម្តងទៀត។ ប្រៀបធៀបទៅនឹងរដ្ឋធម្មនុញ្ញបារាំង រដ្ឋធម្មនុញ្ញខ្មែរក៏មានបុព្វកថាដែរ ប៉ុន្តែពុំមានបង្កប់នូវគោលការណ៍គ្រឹះអ្វីដូចជាបារាំងទេ ហើយអ្វីៗដែលបានរៀបរាប់ក្នុងបុព្វកថានោះ គ្រាន់តែបង្ហាញអំពីឆន្ទៈរបស់ប្រជាពលរដ្ឋខ្មែរ ដែលចង់កសាងប្រទេសខ្លួនឡើងវិញ គឺមិនមែនក្នុងគោលដៅដាក់ជាបទបញ្ញត្តិចូលក្នុងរដ្ឋធម្មនុញ្ញទេ ដូចឃ្លាខាងក្រោមនេះ បានបញ្ជាក់យ៉ាងច្បាស់លាស់។

"ក្នុងឆន្ទៈមោះមុតនេះ យើងសរសេរចារឹក ក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដូចតទៅ ..."។

គោលការណ៍គ្រឹះទាំងអស់ មានចែងក្នុងមាត្រានៃរដ្ឋធម្មនុញ្ញជាបទបញ្ញត្តិ ដែលជាហេតុនាំអោយមានការងាយស្រួលអនុវត្តដោយរដ្ឋធម្មនុញ្ញដូចបារាំងដែរ ប៉ុន្តែក្រុមប្រឹក្សាធម្មនុញ្ញខ្មែរមានសិទ្ធិធំជាងក្រុមប្រឹក្សាធម្មនុញ្ញបារាំង ត្រង់មានសមត្ថកិច្ចត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ទាំងមុខ (a priori) ទាំងក្រោយ(a posteriori) ការប្រកាសអោយប្រើ។ ចំណុចនេះធ្វើអោយច្បាប់ខ្មែរ ដើរលឿនជាងច្បាប់បារាំងមួយកម្រិត ពីព្រោះខាងខ្មែរ គេអាចរំលាយច្បាប់ដែលជាធរមាន ហើយបានក្នុងករណីឃើញមានអធម្មនុញ្ញភាពក្នុងការអនុវត្តន៍។ នៅពេលដែលក្រុមប្រឹក្សាធម្មនុញ្ញ បានសម្រេចរំលាយច្បាប់ដែលខុសនឹងរដ្ឋធម្មនុញ្ញ ហើយកិច្ចរដ្ឋបាលដែលជាកិច្ចអនុវត្តតាមច្បាប់ខុសនោះ ក៏នឹងអាចត្រូវរំលាយតាមក្រោយបានដែរ ដោយចៅក្រមបើមានបណ្តឹង។ ម្យ៉ាងទៀតក្រុមប្រឹក្សាធម្មនុញ្ញខ្មែរក៏មានសមត្ថកិច្ចពិនិត្យអធម្មនុញ្ញភាព នៃកិច្ចរដ្ឋបាលបានដែរ ក្នុងរឿងក្តីនៅតុលាការ ដែលមានភាគីលើកឡើង

[៨] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ មាត្រាទ១៥៥ មាត្រា១៥៧

អំពីធម្មនុញ្ញភាពនៃសេចក្តីសម្រេចរដ្ឋបាលណាមួយ ដែលប៉ះពាល់ដល់សិទ្ធិសេរីភាពជាសារវន្តរបស់គេ ហើយដែលតុលាការកំពូលយល់ព្រមប្តឹងក្រុមប្រឹក្សាធម្មនុញ្ញ។ រឿងដូចគ្នានេះ នៅប្រទេសបារាំងមិនទាន់មានច្បាប់ធ្វើកើតនៅឡើយទេ។ រហូតដល់ទល់នឹងថ្ងៃនេះ ច្បាប់ខ្មែរពុំទាន់មានអ្វីដែលគេហៅថា "**ដុំធម្មនុញ្ញភាព**" ដូចបារាំងនៅឡើយ។ តាមការប្រមើលទៅមុខក៏ប្រហែលជាអត់មានដែរ ពីព្រោះគោលការណ៍ទាំងអស់សុទ្ធតែជាបទបញ្ញត្តិរដ្ឋធម្មនុញ្ញស្រាប់ទៅហើយ គឺនៅក្នុងមាត្រានៃរដ្ឋធម្មនុញ្ញខ្មែរម្តង។

ច្បាប់ និងសេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋ ត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត។ ដូច្នេះ រដ្ឋធម្មនុញ្ញខ្មែរ ក៏ដូចរដ្ឋធម្មនុញ្ញបារាំងដែរ ជាប្រភពដ៏សំខាន់មួយ នៃនីតិរដ្ឋបាលខ្មែរ។[៩]

១០.២.រដ្ឋធម្មនុញ្ញប្រទេសស្វីស(ប្រជាមតិ)

ប្រទេសស្វីស ជាប្រទេសប្រើប្រព័ន្ធ(សហ-សហព័ន្ធ) ប្រើប្រព័ន្ធសភានិយម។ រដ្ឋសភាមានសមាជិក ២០០នាក់ ព្រឹទ្ធសភាមានសមាជិក ៤៦នាក់ មានអាណត្តិ៤ឆ្នាំ បោះឆ្នោតដោយសេរី សកល ចេញពីរដ្ឋក្នុងសហព័ន្ធ។ សភាមានភាពឯករាជ្យ សភាទាំងពីរធ្វើការបោះឆ្នោតជ្រើសរើសសហព័ន្ធ(រដ្ឋាភិបាលសហព័ន្ធ) ដោយសកលដែលមានសមាជិក ៧នាក់ ហើយជ្រើសរើសប្រធានាធិបតី សម្រាប់មួយអាណត្តិរយៈពេលមួយឆ្នាំ។ សភាទាំងពីរបោះឆ្នោតជ្រើសរើស អធិការធិបតី និងអគ្គអធិការធិបតី ដែលមានអាណត្តិ ៦ឆ្នាំ ហើយជ្រើសរើសតុលាការសហព័ន្ធមានរយៈពេល ៦ឆ្នាំ។ ក្រុមប្រឹក្សាសហព័ន្ធ(រដ្ឋាភិបាល) ជានិច្ចកាលមានតំណាងប្រជាជាតិនីមួយៗចូលរួមដូចជា គណៈកម្មការ តំណាងអោយកាតូលិក ២នាក់ និងប្រតេស្តាន់ ៥នាក់។ ក្នុងចំនួន ៧នាក់ មានអ្នកតំណាងអោយអាឡឺម៉ង់ ៤ទៅ៥នាក់ , តំណាងបារាំង ១នាក់ , តំណាងអោយអ៊ីតាលី ១នាក់ ។ ក្នុងរដ្ឋធម្មនុញ្ញសហព័ន្ធស្វីស "សភា" មិនអាចទម្លាក់រាជរដ្ឋាភិបាលបានឡើយ ហើយរដ្ឋាភិបាលក៏មិនអាចរំលាយសភាបានដែរ។ ចេញពីសមាជិករដ្ឋសភា ត្រូវបានជ្រើសរើសអោយចូលទៅស្ថាប័នផ្សេងៗដូចជាតុលាការសហព័ន្ធ អធិការធិបតី រដ្ឋាភិបាលសហព័ន្ធ។ ដោយរដ្ឋាភិបាលពុំបានជ្រើសរើសតាមលក្ខណៈបោះឆ្នោតសកលប្រជាពលរដ្ឋផ្ទាល់ ទើបប្រជាពលរដ្ឋស្វីស អាចមានសកម្មភាពទៅលើរដ្ឋាភិបាលសហព័ន្ធ តាមលក្ខណៈប្រជាមតិ។ តាមច្បាប់ធម្មនុញ្ញសហព័ន្ធស្វីសប្រជាជាតិស្វីសអាចអនុញ្ញាតិអោយធ្វើប្រជាមតិបានលុះត្រាតែ ស្ថិតនៅលើមូលដ្ឋាននៃបរិមាណចំនួនប្រជារាស្ត្រពី៥០០០០(ប្រាំម៉ឺន)ទៅ១០០០០០(មួយសែន)នាក់ឡើងទៅ។ ចំពោះរដ្ឋធម្មនុញ្ញសហព័ន្ធ មានលក្ខណៈគ្រប់គ្រងនិងលក្ខណៈប្រហាក់ប្រហែលរបៀបរបបដឹកនាំប្រទេសដែរ ដែលរដ្ឋាភិបាលក្នុងរដ្ឋសហព័ន្ធទាំងនោះ មានច្បាប់រដ្ឋធម្មនុញ្ញស្វយ័ត។ ប៉ុន្តែស្មារតីធម្មនុញ្ញទាំងនោះ ស្ថិតនៅលើច្បាប់ធម្មនុញ្ញសហព័ន្ធ។ ម្យ៉ាងទៀតស្មារតីរដ្ឋធម្មនុញ្ញស្វីស និងរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា មានខ្លឹមសារស្រដៀងគ្នា ដូចជា ការប្រកាន់របបអព្យាក្រឹត្យ មានចែងក្នុងមាត្រានៃរដ្ឋធម្មនុញ្ញ ពីភាពប្រុងប្រយ័ត្ន ភាពប្រយ័ត្នប្រយែង ការភ័យខ្លាចទុកជាមុន ពីការឈ្លានពានបរទេសផ្សេងៗជាដើម។

ដូច្នេះ អាចសន្និដ្ឋានបានថា ប្រព័ន្ធគ្រប់គ្រង ឬច្បាប់រដ្ឋធម្មនុញ្ញស្វីស មានលក្ខណៈស្មុកស្មាញខ្លាំងរវាងអំណាចកណ្តាល(រដ្ឋភិបាលសហព័ន្ធ) និងអំណាចតាមតំបន់។ ការអនុវត្តន៍ក្នុងជីវភាពនយោបាយ ជាធម្មតាតែងតែជួបប្រទះបញ្ហា និងវិបត្តិជាច្រើនរវាងរដ្ឋាភិបាលសហព័ន្ធ និងរដ្ឋាភិបាលតាមតំបន់ ប៉ុន្តែរដ្ឋាភិបាលនីមួយៗនៅតាមតំបន់បានស្រុះស្រួលគ្នា គោរពនូវគោលការណ៍ "ថ្លុងមួយ"។

[៩] បណ្ឌិតសាយ បូរី នីតិរដ្ឋបាលទូទៅ បោះពុម្ពលើកទី២ឆ្នាំ២០០១,ទំព័រទី៤១

១០.៣.រដ្ឋធម្មនុញ្ញបារាំង

រដ្ឋធម្មនុញ្ញបារាំងសព្វថ្ងៃ គឺជារដ្ឋធម្មនុញ្ញឆ្នាំ១៩៥៨ ដែលប្រជាមតិថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០០០ ទើបនឹងបានកែអាណត្តិប្រធានាធិបតីពី ៧ឆ្នាំ អោយមកនៅត្រឹម ៥ឆ្នាំវិញ។ ច្បាប់កំពូលនេះ ជាប្រភព "ផ្ទាល់ ឬប្រយោល" នៃអំណាច ឬសមត្ថកិច្ចរដ្ឋបាល ហេតុដូច្នេះហើយ ទើបសាស្ត្រាចារ្យ Vedel និយាយថា រដ្ឋធម្មនុញ្ញផ្តល់ "មូលដ្ឋានធម្មនុញ្ញ" (basc constitutionnelle) អោយសមត្ថកិច្ចរដ្ឋបាល។ នៅក្នុងរដ្ឋធម្មនុញ្ញបារាំងនេះ មានគោលការណ៍គ្រឹះ ដែលមានចែងក្នុងបុព្វកថា (Préambule) និងក្នុងបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ។ គោលការណ៍គ្រឹះនេះ មិនអាចអំណាចនីតិប្រតិបត្តិរំលោភបានឡើយ។ ចៅក្រមជាអ្នកការពារមិនអោយអំពើរបស់រដ្ឋការរំលោភបាន ប៉ុន្តែក្នុងករណីដែលកិច្ចរដ្ឋបាល(acte administratif) បានបំពានដោយផ្ទាល់ ដោយខ្លួនឯងដល់រដ្ឋធម្មនុញ្ញប៉ុណ្ណោះ។ ប្រសិនបើជាកិច្ចការរដ្ឋបាល គ្រាន់តែអនុវត្តតាមច្បាប់ដែលរដ្ឋសភាបានអនុម័តដោយខុសនឹងរដ្ឋធម្មនុញ្ញនោះ ចៅក្រមមិនអាចរំលាយកិច្ចរដ្ឋបាលនោះបានទេ។ ពីព្រោះរដ្ឋធម្មនុញ្ញឆ្នាំ១៩៥៨ បានប្រគល់អំណាចត្រួតពិនិត្យធម្មនុញ្ញភាព(contrÔle de la constitutiionnalité)នៃច្បាប់ អោយទៅ"ក្រុមប្រឹក្សាធម្មនុញ្ញ" (Conseil constitutionnel) តែមួយគត់។ តាមច្បាប់បារាំង ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់បាន តែមុខច្បាប់នោះត្រូវប្រកាសប្រើ។ ដូច្នេះ បើមានការលើកឡើងអំពីអធម្មនុញ្ញភាព(inconstitutionnalité)នៃច្បាប់ ក្រោយដែលច្បាប់នេះត្រូវបានប្រកាសអោយប្រើរួចហើយ ក្រុមប្រឹក្សាធម្មនុញ្ញមិនអាចត្រួតពិនិត្យបានឡើយ។ ដូចគ្នាដែរ ច្បាប់ណាដែលក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យរួចហើយ មិនអាចលើកយកមកពិនិត្យធម្មនុញ្ញភាពសាជាថ្មីម្តងទៀតឡើយ ទោះបីក្នុងការអនុវត្តន៍ទៅ គេឃើញថាច្បាប់ដែលក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យមើលហើយនោះ នៅមានកន្លែងខ្លះខុសនឹងរដ្ឋធម្មនុញ្ញក៏ដោយ។

ក្នុងករណីទាំងពីរខាងលើនេះ "កិច្ចរដ្ឋបាល" ដែលប្រតិបត្តិតាមច្បាប់ដែលខុសនឹងរដ្ឋធម្មនុញ្ញនោះ នឹងពុំមានស្ថាប័នណាអាចរំលាយបានឡើយ ក្នុងស្ថានភាពគតិយុត្តរបស់ប្រទេសបារាំង សព្វថ្ងៃ។

បទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ និងគោលការណ៍គ្រឹះនៃបុព្វកថារដ្ឋធម្មនុញ្ញ ត្រូវបានគេបញ្ចូលក្នុងអ្វីដែលគេហៅថា ដុំធម្មនុញ្ញភាព (bloc de constitutionnalité)។ ដុំធម្មនុញ្ញភាពនេះចេះតែរីកធំឡើងៗ ដោយសារតែក្រុមប្រឹក្សាធម្មនុញ្ញទទួលយកគោលការណ៍គ្រឹះនៃបុព្វកថានោះ អោយមានតម្លៃជាបទបញ្ញត្តិរដ្ឋធម្មនុញ្ញដែរ។ បទបញ្ញត្តិដែលចេញពីបុព្វកថារដ្ឋធម្មនុញ្ញ មានជាអាទិ៍ សេចក្តីប្រកាសសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋ ឆ្នាំ១៧៨៩ (Déclaration des droits de l'Homme et du Citoyen de 1789) គោលការណ៍គ្រឹះដែលទទួលស្គាល់ដោយច្បាប់សាធារណៈរដ្ឋ (Principes fondamentaux reconnus per les lois de la République) សេរីភាពធ្វើសមាគម សេរីភាពខាងសិក្សាធិការ និងឯករាជ្យភាពនៃយុត្តាធិការរដ្ឋបាល។ល។

រដ្ឋការបារាំង ត្រូវតែគោរពជាដាច់ខាត នូវបទបញ្ញត្តិក្នុង "ដុំរដ្ឋធម្មនុញ្ញ" (ឬប្លុកធម្មនុញ្ញភាព) នេះ។ ដូច្នេះ នីតិរដ្ឋធម្មនុញ្ញបារាំង ជាប្រភពមួយដ៏សំខាន់នៃនីតិរដ្ឋបាលរបស់បារាំង។[១០]

សាធារណៈរដ្ឋបារាំងជួបវិបត្តិច្រើនដោយសារការអនុវត្តន៍រដ្ឋធម្មនុញ្ញ។ ប្រទេសបារាំង គឺជាប្រទេសដែលប្រមូលផ្តុំទៅដោយច្បាប់រដ្ឋធម្មនុញ្ញ។ ប្រធានាធិបតីមានអាណត្តិ ៧ឆ្នាំ បោះឆ្នោតដោយសេរី ដោយសកល។ រដ្ឋសភាមានសមាជិក ៥៧៧នាក់ មានអាណត្តិ ៥ឆ្នាំ បោះឆ្នោតជាសកល និងបិទមុខ។ ព្រឹទ្ធសភាមានសមាជិក ៣១៩នាក់ បោះឆ្នោតដោយអសកលតាមផ្នែកនីមួយៗ មានន័យថា សមាជិកព្រឹទ្ធសភាចំនួន ២/៣ ត្រូវផ្លាស់ថ្មី

[១០] បណ្ឌិតសាយ បូរី នីតិរដ្ឋបាលទូទៅ បោះពុម្ពលើកទី២ឆ្នាំ២០០១,ទំព័រទី៣៩

ក្នុងរយៈពេល ៣ឆ្នាំម្តង ដោយឆ្លងកាត់គណៈកម្មការបោះឆ្នោតមណ្ឌលនីមួយៗ។ ក្នុងរដ្ឋធម្មនុញ្ញបារាំងក៏មានកំណត់កម្រិតអំណាចប្រធានាធិបតីផងដែរ។

បារាំងជាប្រទេសប្រើប្រព័ន្ធបោះឆ្នោត "ភាគច្រើន" (Majority System)។ ប្រព័ន្ធ៥០%+១ មានលក្ខខ័ណ្ឌពីរ ក្នុងការអនុម័តច្បាប់បោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ និងប្រធានាធិបតីសាធារណៈរដ្ឋ។

លក្ខខ័ណ្ឌទី១ : បើសិនជាបេក្ខជន ឬគណបក្សបានទទួលសន្លឹកឆ្នោតគាំទ្រ ពីប្រជាពលរដ្ឋច្រើនជាង ៥០%(ច្រើនជាង ៥០%ឡើងទៅ) ហើយមានការចូលរួមពីប្រជាពលរដ្ឋច្រើនជាង ២៥% ដែលចំនួនទាំងនេះសមាមាត្រ(ធៀប ឬទូទាត់) ទៅនឹងបេក្ខភាព និងបេក្ខភាពតំណាងរាស្ត្រ ក្នុងខណៈពេលបោះឆ្នោតលើកទី១ អាចចាត់ទុកថា ក្រុមប្រឹក្សាបោះឆ្នោត បានបញ្ចប់ភារកិច្ចរបស់ខ្លួន មានន័យថា អ្នកឈ្នះឆ្នោតអាចបង្កើតប្រព័ន្ធប្រធានាធិបតី រដ្ឋាភិបាល និងរដ្ឋសភាតាមច្បាប់។

លក្ខខ័ណ្ឌទី២ : ប្រសិនបើការជ្រើសរើសបេក្ខជនប្រធានាធិបតី ឬតំណាងរាស្ត្រ បានទទួលសន្លឹកឆ្នោតតិចជាង ៥០% នោះក្រុមប្រឹក្សាបោះឆ្នោតត្រូវចាត់ចែងធ្វើការបោះឆ្នោតសារជាថ្មីឡើងវិញ។

ការបោះឆ្នោតជ្រើសរើសប្រធានាធិបតីលើកទី២ បេក្ខជនប្រធានាធិបតីត្រូវបានជ្រើសរើសយកតែពីរនាក់គត់ គឺអ្នកដែលបានទទួលសន្លឹកឆ្នោតច្រើនជាងគេនៅក្នុងចំណោមទាំងអស់។ បេក្ខជនដែលឈ្នះឆ្នោតច្រើនជាងគេនៅលើកទី២ ត្រូវបានជ្រើសរើសតាំងជាប្រធានាធិបតីសាធារណៈរដ្ឋ។ ការអនុវត្តន៍ច្បាប់នេះបានបញ្ជាក់ថា អ្នកដែលបានទទួលសន្លឹកឆ្នោតច្រើនជាងគេ ក្នុងការបោះឆ្នោតលើកទី១ មិនអាចពិតប្រាកដថា ឈ្នះឆ្នោតលើកទី២ ទៀតនោះទេ ជាក់ស្តែងការបោះឆ្នោតជ្រើសរើសប្រធានាធិតីបារាំងនៅឆ្នាំ១៩៩៥។

ក្នុងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រលើកទី២ ក៏មានលក្ខណៈប្រហាក់ប្រហែលគ្នានេះដែរ។ បេក្ខជនឈរឈ្មោះ អាចជ្រើសរើសយកមកបោះឆ្នោតលើកទី២ បានគឺអាស្រ័យទៅនឹងលក្ខខ័ណ្ឌ ដែលបុគ្គលនោះទទួលការគាំទ្រ ហើយមានសន្លឹកឆ្នោតយ៉ាងតិច ១២.៥% នៃប្រជារាស្ត្រដែលចូលរួមបោះឆ្នោតទាំងអស់។ អ្នកដែលអាចសន្មត់ថាជាប់ឆ្នោតជាស្ថាពរ គឺបានទទួលសន្លឹកឆ្នោតច្រើនជាគេ(លើសគេ)។ ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្របែបបារាំង ប្រើប្រព័ន្ធឯកត្តនាម។ ប្រព័ន្ធនេះត្រូវបានអោយឈ្មោះថា Majorital Uninominal System ។ ក្នុងការបោះឆ្នោតជ្រើសរើសសភាសហភាពអឺរ៉ុប ប្រទេសបារាំងប្រើប្រព័ន្ធបោះឆ្នោតសមាមាត្រ Proportionate System ។

ប្រព័ន្ធបោះឆ្នោតបែបអសកល ឬជាប្រយោល ត្រូវបានអនុវត្តន៍នៅក្នុងប្រព័ន្ធជ្រើសតាំង សមាជិកព្រឹទ្ធសភា។ ប្រជាពលរដ្ឋបារាំងទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ២៣ឆ្នាំ អាចឈរឈ្មោះ ជាបេក្ខជនតំណាងរាស្ត្រ និងឈរឈ្មោះជាបេក្ខជនសមាជិកព្រឹទ្ធសភា មានអាយុយ៉ាងតិច ៣៥ឆ្នាំ។ សមាជិកព្រឹទ្ធសភាមានធាតុផ្សំដូចជា សមាជិកសភា សមាជិកជ្រើសរើសតាមមណ្ឌល សមាជិកមកពីរដ្ឋាភិបាល ប្រធានគណៈកម្មាធិការ សហគមន៍ ដែលតាមក្បួនខាតជ្រើសរើសយកបុគ្គលណា ដែលមានសន្លឹកឆ្នោតគាំទ្រច្រើនជាងគេ។ ការបោះឆ្នោតជ្រើសរើសព្រឹទ្ធសភា ប្រព្រឹត្តទៅតាមប្រព័ន្ធសមាមាត្រ(Propotionat System) ។

ដូច្នេះ អាចសន្និដ្ឋានបានថា រដ្ឋធម្មនុញ្ញបារាំងប្រជុំទៅដោយប្រព័ន្ធផ្សេង "ប្រព័ន្ធល្បាយ" ដែលប្រទេសបារាំងខ្លួនឯងជាអ្នកបង្កើតឡើង ហើយពិបាកអនុវត្តន៍។ ម្យ៉ាងវិញទៀតដោយមានភាពចម្រុះបែបនេះ ទើបបង្កើតអោយមានភាពសម្បូរច្រកចេញ ដែលធ្វើអោយប្រាសចាកពីច្បាប់រដ្ឋធម្មនុញ្ញ។ តាមការសង្កេតគេឃើញមានកើតវិបត្តិខ្លាំងនៅឆ្នាំ ១៩៥៨ , ៦០ , ៧០ , នាសតវត្សទី១០ ។

១០.៩.រដ្ឋធម្មនុញ្ញសហព័ន្ធរុស្ស៊ី

តុល្យភាពទាំងបីក្នុងរដ្ឋធម្មនុញ្ញសហព័ន្ធរុស្ស៊ី។

រដ្ឋសហព័ន្ធមានធាតុផ្សំ ៨៣រដ្ឋ ខេត្តក្រុង។ រដ្ឋសភាមានសមាជិក ៤៥០នាក់ ព្រឹទ្ធសភាមាន ១៧៨នាក់ មានអាណត្តិ ៤ឆ្នាំ។ ប្រធានាធិបតីសហព័ន្ធរុស្ស៊ី ជាមេបញ្ជាការ និងជាប្រធានរដ្ឋ។ តាមច្បាប់រដ្ឋធម្មនុញ្ញ ប្រធានាធិបតី បន្ទុកទៅដោយសិទ្ធិអំណាចខ្ពស់ មានអាណត្តិរបស់ខ្លួន ៤ឆ្នាំ។ សភានៅតាមរដ្ឋសភា នៅតាមរដ្ឋសហព័ន្ធនីមួយៗ មានអាណត្តិ ៣ឆ្នាំ មានរចនាសម្ព័ន្ធដឹកនាំប្រហាក់ប្រហែលនឹងសភាសហព័ន្ធដែរ។ ការបោះឆ្នោតប្រព្រឹត្តទៅក្នុងរយៈពេលបន្តបន្ទាប់ ហើយពុំមានគំលាតឆ្ងាយពីគ្នាឡើយ។ ស្មារតីនៃរដ្ឋធម្មនុញ្ញបែបនេះមិនបានបង្ហាញពីភាពស្មុគស្មាញការបន្ទុកបង្អាក់ក្នុងអាណត្តិដឹកនាំរបស់អង្គការនីតិប្រតិបត្តិ។ ការបែងចែកមុខងារនៃស្ថាប័ននីមួយៗ មានកំណត់ច្បាស់លាស់(ឧ. តួនាទី សិទ្ធិអំណាច ប្រធានាធិបតី ៦ប្រការសំខាន់ៗ និងមាន ១៤ មាត្រា ក្នុងច្បាប់រដ្ឋធម្មនុញ្ញ , រដ្ឋសភាសហព័ន្ធមាន ១១ប្រការ , រដ្ឋាភិបាលសហព័ន្ធមាន ៧ប្រការ , តុលាការសហព័ន្ធមាន ៦ប្រការសំខាន់ៗ)។ អំណាចនៃស្ថាប័ននីមួយៗ និងតួនាទីបុគ្គលជាតំណាងក្នុង ស្ថាប័នណាមួយត្រូវបានបែងចែក និងចែករំលែកដាច់ពីគ្នា។ ប្រធានាធិបតីជាអ្នកតែងតាំងនាយករដ្ឋមន្ត្រីសហព័ន្ធ ដោយមានការយល់ព្រមពីសភាសហព័ន្ធ។ ប្រធានាធិបតី ជាប្រធានអង្គប្រជុំ រដ្ឋាភិបាលសហព័ន្ធមានសិទ្ធិអនុម័តទម្លាក់ រដ្ឋាភិបាលសហព័ន្ធ មានសិទ្ធិជ្រើសរើស និងដកតំណែងប្រធានធានាគាជាតិ ដោយលើកយកបញ្ហានេះ ដាក់ជូនរដ្ឋសភាសហព័ន្ធអនុម័ត។ តាមការស្នើសុំពីនាយករដ្ឋមន្ត្រី ប្រធានាធបតីអាចដកហូតឧបនាយករដ្ឋមន្ត្រីសហព័ន្ធ។ ប្រធានាធិបតីមានសិទ្ធិជ្រើសរើសបេក្ខជនក្នុងស្ថាប័នតុលាការសហព័ន្ធ ដាក់ជូនព្រឹទ្ធសភា អោយសម្រេចចាត់តាំង និងបញ្ជូនត្រឡប់មកមាតុប្រទេសវិញនូវអគ្គរដ្ឋទូតបន្ទាប់ពីធ្វើការសាកសួរយោបល់ពីក្រុមប្រឹក្សានៃសភាដែលទទួលបន្ទុកផ្នែកការបរទេស ជាអ្នកកំណត់ពេលវេលាបោះឆ្នោតជ្រើសរើសសមាជិកតំណាងរាស្ត្រ តាមច្បាប់រដ្ឋធម្មនុញ្ញសហព័ន្ធ។ប្រធានាធិបតីមានសិទ្ធិរំលាយសភាសហព័ន្ធក្នុងសភាពការចៃដន្យ និងក្នុងសណ្តាប់ធ្នាប់ មានចែងកំណត់ក្នុងច្បាប់រដ្ឋធម្មនុញ្ញ។ ប្រធានាធិបតីជាអ្នកបញ្ជូនច្បាប់ដាក់អោយសភាអនុម័ត។ ប្រធានាធិបតី អាចមានសិទ្ធិដោះស្រាយនូវទំនាស់ផ្សេងៗក្នុងស្ថាប័នរវាងស្ថាប័ន និងបញ្ហាសហព័ន្ធទាំងមូល, អាចបញ្ឈប់នូវការអនុវត្តន៍ច្បាប់ទាំងឡាយណា ដែលមានស្របនឹងច្បាប់រដ្ឋធម្មនុញ្ញ។ អង្គប្រធានាធិបតី មិនអាចនរណារំលោភបំពានបានឡើយ។ ក្នុងខណៈចៃដន្យ ប្រធានាធិបតីមិនអាចបំពេញភារកិច្ចរបស់ខ្លួនបាន ប្រធានរដ្ឋាភិបាល(នាយករដ្ឋមន្ត្រី) អាចចូលបំពេញការងារជាធម្មតា ប៉ុន្តែមិនអាចមានសិទ្ធិរំលោភរដ្ឋសភា កំណត់ពេលវេលាជាប្រជាមតិ ហើយមិនអាចដាក់ជូនរដ្ឋសភានូវបញ្ហាផ្សេងៗ ក្នុងការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញបានដែរ។

ប្រធានាធិបតីរុស្ស៊ី អាចទម្លាក់ចេញពីតំណែង ដោយព្រឹទ្ធសភាសហព័ន្ធយោងតាមមូលដ្ឋាននៃការពិភាក្សាចោទប្រកាន់ពីសំណាក់រដ្ឋសភាសហព័ន្ធ អំពើក្បត់ជាតិ ករណីប្រព្រឹត្តបទល្មើស និងមានការត្រួតពិនិត្យហេតុផលច្បាស់លាស់ ពីក្រុមប្រឹក្សាតុលាការធម្មនុញ្ញ។ ការអនុម័តច្បាប់របស់រដ្ឋសភាសហព័ន្ធអំពីការប្រកាន់ និងការទម្លាក់ប្រធានាធិបតីពីតំណែង ដោយព្រឹទ្ធសភាសហព័ន្ធអាចធ្វើទៅបាន លុះត្រាតែមានសំឡេងចំនួន ២/៣ ពីសមាជិកទាំងអស់ពីសភានីមួយៗ។ សេចក្តីចោទប្រកាន់អាចធ្វើទៅបាន ដោយតាមការស្នើសុំពីសមាជិករដ្ឋសភាសហព័ន្ធចំនួន ១/៣ យ៉ាងតិច និងមានគណៈកម្មការពិសេស ដែលបង្កើតឡើងដោយរដ្ឋសភាជាអ្នកវាយតម្លៃ។ ការអនុម័តសភា ទម្លាក់ប្រធានាធិបតីពីតំណែងប្រព្រឹត្តទៅមិនលើសពីរយៈពេល ៣ខែឡើយ បន្ទាប់ពីរដ្ឋសភាអាចធ្វើការចោទប្រកាន់រួចមក។ បើសិនជាក្នុងរយៈពេលនេះព្រឹទ្ធសភាសហព័ន្ធ ពុំបានធ្វើការសម្រេច នោះ

ចាត់ទុកជាមោឃៈ។ ការកណាត់អំណាចតាមតួនាទីដាច់ដោយឡែកពីគ្នា ដូច្នេះ បានបង្ហាញអោយឃើញនូវយន្តការរលូនក្នុងប្រព័ន្ធគ្រប់គ្រងប្រទេស ប្រធានាធិបតីមានសិទ្ធិតែងតាំងនាយករដ្ឋមន្ត្រី។[១១]

[១១] និក្ខេបបទ អ៊ុំ សំអាង និរន្តរភាពនយោបាយស្ថាប័នអង្គការនីតិប្រតិបត្តិឆ្នាំ១៩៩៣-២០០៥, បោះពុម្ពឆ្នាំ២០០៥,ទំព័រ២៤០-២៤៥

**១០.សេចក្តីសន្និដ្ឋាន**

អាស្រ័យដោយការអធិប្បាយដូចខាងលើ គេអាចអោយនិយមន័យរដ្ឋធម្មនុញ្ញថា ជាច្បាប់ដោយឡែកពីបណ្តាច្បាប់ឯទៀត ដែលចែងតែអំពីស្ថាប័ន និងគោលការណ៍សំខាន់ៗដែលត្រូវបានបង្កើតឡើងនឹងកែប្រែតាមនីតិវិធីឱឡារិក ហើយរដ្ឋធម្មនុញ្ញគេចាត់ទុកថា ជាច្បាប់កំពូល។ ដូច្នេះ បានជានៅប្រទេសមួយចំនួន គេមិនអោយឈ្មោះរដ្ឋធម្មនុញ្ញតែគេហៅថា "ច្បាប់គ្រឹះ" ទៅវិញ ដូចជានៅប្រទេសអាឡឺម៉ង់ ជាដើម (Fundamental law) ។

ការបង្កើតរដ្ឋធម្មនុញ្ញ គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់បណ្តាប្រទេស ឬរដ្ឋនីមួយៗព្រោះរដ្ឋធម្មនុញ្ញជាច្បាប់គ្រឹះដ៏សំខាន់សម្រាប់ដំណើរការដឹកនាំប្រទេស ក្នុងការគ្រប់គ្រងរដ្ឋ អនុវត្តអំណាចរបស់រដ្ឋ និងជាមូលដ្ឋានគ្រឹះ ដែលជាគោលសម្រាប់ធ្វើច្បាប់។ គួរបញ្ជាក់ដែរថា រាល់ច្បាប់ និងឯកសារគតិយុត្តទាំងឡាយ ត្រូវអនុលោមទៅ តាមរដ្ឋធម្មនុញ្ញ បើពុំនោះសោត ច្បាប់ និងឯកសារគតិយុត្តទាំងនោះនឹងអធម្មនុញ្ញភាព។ ម្យ៉ាងវិញទៀតរដ្ឋធម្មនុញ្ញបានចែងយ៉ាងច្បាស់លាស់អំពីសិទ្ធិ ការបែងចែកអំណាច និងរបបនយោបាយនៃការគ្រប់គ្រងប្រទេស យ៉ាងច្បាស់លាស់។

ធម្មជាតិរបស់មនុស្ស មានចំណុចប្លែកគ្នាជាច្រើនទាំងសតិបញ្ញា រាងកាយ ភាពក្លាហាន ភាពភ័យខ្លាចមហិច្ឆិតា និងលទ្ធភាព ដែលជាប្រភពបង្ករអោយមានទំនាស់ជាច្រើននឹងកើតមានរវាងសមាជិកទាំងឡាយក្នុងសង្គម និងធ្វើអោយគ្មានរបៀបរៀបរយ។ ដើម្បីធ្វើអោយមានរបៀបរៀបរយ និងបំបាត់ទំនាស់ក្នុងសង្គម គឺជាការចាំបាច់រៀបចំអោយមានច្បាប់ក្នុងសង្គម ដើម្បីអោយមានការគោរពបទដ្ឋានក្នុងការរស់នៅដោយរក្សាអោយមានសុវត្ថិភាព សន្តិភាពជាមួយគ្នា ដើម្បីធានាអោយមានការអនុវត្តច្បាប់ វិន័យ សីលធម៌នេះដោយម៉ត់ចត់ និងដើម្បីភាពយុត្តិធម៌សម្រាប់សមាជិកក្នុងសង្គមទាំងមូល។

ដូច្នេះ យើងម្នាក់ៗត្រូវតែខិតខំប្រឹងប្រែង ទោះជាតាមវិធីណាក៏ដោយ ដើម្បីបង្កើតការការពារមាតុភូមិលើវិស័យសន្តិសុខ សុវត្ថិភាព សន្តិភាព ស្ថេរភាពនយោបាយ ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ការទំនាក់ទំនងល្អជាមួយអន្តរជាតិ ទើបសង្គមជាតិរបស់យើងក្លាយទៅជាប្រជាជាតិមួយរុងរឿងទៅបាន។ កាលណាប្រទេសមួយមានរដ្ឋធម្មនុញ្ញ និងមានច្បាប់សម្រាប់អនុវត្តត្រឹមត្រូវច្បាស់លាស់ហើយ នោះប្រជាពលរដ្ឋប្រាកដជានាំគ្នាគោរពច្បាប់គ្រប់ៗគ្នា ហើយទីបំផុតប្រទេសនឹងឈានទៅរកនីតិរដ្ឋ និងការរីកចម្រើនយ៉ាងពិតប្រាកដ ដូចអរិយប្រទេសលើពិភពលោក។

# ឯកសារយោង


១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

២. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣..................................................បោះពុម្ពឆ្នាំ២០១០

៣. អត្ថបទមេរៀនសាស្ត្រាចារ្យ ដុំ អ៊ីម នៃសាកលវិ.ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

៤. ចោង ស៊ីម នីតិរដ្ឋធម្មនុញ្ញៈ បណ្ឌិត្យសភានគរបាលកម្ពុជា.......................................បោះពុម្ពឆ្នាំ២០១១

៥. បណ្ឌិតសាយ បូរី នីតិរដ្ឋបាលទូទៅ បោះពុម្ពលើកទី២..........................................បោះពុម្ពឆ្នាំ២០០១

៦. និក្ខេបបទ អ៊ុំ សំអាង និរន្តរភាពនយោបាយស្ថាប័នអង្គការនីតិប្រតិបត្តិឆ្នាំ១៩៩៣-២០០៥ បោះពុម្ពឆ្នាំ២០០៥

៧. Web site: WWW.Senate.gove.kh , ម៉ោង១០:00ព្រឹក.........................................២៥/០៦/២០១១

# ឧបសម្ព័ន្ធ

# រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣

# នៃ

# ព្រះរាជាណាចក្រកម្ពុជា

# បុព្វកថា

# យើង ប្រជារាស្ត្រខ្មែរ

ដែលធ្លាប់មានអារ្យធម៌ឧត្តុង្គឧត្តម ប្រទេសជាតិស្ដុកស្ដម្ភធំទូលាយថ្កុំថ្កើងរុងរឿង កិត្យានុភាពខ្ពង់ខ្ពស់ ភ្លឺថ្លៃថ្លាចែងចាំងដូចពេជ្រពណ្ណរាយ

បានធ្លាក់ខ្លួនដ៏សែនរន្ធត់ ក្នុងអំឡុងពីរទសវត្សចុងក្រោយនេះ ឆ្លងកាត់ទុក្ខសោកវិនាសអន្តរាយទ្រុឌទ្រោម ឱនថយមហាសោកស្ដាយ

បានភ្ញាក់រលឹក ក្រោកឈរឡើង ចងបាច់ឆន្ទៈ មោះមុត ប្ដូរផ្ដាច់ រួបរួមគ្នាពង្រឹងឯកភាពជាតិ រក្សាការពារទឹកដីកម្ពុជា អធិបតេយ្យថ្លៃថ្លា និងអារ្យធម៌អង្គរដ៏បវរ កសាងប្រទេសជាតិឱ្យទៅជា "កោះសន្តិភាព" ឡើងវិញ ផ្អែកលើប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស ធានាសិទ្ធិមនុស្ស គោរពច្បាប់ ទទួលខុសត្រូវខ្ពស់ ចំពោះវាសនាអនាគតជាតិ ឱ្យបានឈានឡើង រីកចំរើនលូតលាស់ សម្បូររុងរឿង ជានិច្ច និរន្តរ៍ ។

**ក្នុងឆន្ទៈមោះមុតនេះ**

យើងសរសេរចារឹកក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដូចតទៅ :

## ជំពូកទី១

## អំពី អធិបតេយ្យ

**មាត្រា ១.-**

ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រ ដែលព្រះមហាក្សត្រ ទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិប-តេយ្យ សេរីពហុបក្ស ។

ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹត្យ អចិន្ត្រៃយ៍ មិនចូលបក្សសម្ព័ន្ធ ។

**មាត្រា ២.-**

បូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា មិនអាចរំលោភបានដាច់ខាតក្នុងព្រំដែនរបស់ខ្លួនដែលមានកំណត់ក្នុងផែនទីខ្នាត ១/១០០.០០០ ធ្វើនៅចន្លោះឆ្នាំ ១៩៣៣-១៩៥៣ ហើយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិនៅចន្លោះ ឆ្នាំ ១៩៦៣-១៩៦៩ ។

**មាត្រា ៣.-**

ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋដែលមិនអាចបំបែកបាន ។

**មាត្រា ៤.-**

បាវចនានៃព្រះរាជាណាចក្រកម្ពុជា គឺ : ជាតិ សាសនា ព្រះមហាក្សត្រ ។

**មាត្រា ៥.-**

ភាសា និងអក្សរ ដែលប្រើជាផ្លូវការ គឺភាសា និងអក្សរខ្មែរ ។

**មាត្រា ៦.-**

ភ្នំពេញជារាជធានី នៃព្រះរាជាណាចក្រកម្ពុជា ។

ទង់ជាតិ ភ្លេងជាតិ និងសញ្ញាជាតិ មានកំណត់នៅក្នុងឧបសម្ព័ន្ធ ១ , ២ និង ៣ ។

## ជំពូកទី២
## អំពី ព្រះមហាក្សត្រ

**មាត្រា ៧.-**

ព្រះមហាក្សត្រកម្ពុជាទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ ។

ព្រះមហាក្សត្រទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត ។

អង្គព្រះមហាក្សត្រ មិនអាចនរណារំលោភបំពានបានឡើយ ។

**មាត្រា ៨.-**

ព្រះមហាក្សត្រ ព្រះអង្គទ្រង់ជានិមិត្តរូប នៃឯកភាពជាតិ និងនិរន្តរភាពជាតិ ។

ព្រះមហាក្សត្រ ទ្រង់ជាអ្នកធានាឯករាជ្យជាតិ អធិបតេយ្យ និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ជាអ្នកធានាការគោរពសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ និងការគោរពសន្ធិសញ្ញាអន្តរជាតិ ។

**មាត្រា ៩.-**

ព្រះមហាក្សត្រ ទ្រង់មានតួនាទីខ្ពង់ខ្ពស់ជាអាជ្ញាកណ្តាល ដើម្បីធានាការប្រព្រឹត្តទៅនៃអំណាចសាធារណៈឱ្យមានភាពទៀងទាត់ ។

**មាត្រា ១០.-**

របបរាជានិយមកម្ពុជា ជារបបជ្រើសតាំង ។

ព្រះមហាក្សត្រ ទ្រង់ឥតមានព្រះរាជអំណាចចាត់តាំងព្រះរជ្ជទាយាទ សម្រាប់គ្រងរាជសម្បត្តិឡើយ ។

**មាត្រា ១១.- ថ្មី**

ក្នុងករណីដែលព្រះមហាក្សត្រ ពុំអាចបំពេញព្រះរាជភារៈ ជាព្រះប្រមុខរដ្ឋបានដូចធម្មតា ដោយព្រះអង្គទ្រង់ប្រឈួនជាទម្ងន់មានការបញ្ជាក់ដោយក្រុមគ្រូពេទ្យជំនាញ ជ្រើសរើសដោយប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា និង នាយករដ្ឋមន្ត្រី នោះប្រធានព្រឹទ្ធសភាបំពេញភារកិច្ចប្រមុខរដ្ឋជំនួសព្រះអង្គក្នុងឋានៈជាព្រះរាជានុសិទ្ធិ ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភា ពុំមានលទ្ធភាពបំពេញភារកិច្ចជាប្រមុខរដ្ឋជំនួសព្រះមហាក្សត្រ ក្នុងឋានៈជាព្រះរាជានុសិទ្ធិ ពេលព្រះអង្គទ្រង់ប្រឈួនជាទម្ងន់ ដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ ប្រធានរដ្ឋសភាជាអ្នកបំពេញភារកិច្ចនេះ ។

តំណែងជាប្រមុខរដ្ឋជំនួសព្រះមហាក្សត្រក្នុងឋានៈជាព្រះរាជានុសិទ្ធិនេះ អាចនឹងដូរឥស្សរជនផ្សេងទៀត ក្នុងករណីដូចដែលបានចែងក្នុងវាក្យខ័ណ្ឌខាងលើ តាមឋានានុក្រមដូចតទៅ :

| | |
|---|---|
| ក-អនុប្រធានទី ១ | ព្រឹទ្ធសភា |
| ខ-អនុប្រធានទី ១ | រដ្ឋសភា |
| គ-អនុប្រធានទី ២ | ព្រឹទ្ធសភា |

ឃ-អនុប្រធានទី ២ រដ្ឋសភា

**មាត្រា ១២.~ ថ្មី**

នៅពេលព្រះមហាក្សត្រទ្រង់ចូលទិវង្គត ប្រធានព្រឹទ្ធសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ក្នុងឋានៈជាព្រះរាជានុ-សិទ្ធិនៃព្រះរាជាណាចក្រកម្ពុជា ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភាពុំមានលទ្ធភាពបំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទីជំនួសព្រះមហាក្សត្រ ក្នុងពេលព្រះ-អង្គចូលទិវង្គត ការទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីក្នុងឋានៈជាព្រះរាជានុសិទ្ធិ ត្រូវអនុវត្តតាមវាក្យខ័ណ្ឌទី ២ និងទី ៣ នៃមាត្រា ១១ ថ្មី។

**មាត្រា ១៣.~ ថ្មី**

ក្នុងរយៈវេលា ៧ថ្ងៃយ៉ាងយូរ ព្រះមហាក្សត្រថ្មីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សារាជសម្បត្តិ ។

សមាសភាពនៃក្រុមប្រឹក្សារាជសម្បត្តិមាន :

- ប្រធានព្រឹទ្ធសភា
- ប្រធានរដ្ឋសភា
- នាយករដ្ឋមន្ត្រី
- សម្តេចព្រះសង្ឃរាជគណៈមហានិកាយ និងគណៈធម្មយុត្តិកនិកាយ
- អនុប្រធានទី ១ និងអនុប្រធានទី ២ ព្រឹទ្ធសភា
- អនុប្រធានទី ១ និងអនុប្រធានទី ២ រដ្ឋសភា

ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិនឹងមានកំណត់ក្នុងច្បាប់មួយ ។

**មាត្រា ១៤.~**

ត្រូវបានជ្រើសរើសជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សមាជិកនៃព្រះរាជវង្សានុវង្សខ្មែរ ដែលមានព្រះ-ជន្មាយុយ៉ាងតិច ៣០ ព្រះវស្សា ហើយដែលជាព្រះរាជបច្ឆាញាតិនៃព្រះមហាក្សត្រ **អង្គឌួង** ឬព្រះមហាក្សត្រ **នរោត្តម** ឬ ក៏ព្រះមហាក្សត្រ **ស៊ីសុវត្ថិ** ។

មុនចូលគ្រងរាជសម្បត្តិ ព្រះមហាក្សត្រទ្រង់ថ្លែងសច្ចាប្រណិធាន ដូចមានចែងក្នុងឧបសម្ព័ន្ធទី ៤ ។

**មាត្រា ១៥.~**

ព្រះជាយានៃព្រះមហាក្សត្រ មានព្រះរាជឋានៈជាព្រះមហេសីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១៦.~**

ព្រះមហេសីនៃព្រះរាជាណាចក្រកម្ពុជា ពុំមានព្រះរាជសិទ្ធិធ្វើនយោបាយ ទទួលតួនាទីជាអ្នកដឹកនាំរដ្ឋ ឬជាអ្នកដឹកនាំរាជរដ្ឋាភិបាល ឬទទួលតួនាទីរដ្ឋបាល ឬនយោបាយឡើយ ។

ព្រះមហេសីនៃព្រះរាជាណាចក្រកម្ពុជា ទុកព្រះរាជកាយពល បំពេញព្រះរាជភារៈបំរើប្រយោជន៍សង្គម មនុស្ស-ធម៌ សាសនា និងជួយព្រះមហាក្សត្រ ក្នុងព្រះរាជកាតព្វកិច្ច ផ្នែកពិធីការ និងការទូត ។

**មាត្រា ១៧.-**

ប្រការដែលព្រះមហាក្សត្រ ទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ ហើយដែលមានចែងក្នុងវាក្យ-ខ័ណ្ឌទីមួយនៃមាត្រា ៧ នៃរដ្ឋធម្មនុញ្ញនេះមិនអាចសុំកែប្រែបានជាដាច់ខាត ។

**មាត្រា ១៨.- ថ្មី**

ព្រះមហាក្សត្រ ព្រះអង្គទ្រង់ទាក់ទងជាមួយព្រឹទ្ធសភា និងរដ្ឋសភា ដោយព្រះរាជសារ ។

ព្រះរាជសារនេះ ព្រឹទ្ធសភា និងរដ្ឋសភាមិនអាចយកទៅជជែកពិភាក្សាឡើយ ។

**មាត្រា ១៩.- ថ្មី**

ព្រះមហាក្សត្រទ្រង់តែងតាំងនាយករដ្ឋមន្ត្រី និង ទ្រង់តែងតាំងគណៈរដ្ឋមន្ត្រី តាមបែបបទដែលមានចែងក្នុងមាត្រា១១៩ ថ្មី ។

**មាត្រា ២០.-**

ព្រះមហាក្សត្រទ្រង់ទទួលសវនាការជាផ្លូវការពីរដងក្នុងមួយខែ ឱ្យនាយករដ្ឋមន្ត្រី និងគណៈរដ្ឋមន្ត្រីចូលគាល់ រាយ-ការណ៍ទូលថ្វាយទ្រង់ជ្រាប អំពីសភាពការណ៍ នៃប្រទេសជាតិ ។

**មាត្រា ២១.-**

តាមសេចក្តីស្នើរបស់គណៈរដ្ឋមន្ត្រី ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតែងតាំង ផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីជាន់ខ្ពស់ស៊ីវិល និងយោធា ឯកអគ្គរាជទូត និងប្រេសិតវិសាមញ្ញ និងពេញសមត្ថភាព ។

តាមសេចក្តីស្នើរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតែងតាំង ផ្លាស់ប្តូរ ឬដកចៅក្រមផ្នែកយុត្តាធិការ ។

**មាត្រា ២២.- ថ្មី**

នៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ព្រះមហាក្សត្រទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈ ដាក់ប្រទេសជាតិស្ថិតនៅក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពី នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា ។

**មាត្រា ២៣.-**

ព្រះមហាក្សត្រ ទ្រង់ជាមេបញ្ជាការកំពូល នៃកងយោធពលខេមរភូមិន្ទ ។ អគ្គមេបញ្ជាការកងយោធពលខេមរ-ភូមិន្ទ ត្រូវបានតែងតាំងឡើង ដើម្បីបញ្ជាកងយោធពលខេមរភូមិន្ទនេះ ។

**មាត្រា ២៤.- ថ្មី**

ព្រះមហាក្សត្រ ទ្រង់គង់ជាព្រះអធិបតី នៃឧត្តមក្រុមប្រឹក្សាការពារជាតិ ដែលនឹងត្រូវបង្កើតឡើងដោយច្បាប់មួយ ។

ព្រះមហាក្សត្រទ្រង់ប្រកាសសង្គ្រាម ក្រោយការអនុម័តរបស់រដ្ឋសភា និងព្រឹទ្ធសភា ។

**មាត្រា ២៥.-**

ព្រះមហាក្សត្រ ទ្រង់ទទួលសារតាំងឯកអគ្គរដ្ឋទូត ឬប្រេសិតវិសាមញ្ញ និងពេញសមត្ថភាពនៃប្រទេសក្រៅមកប្រចាំព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៦.- ថ្មី**

ព្រះមហាក្សត្រ ទ្រង់ឡាយព្រះហស្តលេខាលើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ ហើយទ្រង់ប្រទានសច្ចាប័នលើសន្ធិសញ្ញា និងអនុសញ្ញាទាំងនេះ ក្រោយបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភា និងព្រឹទ្ធសភា ។

**មាត្រា ២៧.-**

ព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស និងលើកលែងទោស ។

**មាត្រា ២៨.- ថ្មី**

ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខា លើព្រះរាជក្រមប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ និងទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី ។

ក្នុងពេលដែលព្រះមហាក្សត្រប្រឈួន ហើយត្រូវព្យាបាលព្រះរោគនៅបរទេស ក្នុងពេលនោះព្រះមហាក្សត្រមានសិទ្ធិផ្ទេរអំណាចឡាយព្រះហស្តលេខានៅលើព្រះរាជក្រម ឬព្រះរាជក្រឹត្យខាងលើនេះ ទៅប្រមុខរដ្ឋស្តីទីចុះហត្ថលេខាជំនួសដោយព្រះរាជសារប្រគល់សិទ្ធិ ។

**មាត្រា ២៩.- ថ្មី**

ព្រះមហាក្សត្រទ្រង់បង្កើត និងប្រទានគ្រឿងឥស្សរិយយសជាតិ ។

ព្រះមហាក្សត្រ ទ្រង់សំរេចប្រទានឋានន្តរសក្តិ ឋានៈ យោធា និងស៊ីវិលតាមច្បាប់កំណត់ ។

**មាត្រា ៣០.- ថ្មី**

ក្នុងរយៈពេលព្រះមហាក្សត្រ ទ្រង់អវត្តមាន ប្រធានព្រឹទ្ធសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភាពុំមានលទ្ធភាពបំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទីជំនួសព្រះមហាក្សត្រ ពេលព្រះអង្គទ្រង់អវត្តមាន ការទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ត្រូវអនុវត្តតាមវាក្យខ័ណ្ឌទី ២ និងទី ៣នៃមាត្រា ១១ថ្មី ។

## ជំពូកទី ៣
## អំពី សិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ

**មាត្រា ៣១.-**

ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញ នៃអង្គការសហប្រជាជាតិ សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ ។

ប្រជាពលរដ្ឋខ្មែរ មានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់ ។

**មាត្រា ៣២.-**

ជនគ្រប់រូប មានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន ។

ទោសប្រហារជីវិតមិនត្រូវឱ្យមានឡើយ ។

**មាត្រា ៣៣.-**

ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក ។

ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅឯបរទេសត្រូវបានរដ្ឋគាំពារ ។

ការទទួលសញ្ជាតិខ្មែរត្រូវកំណត់ក្នុងច្បាប់ ។

**មាត្រា ៣៤.- ថ្មី**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ១៨ ឆ្នាំ មានសិទ្ធិបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ២៥ ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ៤០ ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា ។

បទប្បញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត ត្រូវចែងក្នុងច្បាប់បោះឆ្នោត ។

**មាត្រា ៣៥.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

របស់ប្រទេសជាតិ ។

សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ ពីអង្គការរដ្ឋ ។

**មាត្រា ៣៦.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរ សមស្របតាមសមត្ថភាពរបស់ខ្លួន តាមសេចក្តីត្រូវការរបស់សង្គម ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា។

ការងារមេផ្ទះមានតម្លៃស្មើគ្នានឹងកំរៃដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលការធានារ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ច ដែលមានចែងក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីពនេះ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃសហជីពនឹងមានកំណត់ក្នុងច្បាប់ ។

**មាត្រា ៣៧.-**

សិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្មដោយសន្តិវិធី ត្រូវយកមកអនុវត្តនៅក្នុងក្របខ័ណ្ឌនៃច្បាប់ ។

**មាត្រា ៣៨.-**

ច្បាប់រ៉ាប់រង មិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ ។

ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ នឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។

ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តិកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារត្រូវហាមឃាត់មិនធ្វើឡើយ ។ អ្នកដែលដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិតត្រូវទទួលទោសតាមច្បាប់ ។

ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំ តាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធ-ភាពទេ ។

វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ។

ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ ។

**មាត្រា ៣៩.-**

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើខុស

ច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ ។ ការដោះស្រាយបណ្ដឹងតវ៉ា និងសំណង ជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ ។

**មាត្រា ៤០.-**

សេរីភាពក្នុងការដើរឆ្ងាយជិត និងតាំងទីលំនៅក្នុងស្ថានភាពស្របច្បាប់ របស់ប្រជាពលរដ្ឋត្រូវបានគោរព ។

ប្រជាពលរដ្ឋខ្មែរអាចចេញទៅតាំងទីលំនៅ នៅប្រទេសក្រៅ ឬវិលត្រឡប់មកវិញបាន។

ការរក្សាសិទ្ធិមិនឱ្យរំលោភលើលំនៅឋាន និងអាថ៌កំបាំងនៃការឆ្លើយឆ្លងតាមលិខិត តាមសារទូរលេខ ទូរពុម្ព ទូរគមនី និងតាមទូរស័ព្ទត្រូវបានធានា ។

ការឆែកឆេរលំនៅឋាន សម្ភារៈវត្ថុ និងលើរូបបុគ្គលត្រូវធ្វើឱ្យស្របនឹងបញ្ញត្តិច្បាប់ ។

**មាត្រា ៤១.-**

ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះ ដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទំលាប់ល្អរបស់សង្គម ដល់សណ្ដាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ ។

របបសារព័ត៌មាន ត្រូវរៀបចំឡើងដោយច្បាប់ ។

**មាត្រា ៤២.-**

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងឡាយ អាចចូលរួមក្នុងអង្គការមហាជនជួយគ្នាទៅវិញទៅមក ការពារសមិទ្ធផលជាតិ និងសណ្ដាប់ធ្នាប់សង្គម ។

**មាត្រា ៤៣.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិពេញទីខាងជំនឿ ។

សេរីភាពខាងជំនឿ និងការប្រតិបត្តិខាងផ្លូវសាសនាត្រូវបានរដ្ឋធានា ក្នុងលក្ខខណ្ឌដែលមិនប៉ះពាល់ដល់ជំនឿ ឬសាសនាដទៃទៀត ដល់សណ្ដាប់ធ្នាប់ និងសន្តិសុខសាធារណៈ ។

ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។

**មាត្រា ៤៤.-**

ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី ។

កម្មសិទ្ធិឯកជនស្របច្បាប់ ឋិតនៅក្រោមការគាំពារនៃច្បាប់ ។

ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឱ្យធ្វើ ក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌ ។

**មាត្រា ៤៥.-**

ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រីភេទ ត្រូវបំបាត់ចោល ។

ការធ្វើអាជីវកម្មលើការងាររបស់ស្ត្រីត្រូវហាមឃាត់ ។

បុរស និងស្ត្រី មានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ ។

អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមលក្ខខណ្ឌ ដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្ដីមួយប្រពន្ធមួយ ។

**មាត្រា ៤៦.-**

អំពើលក់ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និងអំពើអាសអាភាស ដែលប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់នារីត្រូវហាមឃាត់ ។

ត្រូវហាមឃាត់មិនឱ្យមានការបញ្ឈប់នារីពីការងារ ដោយមូលហេតុមានគភ៌ ។ នារីមានសិទ្ធិឈប់សំរាកនៅពេលសម្រាលកូន ដោយទទួលប្រាក់បៀវត្ស និងដោយមានការធានារក្សាសិទ្ធិអតីតភាពក្នុងការងារ និងអត្ថប្រយោជន៍សង្គមផ្សេងៗទៀត ។

រដ្ឋ និងសង្គមយកចិត្តទុកដាក់បង្កលក្ខណៈឱ្យនារី ជាពិសេសនារីនៅជនបទដែលគ្មានទីពឹង បានទទួលការឧបត្ថម្ភ ដើម្បីមានមុខរបរ មានលទ្ធភាពព្យាបាលជំងឺ ឱ្យកូនទៅរៀន និងមានជីវភាពរស់នៅសមរម្យ ។

**មាត្រា ៤៧.-**

មាតាបិតា មានកាតព្វកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូនឱ្យទៅជាពលរដ្ឋល្អ ។

កូនមានករណីយកិច្ចចិញ្ចឹម និងបីបាច់ថែរក្សាមាតាបិតា ដែលចាស់ជរាតាមទំនៀមទំលាប់ខ្មែរ ។

**មាត្រា ៤៨.-**

រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្ដីពីកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវ-កម្មសេដ្ឋកិច្ច ឬកាមគុណលើកុមារ ។

រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ ។

**មាត្រា ៤៩.-**

ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់ ។

ប្រជាពលរដ្ឋខ្មែរគ្រប់រូប មានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិ ។

កាតព្វកិច្ចការពារមាតុភូមិត្រូវអនុវត្តតាមបញ្ញត្តិច្បាប់ ។

**មាត្រា ៥០.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ត្រូវគោរពគោលការណ៍អធិបតេយ្យជាតិ និងលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ត្រូវគោរពទ្រព្យសម្បត្តិសាធារណៈ និងកម្មសិទ្ធស្របច្បាប់របស់ឯកជន ។

## ជំពូកទី៤

## អំពី របបនយោបាយ

### មាត្រា ៥១.- ថ្មី

ព្រះរាជាណាចក្រកម្ពុជា អនុវត្តនយោបាយប្រជាធិបតេយ្យ សេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។

អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួន តាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជំរះក្តី ។

អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។

### មាត្រា ៥២.-

រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញារក្សាការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា អនុវត្តនយោបាយបង្រួបបង្រួមជាតិ ដើម្បីការពារឯកភាពជាតិ រក្សាការពារទំនៀមទំលាប់ និងប្រពៃណីល្អរបស់ជាតិ ។ រាជរដ្ឋាភិបាលកម្ពុជា ត្រូវការពារនីត្យានុកូលភាព ធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ ។ រដ្ឋយកចិត្តទុកដាក់ជាអាទិភាពចំពោះជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ ។

### មាត្រា ៥៣.-

ព្រះរាជាណាចក្រកម្ពុជា ប្រកាន់ខ្ជាប់ជានិច្ច នូវនយោបាយអព្យាក្រឹតអចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ ។ ព្រះរាជាណាចក្រកម្ពុជា រួមរស់ដោយសន្តិសហវិជ្ជមានជាមួយប្រទេសជិតខាង និងប្រទេសដទៃទៀតទាំងអស់ នៅលើសកលលោក ។

ព្រះរាជាណាចក្រកម្ពុជា មិនឈ្លានពានប្រទេសណាដាច់ខាត មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃប្រទេសដទៃដោយផ្ទាល់ ឬដោយប្រយោល ទោះបីក្រោមរូបភាពណាក៏ដោយ ដោះស្រាយរាល់បញ្ហាដោយសន្តិវិធី និងគោរពផលប្រយោជន៍ផងគ្នាទៅវិញទៅមក ។

ព្រះរាជាណាចក្រកម្ពុជា មិនចងសម្ព័ន្ធយោធា ឬចូលក្នុងកិច្ចព្រមព្រៀងយោធាណាមួយដែលមិនស្របនឹងអព្យាក្រឹត្យភាពរបស់ខ្លួនឡើយ ។

ព្រះរាជាណាចក្រកម្ពុជា មិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធាបរទេសនៅលើទឹកដីរបស់ខ្លួន ហើយក៏មិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធារបស់ខ្លួននៅបរទេសដែរ លើកលែងតែក្នុងក្របខ័ណ្ឌនៃសំណូមពររបស់អង្គការសហប្រជាជាតិ ។

ព្រះរាជាណាចក្រកម្ពុជា រក្សាសិទ្ធិទទួលយកជំនួយបរទេសជាសម្ភារៈយោធា អាវុធ គ្រាប់រំសេវ ការហ្វឹកហ្វឺនកងកម្លាំងប្រដាប់អាវុធ និងជំនួយផ្សេងៗទៀត ដើម្បីការពារខ្លួន និងធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈនៅផ្ទៃក្នុងប្រទេស ។

### មាត្រា ៥៤.-

ការផលិត ការប្រើប្រាស់ ការរក្សាទុកអាវុធ បរមាណូ អាវុធគីមី ឬអាវុធវេគ្រាណូ ត្រូវហាមឃាត់ដាច់ខាត ។

**មាត្រា ៥៥.-**

សន្ធិសញ្ញា និង កិច្ចព្រមព្រៀងទាំងឡាយណា ដែលមិនសមស្របនឹងឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី អព្យាក្រឹតភាព និងឯកភាពជាតិរបស់ព្រះរាជាណាចក្រកម្ពុជាត្រូវលុបចោល ។

## ជំពូកទី៥
## អំពី សេដ្ឋកិច្ច

**មាត្រា ៥៦.-**

ព្រះរាជាណាចក្រកម្ពុជា អនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃប្រព័ន្ធសេដ្ឋកិច្ចនេះនឹងមានកំណត់ក្នុងច្បាប់ ។

**មាត្រា ៥៧.-**

ការយកពន្ធដារនឹងអាចធ្វើទៅបាន លុះត្រាតែមានច្បាប់អនុញ្ញាត ។ ថវិកាជាតិត្រូវបានកំណត់ឱ្យអនុវត្តតាមច្បាប់ ។

របបគ្រប់គ្រងរូបិយវត្ថុ និងប្រព័ន្ធហិរញ្ញវត្ថុ ត្រូវកំណត់ក្នុងច្បាប់ ។

**មាត្រា ៥៨.-**

ទ្រព្យសម្បត្តិរបស់រដ្ឋមានជាអាទិ៍ ដីធ្លី ក្រោមដី ភ្នំ សមុទ្ទ បាតសមុទ្ទ ក្រោមបាតសមុទ្ទ ឆ្នេរសមុទ្ទ អាកាស កោះ ទន្លេ ព្រែក ស្ទឹង បឹង ព្រៃឈើ ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ចវប្បធម៌ មូលដ្ឋានការពារប្រទេស សំណង់ផ្សេងៗទៀតដែលបានកំណត់ថា ជារបស់រដ្ឋ ។

ការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ នឹងត្រូវកំណត់ក្នុងច្បាប់ ។

**មាត្រា ៥៩.-**

រដ្ឋត្រូវរក្សាការពារបរិស្ថាន និងតុល្យភាពនៃភោគទ្រព្យធម្មជាតិ ហើយត្រូវចាត់ចែងឱ្យមានផែនការច្បាស់លាស់ក្នុងការគ្រប់គ្រង មានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភោគោត្តសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និងឧស្ម័ន ថ្ម និងខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆាជាតិ ធនធានជលផល ។

**មាត្រា ៦០.-**

ពលរដ្ឋមានសិទ្ធិលក់ដូរផលិតផលរបស់ខ្លួនដោយសេរី ។ ការតំរូវឱ្យលក់ផលិតផលជូនរដ្ឋ ឬការយកភោគផល ឬទ្រព្យសម្បត្តិឯកជនទៅប្រើប្រាស់ ទោះបីមួយរយៈពេលក៏ដោយ ត្រូវហាមឃាត់ វៀរលែងតែក្នុងករណីពិសេសដែលមានច្បាប់អនុញ្ញាត ។

**មាត្រា ៦១.-**

រដ្ឋជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រប់វិស័យ ជាពិសេសវិស័យកសិកម្ម សិប្បកម្ម ឧស្សាហកម្ម ចាប់តាំងពីតំបន់ដាច់-

ស្រយាល ដោយយកចិត្តទុកដាក់ទៅលើនយោបាយទឹក ភ្លើង ផ្លូវ និងមធ្យោបាយដឹកជញ្ជូន បច្ចេកទេសទំនើប និងប្រព័ន្ធឥណទាន ។

**មាត្រា ៦២.-**

រដ្ឋយកចិត្តទុកដាក់ ជួយដោះស្រាយមធ្យោបាយផលិត ការពារថ្លៃផលិតផល ជូនកសិករ សិប្បករ និងជួយរកទីផ្សារលក់ផលិតផល ។

**មាត្រា ៦៣.-**

រដ្ឋយកចិត្តទុកដាក់ គ្រប់គ្រងទីផ្សារ ជួយឱ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ មានកម្រិតសមរម្យ ។

**មាត្រា ៦៤.-**

រដ្ឋហាមឃាត់ និងផ្ដន្ទាទោសជាទម្ងន់ដល់ជនណាដែលនាំចូលផលិតផល លក់ដូរ គ្រឿងញៀន ទំនិញក្លែងក្លាយ ហួសរយៈពេលប្រើ ដែលប៉ះពាល់ដល់សុខភាព អាយុជីវិតរបស់អ្នកប្រើ ។

## **ជំពូកទី៦**
## **អំពី អប់រំ វប្បធម៌ និងសង្គមកិច្ច**

**មាត្រា ៦៥.-**

រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលការអប់រំ ប្រកបដោយគុណភាពនៅគ្រប់កំរិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗ ដើម្បីឱ្យការអប់រំនេះ បានទៅដល់ប្រជាពលរដ្ឋគ្រប់រូប ។

រដ្ឋយកចិត្តទុកដាក់ ដល់វិស័យអប់រំកាយ និងកីឡា ដែលជាសុខុមាលភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ។

**មាត្រា ៦៦.-**

រដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញ និងឯកភាពនៅទូទាំងប្រទេស ដែលធានាឱ្យបាននូវគោលការណ៍សេរីភាពខាងសិក្សាធិការ និងគោលការណ៍សមភាពក្នុងការអប់រំ ដើម្បីអោយប្រជាពលរដ្ឋគ្រប់រូប មានភ័ព្វសំណាងគ្រប់គ្រាន់ ស្មើគ្នាក្នុងការកសាងជីវិត ។

**មាត្រា ៦៧.-**

រដ្ឋអនុវត្តកម្មវិធីសិក្សា និងគោលការណ៍គរុកោសល្យទំនើប រាប់បញ្ចូលទាំងបច្ចេកវិទ្យា និងភាសាបរទេស ។

រដ្ឋគ្រប់គ្រងគ្រឹះស្ថានសិក្សា និងថ្នាក់សិក្សាសាធារណៈ និងឯកជននៅគ្រប់ភូមិសិក្សា ។

**មាត្រា ៦៨.-**

រដ្ឋផ្ដល់កិច្ចការអប់រំផ្នែកបឋម និងមធ្យមសិក្សានៅសាលារៀនសាធារណៈសំរាប់ប្រជាពលរដ្ឋគ្រប់រូប ដោយឥតបង់ថ្លៃ ។

ប្រជាពលរដ្ឋត្រូវបានទទួលការអប់រំយ៉ាងតិចប្រាំបួនឆ្នាំ ។

រដ្ឋជួយផ្សព្វផ្សាយ និងលើកតំកើងសាលាបាលី និងពុទ្ធិកសិក្សា ។

**មាត្រា ៦៩.-**

រដ្ឋមានកាតព្វកិច្ចថែរក្សា និង ពង្រីកវប្បធម៌ជាតិ ។

រដ្ឋមានកាតព្វកិច្ចការពារ និងពង្រីកភាសាខ្មែរឱ្យសមស្រប នឹងសេចក្តីត្រូវការ ។

រដ្ឋមានកាតព្វកិច្ចថែរក្សា និងការពារប្រាសាទបុរាណ វត្ថុសិល្បៈបុរាណ និងកែលំអរមណីដ្ឋានប្រវត្តិសាស្ត្រឡើងវិញ ។

**មាត្រា ៧០.-**

បទល្មើសទាំងឡាយដែលប៉ះពាល់ ឬ ទាក់ទងនឹងបេតិកភ័ណ្ឌវប្បធម៌ និងបេតិកភ័ណ្ឌសិល្បៈ ត្រូវផ្តន្ទាទោសជាទម្ងន់ ។

**មាត្រា ៧១.-**

បរិវេណបេតិកភ័ណ្ឌជាតិ ក៏ដូចជាបេតិកភ័ណ្ឌដែលបានបញ្ចូលជាបេតិកភ័ណ្ឌពិភពលោក ត្រូវទុកជាតំបន់អព្យាក្រឹតដែលមិនឱ្យមានសកម្មភាពយោធា ។

**មាត្រា ៧២.-**

សុខភាពរបស់ប្រជារាស្ត្រត្រូវបានធានា ។ រដ្ឋយកចិត្តទុកដាក់ដល់ការការពារជម្ងឺ និងព្យាបាលជម្ងឺ ។ ប្រជារាស្ត្រក្រីក្រត្រូវបានទទួលការពិនិត្យរោគ ដោយឥតបង់ថ្លៃនៅតាម មន្ទីរពេទ្យ គិលានដ្ឋាន និងមន្ទីរសម្ភពសាធារណៈ ។

រដ្ឋរៀបចំឱ្យមានគិលានដ្ឋាន និងមន្ទីរសម្ភពដល់ជនបទ ។

**មាត្រា ៧៣.-**

រដ្ឋយកចិត្តទុកដាក់ចំពោះកុមារ និងមាតា ។ រដ្ឋរៀបចំឱ្យមានទារកដ្ឋាន និងជួយឧបត្ថម្ភនារីដែលមានកូនច្រើនក្នុងបន្ទុកហើយឥតទីពឹង ។

**មាត្រា ៧៤.-**

រដ្ឋជួយឧបត្ថម្ភជនពិការ និងដល់គ្រួសារយុទ្ធជន ដែលបានបូជាជីវិតដើម្បីប្រទេសជាតិ ។

**មាត្រា ៧៥.-**

រដ្ឋចាត់ចែងឱ្យមានរបបសន្តិសុខសង្គម ដល់កម្មករ និងនិយោជិត ។

# ជំពូកទី ៧
## អំពី រដ្ឋសភា

**មាត្រា ៧៦.-**

រដ្ឋសភាមានសមាជិកជាតំណាងរាស្ត្រយ៉ាងតិច ១២០រូប ។

តំណាងរាស្ត្រត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

តំណាងរាស្ត្រអាចឈរឈ្មោះបោះឆ្នោតសាជាថ្មីបាន ។

អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ គឺប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ២៥ឆ្នាំ មានសញ្ជាតិជាខ្មែរតាំងពីកំណើត ។

អង្គការរៀបចំការបោះឆ្នោត បែបបទ និងការប្រព្រឹត្តទៅនៃការបោះឆ្នោត ត្រូវកំណត់ក្នុងច្បាប់បោះឆ្នោត ។

**មាត្រា ៧៧.-**

តំណាងរាស្ត្រក្នុងរដ្ឋសភា ជាតំណាងប្រជាជាតិខ្មែរទាំងមូលពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋ ក្នុងមណ្ឌលរបស់ខ្លួននោះទេ ។

អាណត្តិអាជ្ញាបញ្ជាទាំងឡាយ ត្រូវទុកជាមោឃៈ ។

**មាត្រា ៧៨.-**

នីតិកាលរបស់រដ្ឋសភាមានកំណត់ ៥ ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលរដ្ឋសភាថ្មីចូលកាន់តំណែង ។ រដ្ឋសភាមិនអាចត្រូវបានរំលាយមុនផុតអាណត្តិបានឡើយ វៀរលែងតែក្នុងករណីដែលរាជរដ្ឋាភិបាល ត្រូវបានទម្លាក់ពីរដងក្នុងរយៈពេល ១២ ខែ ។

ក្នុងករណីនេះ ព្រះមហាក្សត្រត្រូវរំលាយរដ្ឋសភា ក្រោយពីព្រះអង្គទ្រង់បានទទួលការស្នើពីនាយករដ្ឋមន្ត្រី និងបន្ទាប់ពីទ្រង់បានការយល់ព្រមពីប្រធានរដ្ឋសភា ។

ការបោះឆ្នោតដើម្បីជ្រើសរើសរដ្ឋសភាថ្មីនឹងប្រព្រឹត្តទៅក្នុងរយៈពេល ៦០ថ្ងៃយ៉ាងយូរ ចាប់តាំងពីថ្ងៃរំលាយរដ្ឋសភាមក ។

ក្នុងរយៈកាលនេះ រាជរដ្ឋាភិបាលមានតែភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ ។

ក្នុងពេលមានសង្គ្រាម ឬក្នុងកាលៈទេសៈពិសេសដទៃទៀត ដែលមិនអាចធ្វើការបោះឆ្នោតកើត រដ្ឋសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួន មួយដងបានមួយឆ្នាំ តាមសំណើរបស់ព្រះមហាក្សត្រ ។

ការប្រកាសបន្តនីតិកាលរបស់រដ្ឋសភា ត្រូវសំរេចដោយមតិយល់ព្រម ពីរភាគបីយ៉ាងតិច នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ៧៩.-**

អាណត្តិនៃសមាជិករដ្ឋសភា មានវិសមតិភាពជាមួយការបំពេញមុខងារសាធារណៈជាសកម្ម និងជាមួយមុខងារជាសមាជិកនៃស្ថាប័នដទៃទៀត ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ វៀរលែងតែទៅបំពេញមុខងារក្នុងគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល ។

ក្នុងករណីនេះ សមាជិករដ្ឋសភារូបនោះ មានឋានៈជាសមាជិករដ្ឋសភាធម្មតា ប៉ុន្តែមិនត្រូវមានមុខតំណែងអ្វីទាំងអស់ ក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ និងក្នុងគណៈកម្មការផ្សេងៗនៃរដ្ឋសភា ។

**មាត្រា ៨០.-**

តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា ។

តំណាងរាស្ត្ររូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិ ក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនសមាជិកណាមួយនៃរដ្ឋសភានឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទ័ណ្ឌជាក់ស្តែង ។ ក្នុងករណីខាងក្រោយនេះ ក្រសួងមានសមត្ថកិច្ច ត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាជាបន្ទាន់ដើម្បីសំរេច ។

សេចក្តីសំរេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើន ពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល ។

ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់តំណាងរាស្ត្រណាមួយត្រូវផ្អាក ប្រសិនបើ រដ្ឋសភាបានបញ្ចេញមតិអោយផ្អាក តាមមតិភាគច្រើន បីភាគបួន នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ៨១.-**

រដ្ឋសភាមានថវិកាស្វយ័ត សំរាប់ដំណើរការ ។

តំណាងរាស្ត្រត្រូវទទួលប្រាក់បំណាច់ ។

**មាត្រា ៨២.-**

រដ្ឋសភាបើកសម័យប្រជុំដំបូងហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោតតាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្តើមការងាររបស់ខ្លួន រដ្ឋសភាត្រូវអនុម័តបទបញ្ជាផ្ទៃក្នុង សំរេចអំពីសុពលភាពនៃអាណត្តិ របស់សមាជិកនិមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវ ប្រធាន អនុប្រធានរដ្ឋសភា និង សមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើន ពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល ។

តំណាងរាស្ត្រទាំងអស់ត្រូវធ្វើសច្ចាប្រណិធាន មុនចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធ ៥ ។

**មាត្រា ៨៣.-**

រដ្ឋសភាប្រជុំជាសាមញ្ញ ពីរដងក្នុងមួយឆ្នាំ ។

សម័យប្រជុំនិមួយៗ មានថេរៈវេលាយ៉ាងតិចបីខែ ។ បើមានសំណូមពរពីព្រះមហាក្សត្រ ឬសេចក្តីស្នើសុំពី នាយករដ្ឋមន្ត្រី ឬពីសមាជិករដ្ឋសភាចំនួនមួយភាគបីយ៉ាងតិច គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាកោះប្រជុំរដ្ឋសភាជាវិសាមញ្ញ ។

ក្នុងករណីនេះ របៀបវារៈជាក់លាក់នៃសម័យប្រជុំវិសាមញ្ញ ត្រូវផ្សាយដល់ប្រជារាស្ត្រ ជាមួយនឹងថ្ងៃកំណត់ប្រជុំ ។

**មាត្រា ៨៤.-**

នៅចន្លោះសម័យប្រជុំរបស់រដ្ឋសភា គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ទទួលភារកិច្ចចាត់ចែងការងារ ។

គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភារួមមាន : ប្រធានរដ្ឋសភា អនុប្រធានរដ្ឋសភា និងប្រធានគណៈកម្មការទាំងអស់របស់រដ្ឋសភា ។

**មាត្រា ៨៥.-**

សម័យប្រជុំរដ្ឋសភាត្រូវធ្វើនៅរាជធានីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងសាលប្រជុំរបស់រដ្ឋសភា លើកលែងតែមានការសំរេចផ្សេង ចុះក្នុងលិខិតកោះប្រជុំ ដោយកាលៈទេសៈតម្រូវ ។

ក្រៅពីករណីខាងលើ និងក្រៅពីកន្លែង និងពីកាលបរិច្ឆេទ ដែលកំណត់ក្នុងសេចក្តីអញ្ជើញ ការប្រជុំណាក៏ដោយរបស់រដ្ឋសភាត្រូវទុកជាខុសច្បាប់ ហើយជាអសារសូន្យពេញលក្ខណៈ ។

**មាត្រា ៨៦.-**

ក្នុងកាលៈទេសៈដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន រដ្ឋសភាប្រជុំរាល់ថ្ងៃជាប់ជាប្រចាំ ។ រដ្ឋសភាមានសិទ្ធិសំរេចបញ្ចប់កាលៈទេសៈពិសេសខាងលើនេះ កាលបើសភាពការណ៍អនុញ្ញាត ។

បើរដ្ឋសភាមិនអាចប្រជុំបានទេ ដោយមូលហេតុចាំបាច់ ជាអាទិ៍នៅពេលដែលកំលាំងបរទេស ចូលមកកាន់កាប់ទឹកដី ការប្រកាសភាពអាសន្នត្រូវបន្តទៅមុខជាស្វ័យប្រវត្តិ ។

នៅពេលដែលប្រទេសជាតិឋិតក្នុងភាពអាសន្ន រដ្ឋសភាមិនអាចត្រូវរំលាយបានឡើយ ។

**មាត្រា ៨៧.-**

ប្រធានរដ្ឋសភាដឹកនាំអង្គប្រជុំរបស់ រដ្ឋសភាទទួលអាញ្ញត្តិច្បាប់ និងសេចក្តីសំរេចចិត្តទាំងឡាយ ដែលរដ្ឋសភាបានអនុម័តរ៉ាប់រងការអនុវត្តន៏បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា និងចាត់ចែងការទាក់ទងអន្តរជាតិទាំងឡាយរបស់រដ្ឋសភា ។

ក្នុងករណីដែលប្រធានរដ្ឋសភាមានធុរៈ មិនអាចបំពេញមុខងារបានដោយហេតុមកពីជម្ងឺ ឬបំពេញមុខងារជាប្រមុខរដ្ឋស្តីទី ឬជាព្រះរាជានុសិទ្ធិ ឬបំពេញបេសកម្មនៅបរទេស អនុប្រធានរដ្ឋសភាមួយរូបត្រូវទទួលភារកិច្ច ចាត់ចែងការងារជំនួស ។

ក្នុងករណីដែលប្រធាន ឬអនុប្រធានរដ្ឋសភាលាលែងពីមុខតំណែង ឬទទួលអនិច្ចកម្ម រដ្ឋសភាត្រូវបោះឆ្នោតជ្រើសតាំង ប្រធាន ឬអនុប្រធានថ្មី ។

**មាត្រា ៨៨.-**

ការប្រជុំរដ្ឋសភា ត្រូវធ្វើជាសាធារណៈ ។

រដ្ឋសភាអាចប្រជុំជាសម្ងាត់បានតាមការសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ឬពីនាយករដ្ឋមន្ត្រី ។

ការប្រជុំរដ្ឋសភានឹងយកជាការបាន លុះត្រាតែមានកូរ៉ុមប្រាំពីរភាគដប់ នៃសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ៨៩.-**

តាមការសុំពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច រដ្ឋសភាអាចអញ្ជើញឥស្សរជនដ៏ឧត្តមណាមួយ មកបំភ្លឺរដ្ឋសភាអំពីបញ្ហាដែលមានសារៈសំខាន់ពិសេស ។

**មាត្រា ៩០.- ថ្មី**

រដ្ឋសភាជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។

រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានា ផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬ លុបចោលពន្ធដារ ។

រដ្ឋសភាឱ្យសេចក្ដីយល់ព្រមចំពោះគណនីរដ្ឋបាល ។

រដ្ឋសភាអនុម័តច្បាប់ ស្ដីពីការលើកលែងទោសជាទូទៅ ។

រដ្ឋអនុម័តយល់ព្រម ឬលុបចោល សន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ ។

រដ្ឋសភាអនុម័តច្បាប់ ស្ដីពីការប្រកាសសង្គ្រាម ។

ការអនុម័តខាងលើនេះ ប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាបោះឆ្នោតទុកចិត្ត ដល់រាជរដ្ឋាភិបាល តាមមតិភាគច្រើន ពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ៩១.- ថ្មី**

សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងនាយករដ្ឋមន្ត្រីមានសិទ្ធិផ្ដួចផ្ដើមគំនិតធ្វើច្បាប់ ។

តំណាងរាស្ត្រមានសិទ្ធិស្នើ ធ្វើវិសោធនកម្មច្បាប់ប៉ុន្តែសំណើនេះមិនអាចទទួលយកបានទេ បើវិសោធនកម្មនោះសំដៅ បន្ថយប្រាក់ចំនូលសាធារណៈ ឬបន្ថែមបន្ទុកលើប្រជាពលរដ្ឋ ។

**មាត្រា ៩២.-**

ការអនុម័តទាំងឡាយរបស់រដ្ឋសភា ដែលផ្ទុយនឹងគោលការណ៍ រក្សាការពារ ឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំឱ្យប៉ះពាល់ដល់ឯកភាពនយោបាយ ឬការគ្រប់គ្រងរដ្ឋបាល របស់ប្រទេសជាតិនឹងត្រូវចាត់ទុកជាអាសារសូន្យ ។ ក្រុមប្រឹក្សាធម្មនុញ្ញ ជាអង្គការតែមួយគត់ដែលមានសមត្ថកិច្ចសំរេចមោឃភាពនេះ ។

**មាត្រា ៩៣.~ ថ្មី**

ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ ហើយត្រូវបានព្រះមហាក្សត្រទ្រង់ឡាយព្រះហស្ថលេខាប្រកាសអោយប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញក្នុងរយៈពេលដប់ថ្ងៃគត់ ក្រោយពីថ្ងៃប្រ-កាសឱ្យប្រើ និងនៅទូទាំងប្រទេសក្នុងរយៈពេលម្ភៃថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសឱ្យប្រើ ។ ប៉ុន្តែបើច្បាប់នេះ បានចែងថាជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេស ក្រោយថ្ងៃប្រកាសអោយប្រើ ។

ច្បាប់ដែលព្រះមហាក្សត្រ ទ្រង់បានឡាយព្រះហស្ថលេខា ប្រកាសអោយប្រើ ត្រូវចុះក្នុងរាជកិច្ច និងផ្សព្វផ្សាយនៅទូទាំងប្រទេសឱ្យទាន់តាមពេលកំណត់ខាងលើ ។

**មាត្រា ៩៤.~**

រដ្ឋសភាបង្កើត គណៈកម្មការផ្សេងៗដែលចាំបាច់ ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋសភានឹងមានកំនត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ។

**មាត្រា ៩៥.~**

ក្នុងករណីមានសមាជិករដ្ឋសភាទទួល អនិច្ចកម្ម លាលែង ឬប្រាសចាកសមាជិកភាព ដែលកើតមានឡើង ៦ខែយ៉ាងតិចមុនចប់នីតិកាល ត្រូវចាត់ការជ្រើសតាំងជំនួសសមាជិកនោះ តាមលក្ខខណ្ឌកំណត់ ក្នុងបទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងក្នុងច្បាប់បោះឆ្នោត ។

**មាត្រា ៩៦.~**

តំណាងរាស្ត្រ មានសិទ្ធិដាក់សំណួរដល់រាជរដ្ឋាភិបាល ។ សំណួរនេះ ត្រូវសរសេរជាលាយល័ក្ខអក្សរ ប្រគល់ជូនតាមរយៈប្រធានរដ្ឋសភា ។

ចម្លើយអាចធ្វើឡើងដោយរដ្ឋមន្ត្រីមួយរូប ឬច្រើនរូប អាស្រ័យដោយបញ្ហាដែលបានចោទឡើង ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់រដ្ឋមន្ត្រីមួយរូប ឬច្រើនរូប ។ បើបញ្ហាពាក់ព័ន្ធដល់នយោបាយទូទៅរបស់រាជរដ្ឋាភិបាល នាយករដ្ឋមន្ត្រីត្រូវឆ្លើយផ្ទាល់ខ្លួន ។

ចម្លើយរបស់រដ្ឋមន្ត្រី ឬរបស់នាយករដ្ឋមន្ត្រី អាចធ្វើដោយផ្ទាល់មាត់ ឬសរសេរជាលាយល័ក្ខអក្សរ ។

ចម្លើយខាងលើនេះ ត្រូវធ្វើឡើងក្នុងពេលប្រាំពីរថ្ងៃ បន្ទាប់ពីបានទទួលសំណួរ ។

ចំពោះចម្លើយផ្ទាល់មាត់ ប្រធានរដ្ឋសភាអាចសំរេច បើកឱ្យមាន ឬមិនឱ្យមានការជជែកដេញដោល ។ បើគ្មានការបើកឱ្យជជែកដេញដោលទេ នោះចម្លើយរបស់រដ្ឋមន្ត្រី ឬរបស់នាយករដ្ឋមន្ត្រីនឹងបញ្ចប់សំណួរតែម្តង ។

បើមានការបើកឱ្យជជែកដេញដោល ម្ចាស់សំណួរ វាគ្មិនឯទៀត និងរដ្ឋមន្ត្រីពាក់ព័ន្ធ ឬនាយករដ្ឋមន្ត្រីអាចជជែកប្តូរយោបល់ ក្នុងរយៈពេលដែលមិនអាចលើសពីមួយពេលប្រជុំឡើយ ។

រដ្ឋសភាកំណត់ទុកពេលមួយថ្ងៃ ក្នុងមួយសប្តាហ៍ សម្រាប់ការឆ្លើយសំណួរ ។

ទោះបីជាយ៉ាងណាក៏ដោយ សម័យប្រជុំ សំរាប់ឆ្លើយសំណួរខាងលើនេះ មិនអាចបើកលទ្ធភាពឱ្យមានការបោះឆ្នោតប្រភេទណាមួយបានឡើយ ។

**មាត្រា ៩៧.-**

គណៈកម្មការទាំងឡាយរបស់រដ្ឋសភា អាចអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺ អំពីបញ្ហាអ្វីមួយដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់ខ្លួន ។

**មាត្រា ៩៨.-**

រដ្ឋសភា អាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលពីតំណែង ដោយអនុម័តញត្តិបន្ទោសតាមសម្លេងឆ្នោតពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវបានលើកឡើងជូនរដ្ឋសភា ដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន ។

## ជំពូកទី ៨
## អំពី ព្រឹទ្ធសភា

**មាត្រា ៩៩.- ថ្មី**

ព្រឹទ្ធសភាជាអង្គការដែលមានអំនាចនីតិប្បញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួន ដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។

ព្រឹទ្ធសភាមានចំនួនសមាជិកយ៉ាងច្រើន ស្មើនិងពាក់កណ្តាល នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

សមាជិកព្រឹទ្ធសភាត្រូវចាត់តាំងខ្លះ និងត្រូវជ្រើសតាំងដោយការបោះឆ្នោតអសកលខ្លះ ។

សមាជិកព្រឹទ្ធសភា អាចត្រូវបានចាត់តាំង និងជ្រើសតាំងសាជាថ្មីបាន ។ អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនព្រឹទ្ធសភា គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ៤០ ឆ្នាំ មានសញ្ជាតិខ្មែរតាំងពីកំណើត ។

**មាត្រា ១០០.- ថ្មី**

សមាជិកព្រឹទ្ធសភាចំនួន ២ រូប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ ។

សមាជិកព្រឹទ្ធសភាចំនួន ២ រូប ត្រូវបានរដ្ឋសភាជ្រើសតាំងតាមមតិភាគច្រើនដោយប្រៀប ។

រីឯសមាជិកព្រឹទ្ធសភាឯទៀត ត្រូវបានជ្រើសតាំងដោយការបោះឆ្នោតអសកល ។

**មាត្រា ១០១.- ថ្មី**

ការរៀបចំបែបបទ និងការប្រព្រឹត្តទៅ នៃការចាត់តាំង និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ព្រមទាំងការកំណត់អំពីអ្នកបោះឆ្នោត អង្គបោះឆ្នោត និងមណ្ឌលបោះឆ្នោត ត្រូវចែងក្នុងច្បាប់មួយ ។

**មាត្រា ១០២.- ថ្មី**

នីតិកាលរបស់ព្រឹទ្ធសភាមានកំណត់ ៦ ឆ្នាំ ហើយត្រូវផុតកំណត់ នៅពេលដែលព្រឹទ្ធសភាថ្មីចូលកាន់តំណែង។

ក្នុងពេលមានសង្គ្រាម ឬក្នុងកាលៈទេសៈពិសេសដទៃទៀត ដែលមិនអាចធ្វើការបោះឆ្នោតកើត ព្រឹទ្ធសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនមួយដងបានមួយឆ្នាំ តាមសំណើរបស់ព្រះមហាក្សត្រ ។

ការប្រកាសបន្តនីតិកាលរបស់ព្រឹទ្ធសភាត្រូវសំរេចដោយមតិយល់ព្រមពីរភាគបីយ៉ាងតិចនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ក្នុងកាលៈទេសៈដូចបានរៀបរាប់ខាងលើ ព្រឹទ្ធសភាប្រជុំរាល់ថ្ងៃជាប់ជាប្រចាំ ។ ព្រឹទ្ធសភាមានសិទ្ធិសំរេចបញ្ចប់កាលៈទេសៈពិសេសខាងលើនេះ កាលបើសភាពការណ៍អនុញ្ញាត ។

បើព្រឹទ្ធសភាមិនអាចប្រជុំបានទេ ដោយមូលហេតុចាំបាច់ ជាអាទិ៍នៅពេលដែលកម្លាំងបរទេសចូលមកកាន់កាប់ទឹកដី ការប្រកាសភាពអាសន្នត្រូវបន្តទៅមុខជាស្វ័យប្រវត្តិ ។

**មាត្រា ១០៣.- ថ្មី**

អាណត្តិនៃសមាជិកព្រឹទ្ធសភាមាន វិសមិតភាពជាមួយការបំពេញមុខងារសាធារណៈជាសកម្មជាមួយមុខងារជាតំណាងរាស្ត្រ និងជាមួយមុខងារជាសមាជិកស្ថាប័នដទៃទៀត ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។

**មាត្រា ១០៤.- ថ្មី**

សមាជិកព្រឹទ្ធសភាមានអភ័យឯកសិទ្ធិសភា ។

សមាជិកព្រឹទ្ធសភារូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ ។ ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួន សមាជិកណាមួយនៃព្រឹទ្ធសភា នឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីព្រឹទ្ធសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភា ក្នុងចន្លោះសម័យប្រជុំនៃព្រឹទ្ធសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង។ ក្នុងករណីចុងក្រោយនេះ ក្រសួងមានសមត្ថកិច្ច ត្រូវធ្វើសេចក្តីរាយការណ៍ជូនព្រឹទ្ធសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាជាបន្ទាន់ដើម្បីសំរេច ។

សេចក្តីសំរេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភា ត្រូវដាក់ជូនសម័យប្រជុំព្រឹទ្ធសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបីនៃសមាជិកព្រឹទ្ធសភាទាំងមូល ។

ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់សមាជិកព្រឹទ្ធសភាណាមួយត្រូវផ្អាក ប្រសិនបើ ព្រឹទ្ធសភា បានបញ្ចេញមតិឱ្យផ្អាកតាមមតិភាគច្រើន បីភាគបួន នៃសមាជិកព្រឹទ្ធសភាទាំងមូល ។

**មាត្រា ១០៥.- ថ្មី**

ព្រឹទ្ធសភាមានថវិកាស្វយ័តសំរាប់ដំណើរការ ។

សមាជិកព្រឹទ្ធសភាត្រូវទទួលប្រាក់បំណាច់ ។

**មាត្រា ១០៦.- ថ្មី**

ព្រឹទ្ធសភាបើកសម័យប្រជុំដំបូងហុកសិបថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោតតាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្តើមការងាររបស់ខ្លួន ព្រឹទ្ធសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន អនុប្រធានព្រឹទ្ធសភា និងសមាជិកទាំងអស់ នៃគណៈកម្មការនានារបស់ព្រឹទ្ធសភាដោយមតិភាគច្រើនពីរភាគបីនៃសមាជិកព្រឹទ្ធសភាទាំងមូល ។

សមាជិកព្រឹទ្ធសភាទាំងអស់ត្រូវធ្វើសច្ចាប្រណិធាន មុនចូលកាន់តំណែងដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី ៧ នៃរដ្ឋធម្មនុញ្ញ ។

**មាត្រា ១០៧.~ ថ្មី**

ព្រឹទ្ធសភាប្រជុំជាសាមញ្ញពីរដងក្នុងមួយឆ្នាំ ។

សម័យប្រជុំនីមួយៗមានថិរៈវេលាយ៉ាងតិចបីខែ ។ បើមានសំណូមពរពីព្រះមហាក្សត្រ ឬសេចក្តីស្នើសុំពីនាយករដ្ឋមន្ត្រី ឬពីសមាជិកព្រឹទ្ធសភាចំនួនមួយភាគបីយ៉ាងតិចព្រឹទ្ធសភាកោះប្រជុំជាវិសាមញ្ញ ។

**មាត្រា ១០៨.~ ថ្មី**

នៅចន្លោះសម័យប្រជុំរបស់ព្រឹទ្ធសភា គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាទទួលភារកិច្ចចាត់ចែងការងារ ។

គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភារួមមានៈ ប្រធានព្រឹទ្ធសភា អនុប្រធានព្រឹទ្ធសភា និងប្រធានគណៈកម្មការ ទាំងអស់របស់ព្រឹទ្ធសភា ។

**មាត្រា ១០៩.~ ថ្មី**

សម័យប្រជុំព្រឹទ្ធសភាត្រូវធ្វើនៅរាជធានីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងសាលប្រជុំរបស់ព្រឹទ្ធសភា លើកលែងតែមានការសំរេចផ្សេងចុះក្នុងលិខិតកោះប្រជុំដោយកាលៈទេសៈតម្រូវ ។

ក្រៅពីករណីខាងលើ និងក្រៅពីកន្លែង និងកាលបរិច្ឆេទ ដែលកំណត់ក្នុងសេចក្តីអញ្ជើញ ការប្រជុំណាក៏ដោយរបស់ព្រឹទ្ធសភាត្រូវទុកជាខុសច្បាប់ ហើយអាសារសូន្យពេញលក្ខណៈ ។

**មាត្រា ១១០.~ ថ្មី**

ប្រធានព្រឹទ្ធសភាដឹកនាំអង្គប្រជុំរបស់ព្រឹទ្ធសភា ទទួលអាញត្តិច្បាប់ និងសេចក្តីសំរេចចិត្តទាំងឡាយ ដែលព្រឹទ្ធសភាបានអនុម័ត រ៉ាប់រងការអនុវត្តនីបទបញ្ញាផ្ទៃក្នុងរបស់ព្រឹទ្ធសភា និងចាត់ចែងកាទាក់ទងអន្តរជាតិទាំងឡាយរបស់ព្រឹទ្ធសភា ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភាមានធុរៈ មិនអាចបំពេញមុខងារបាន ដោយហេតុមកពីមានជម្ងឺ ឬបំពេញមុខងារជាប្រមុខរដ្ឋស្តីទី ឬជាព្រះរាជានុសិទ្ធិ ឬបំពេញបេសកម្មនៅបរទេស អនុប្រធានព្រឹទ្ធសភាមួយរូប ត្រូវទទួលភារកិច្ចចាត់ចែង ការងារជំនួស ។

ក្នុងករណីដែលប្រធាន ឬអនុប្រធានព្រឹទ្ធសភាលាលែងពីមុខតំណែង ឬទទួលអនិច្ចកម្ម ព្រឹទ្ធសភាត្រូវបោះឆ្នោតជ្រើសតាំងប្រធាន ឬអនុប្រធានថ្មី ។

**មាត្រា ១១១.~ ថ្មី**

ការប្រជុំព្រឹទ្ធសភាត្រូវធ្វើជាសាធារណៈ ។

ព្រឹទ្ធសភាអាចប្រជុំជាសម្ងាត់បានតាមការសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬពីប្រធានរដ្ឋសភា ។

ការប្រជុំព្រឹទ្ធសភានឹងយកជាការបាន លុះត្រាតែមានកូរ៉ុមប្រាំពីរភាគដប់ នៃសមាជិកព្រឹទ្ធសភាទាំងមូល ។

ចំនួនសម្លេងដែលតម្រូវសំរាប់រដ្ឋសភាអនុម័តយល់ព្រម ហើយដែលបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ត្រូវយកមកប្រើសំរាប់ព្រឹទ្ធសភាផងដែរ ។

**មាត្រា ១១២.~ ថ្មី**

ព្រឹទ្ធសភាមានភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភា និងរដ្ឋាភិបាល ។

**មាត្រា ១១៣.~ ថ្មី**

ព្រឹទ្ធសភាពិនិត្យហើយអោយយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរ លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមលើកដំបូងរួចហើយ ព្រមទាំងលើកបញ្ហាទាំងពួងដែលរដ្ឋសភាបានដាក់ឱ្យពិនិត្យ ។ បើជាការប្រញាប់រយៈពេលនោះត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ ។

បើព្រឹទ្ធសភាបានឱ្យយោបល់យល់ព្រម ឬពុំបានឱ្យយោបល់សោះ ក្នុងរយៈពេលដែលមានកំណត់ទុក ហើយនោះទេច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយនោះនឹងត្រូវបានយកទៅប្រកាសឱ្យប្រើ ។

បើព្រឹទ្ធសភា សុំអោយកែសំរួលសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះ រដ្ឋសភាត្រូវយកមកពិចារណាភ្លាមជាលើកទីពីរ ។ រដ្ឋសភាត្រូវពិនិត្យ និងសំរេចតែត្រង់បទប្បញ្ញត្តិ ឬចំនុចណាដែលព្រឹទ្ធសភាសុំឱ្យកែសំរួល ដោយបដិសេធចោលទាំងមូល ឬទុកជាបានការខ្លះ ។

ការបង្វិលទៅបង្វិលមករវាងព្រឹទ្ធសភា និងរដ្ឋសភា ត្រូវធ្វើតែក្នុងរយៈពេលមួយខែ ។ រយៈពេលនេះ ត្រូវបន្ថយមកត្រឹមដប់ថ្ងៃ បើត្រូវពិនិត្យសំរេចពីថវិកាជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែពីរថ្ងៃបើជាការប្រញាប់ ។

បើរដ្ឋសភាទុកឱ្យហួសរយៈពេលកំណត់ ឬពន្យារពេល ដែលកំណត់ទុកសំរាប់ពិនិត្យនោះ រយៈពេលជាគោលការណ៍សំរាប់រដ្ឋសភា និងព្រឹទ្ធសភា ត្រូវបន្ថែមអោយស្មើគ្នាដែរ ។

បើព្រឹទ្ធសភាបដិសេធសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះជាអសារបង់ រដ្ឋសភាមិនអាចនឹងយកមកពិចារណាជាលើកទីពីរបានមុនរយៈពេលមួយខែទេ ។ រយៈពេលនេះត្រូវបន្ថយមកត្រឹមដប់ប្រាំថ្ងៃ បើពិនិត្យពីថវិកាជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែបួនថ្ងៃបើជាការប្រញាប់ ។

ក្នុងការពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ជាលើកទី២នេះ រដ្ឋសភាត្រូវអនុម័តដោយវិធីបោះឆ្នោតចំហ និងយកតាមមតិភាគច្រើនដាច់ខាត ។

សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ណាដែលបានសំរេចដូចខាងលើនេះហើយនោះ នឹងត្រូវបានយកទៅប្រកាសឱ្យប្រើ ។

**មាត្រា ១១៤.~ ថ្មី**

ព្រឹទ្ធសភាបង្កើតគណៈកម្មការផ្សេងៗដែលចាំបាច់ ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃព្រឹទ្ធសភា នឹងមានកំណត់

ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា ។ បទបញ្ជាផ្ទៃក្នុងនេះ ត្រូវអនុម័តយល់ព្រមដោយសម្លេងភាគច្រើនពីរភាគបី នៃចំនួន សមាជិកព្រឹទ្ធសភាទាំងមូល ។

**មាត្រា ១១៥.~ ថ្មី**

ក្នុងករណីមានសមាជិកព្រឹទ្ធសភាទទួលអនិច្ចកម្ម លាលែង ឬប្រាសចាកសមាជិកភាព ដែលកើតមានឡើង ប្រាំមួយខែយ៉ាងតិច មុនចប់នីតិកាលត្រូវចាត់តាំង ឬជ្រើសតាំងជំនួសសមាជិកនោះ តាមលក្ខខណ្ឌកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា និងក្នុងច្បាប់ស្តីពីការចាត់តាំង និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

## ជំពូកទី ៩ ថ្មី

## អំពី សមាជរដ្ឋសភា និងព្រឹទ្ធសភា

**មាត្រា ១១៦.~ ថ្មី**

ក្នុងករណីចាំបាច់ រដ្ឋសភា និងព្រឹទ្ធសភា អាចប្រជុំរួមគ្នាជាសមាជ ដើម្បីដោះស្រាយបញ្ហាសំខាន់ៗរបស់ប្រទេសជាតិ ។

**មាត្រា ១១៧.~ ថ្មី**

បញ្ហាសំខាន់ៗរបស់ប្រទេសជាតិដូចមានចែងក្នុងមាត្រា ១១៦ថ្មី ខាងលើ ព្រមទាំងការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជនឹងត្រូវកំណត់ក្នុងច្បាប់មួយ ។

## ជំពូកទី ១០

## អំពី រាជរដ្ឋាភិបាល

**មាត្រា ១១៨.~ ថ្មី (មាត្រា ៩៩ ចាស់)**

គណៈរដ្ឋមន្ត្រី ជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

គណៈរដ្ឋមន្ត្រី ត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំងមានទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាសមាជិក ។

**មាត្រា ១១៩.~ ថ្មី (មាត្រា ១០០ ចាស់)**

តាមសេចក្តីស្នើពីប្រធាន ដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរៈជនមួយរូបក្នុងចំណោមតំណាងរាស្ត្រនៃគណបក្ស ដែលឈ្នះឆ្នោតអោយបង្កើតរាជរដ្ឋាភិបាល ។ វរៈជនដែលត្រូវបានចាត់តាំងនេះ នាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកគណបក្សតំណាងនៅក្នុងរដ្ឋសភា ដែលផ្គូរផ្គងអោយកាន់តំណែងផ្សេងៗ ក្នុងរាជរដ្ឋាភិបាលទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា ។ កាលបើរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយនោះ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹតតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល ។

មុនចូលកាន់តំណែង គណៈរដ្ឋមន្ត្រីត្រូវធ្វើ សច្ចាប្រណិធាន ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធ ៦ ។

**មាត្រា ១២០.- ថ្មី (មាត្រា ១០១ ចាស់)**

មុខងារនៃសមាជិករាជរដ្ឋាភិបាល មានវិសមិតភាព និងសកម្មភាពខាងវិជ្ជាជីវៈផ្នែកពាណិជ្ជកម្ម ឬឧស្សាហកម្ម ហើយ និងការកាន់តំណែងណាមួយក្នុងមុខងារសាធារណៈ ។

**មាត្រា ១២១.- ថ្មី (មាត្រា ១០២ ចាស់)**

សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាល ទទួលខុសត្រូវរួមគ្នាចំពោះរដ្ឋសភា អំពីនយោបាយទូទៅរបស់រាជរដ្ឋាភិបាល ។

សមាជិកមួយរូបៗ នៃរាជរដ្ឋាភិបាលទទួលខុសត្រូវរៀងខ្លួនចំពោះនាយករដ្ឋមន្ត្រី និងចំពោះរដ្ឋសភាអំពីការដែលខ្លួនបានប្រព្រឹត្ត ។

**មាត្រា ១២២.- ថ្មី (មាត្រា ១០៣ ចាស់)**

សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាល មិនអាចយកសំអាងនៃសេចក្តីបង្គាប់ ដោយលាយលក្ខណ៍អក្សរ ឬដោយវាចាអំពីនរណាមួយ ដើម្បីដោះសារឱ្យរួចខ្លួនពីការទទួលខុសត្រូវរបស់ខ្លួនបានឡើយ ។

**មាត្រា ១២៣.- ថ្មី (មាត្រា ១០៤ ចាស់)**

គណៈរដ្ឋមន្ត្រី ត្រូវប្រជុំរាល់សប្តាហ៍ ជាប្រជុំធំ ឬជាប្រជុំពិនិត្យស្រាវជ្រាវ ។

អង្គប្រជុំធំត្រូវដឹកនាំដោយនាយករដ្ឋមន្ត្រី ។ នាយករដ្ឋមន្ត្រីអាចប្រគល់ភារកិច្ចជូនឧបនាយករដ្ឋមន្ត្រីដឹកនាំអង្គប្រជុំពិនិត្យស្រាវជ្រាវបាន ។

កំណត់ហេតុនៃអង្គប្រជុំទាំងអស់ របស់គណៈរដ្ឋមន្ត្រី ត្រូវធ្វើថ្វាយព្រះមហាក្សត្រទ្រង់ជ្រាប ។

**មាត្រា ១២៤.- ថ្មី (មាត្រា ១០៥ ចាស់)**

នាយករដ្ឋមន្ត្រី អាចរំលែកអំណាចរបស់ខ្លួនអោយទៅឧបនាយករដ្ឋមន្ត្រី ឬសមាជិកណាមួយនៃរាជរដ្ឋាភិបាលបាន ។

**មាត្រា ១២៥.- ថ្មី (មាត្រា ១០៦ ចាស់)**

បើតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរនោះ ត្រូវតែងតាំងគណៈរដ្ឋមន្ត្រីមួយជាថ្មី ក្នុងល័ក្ខខ័ណ្ឌដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ ។ បើការទំនេរនេះជាការទំនេរមួយកាលមួយគ្រាទេ ត្រូវចាត់តាំងនាយករដ្ឋមន្ត្រីស្តីទីជាបណ្តោះអាសន្ន ។

**មាត្រា ១២៦.- ថ្មី (មាត្រា ១០៧ ចាស់)**

សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាល ត្រូវទទួលទណ្ឌកម្មពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលខ្លួនបានប្រព្រឹត្តក្នុងការបំពេញការងាររបស់ខ្លួន ។

ក្នុងករណីនេះ និងក្នុងករណីធ្វើខុសជាទម្ងន់ ក្នុងការបំពេញការងាររបស់ខ្លួន រដ្ឋសភាអាចសំរេចប្តឹងទៅតុលាការមានសមត្ថកិច្ច ។

រដ្ឋសភាសំរេចក្នុងរឿងនេះ ដោយវិធីបោះឆ្នោតជាសំងាត់តាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ១២៧.~ ថ្មី (មាត្រា ១០៨ ចាស់)**

ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីនឹងត្រូវកំណត់ក្នុងច្បាប់មួយ ។

## ជំពូកទី ១១ ថ្មី

## អំពី អំណាចតុលាការ

**មាត្រា ១២៨.~ ថ្មី (មាត្រា ១០៩ ចាស់)**

អំណាចតុលាការជាអំណាចឯករាជ្យ ។

អំណាចតុលាការធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ។

អំណាតតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង ។

អំណាចនេះត្រូវប្រគល់អោយតុលាការកំពូល និងសាលាជំរះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ ។

**មាត្រា ១២៩.~ ថ្មី (មាត្រា ១១០ ចាស់)**

ការជំរះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន ។

មានតែចៅក្រមទេដែលមានសិទ្ធិជំរះក្តី ។ ចៅក្រមត្រូវបំពេញភារកិច្ចនេះដោយគោរពច្បាប់យ៉ាងម៉ឹងម៉ាត់ និងអោយអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន ។

**មាត្រា ១៣០.~ ថ្មី (មាត្រា ១១១ ចាស់)**

គ្មានអង្គការណាមួយ នៃអំណាចនីតិប្បញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ ។

**មាត្រា ១៣១.~ ថ្មី (មាត្រា ១១២ ចាស់)**

មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា ។

**មាត្រា ១៣២.~ ថ្មី (មាត្រា ១១៣ ចាស់)**

ព្រះមហាក្សត្រ ទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ ។

**មាត្រា ១៣៣.~ ថ្មី (មាត្រា ១១៤ ចាស់)**

ចៅក្រមមិនអាចត្រូវគេដកពីមុខងារបានទេ ។ ប៉ុន្តែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សំរេចដាក់វិន័យលើចៅក្រម

ដែលបានប្រព្រឹត្តខុស ។

**មាត្រា ១៣៤.- ថ្មី (មាត្រា ១១៥ចាស់)**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងត្រូវបង្កើតដោយច្បាប់រៀបចំអង្គការមួយ ដែលនឹងកំណត់សមាសភាព និងមុខងារ ។

ឧត្តមក្រុមប្រឹក្សានៃអង្គក្រម ស្ថិតក្រោមព្រះរាជាធិបតីនៃព្រះមហាក្សត្រ ។ ព្រះមហាក្សត្រព្រះអង្គទ្រង់អាចចាត់តាំងព្រះរាជតំណាងម្នាក់របស់ព្រះអង្គអោយធ្វើជាអធិបតីនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនេះ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រ អំពីការតែងតាំងចៅក្រម និងព្រះរាជអាជ្ញាអមសាលាជំរះក្តីទាំងអស់ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងមុខការដាក់វិន័យចំពោះចៅក្រម និងព្រះរាជអាជ្ញា ត្រូវប្រជុំក្រោមអធិបតីភាពនៃប្រធានតុលាការកំពូល ឬអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល អាស្រ័យដោយករណីទាក់ទងនឹងចៅក្រម ឬព្រះរាជអាជ្ញា ។

**មាត្រា ១៣៥.- ថ្មី (មាត្រា ១១៦ ចាស់)**

លក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា និងការរៀបចំអង្គការតុលាការនឹងត្រូវកំណត់ក្នុងច្បាប់ដោយឡែកពីគ្នា ។

## ជំពូកទី ១២ ថ្មី
## អំពី ក្រុមប្រឹក្សាធម្មនុញ្ញ

**មាត្រា ១៣៦.- ថ្មី**

ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារ ការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ។

ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យ និងសំរេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

**មាត្រា ១៣៧.- ថ្មី (មាត្រា ១១៨ ចាស់)**

ក្រុមប្រឹក្សាធម្មនុញ្ញ មានសមាជិកប្រាំបួនរូប ដែលទទួលអាណត្តិប្រាំបួនឆ្នាំ ។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ចំនួនមួយភាគបី ត្រូវផ្លាស់ថ្មីក្នុងរយៈពេលបីឆ្នាំម្តង បីឆ្នាំម្តង ។ សមាជិកបីរូប ត្រូវតែងតាំងដោយព្រះមហាក្សត្រ បីរូបត្រូវជ្រើសតាំងដោយរដ្ឋសភា ហើយបីរូបទៀត ត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

ប្រធានត្រូវបានជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ។ ប្រធានមានសម្លេងឧត្តមានុភាព ក្នុងករណីបែកសម្លេងជាពីរស្មើគ្នា ។

**មាត្រា ១៣៨.-  ថ្មី  (មាត្រា ១១៩ ចាស់)**

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញត្រូវជ្រើសរើសក្នុងចំណោមឥស្សរជន ដែលមានសញ្ញាប័ត្រចាប់ពីឧត្តមសិក្សាទៅខាងច្បាប់ ខាងរដ្ឋបាល ខាងការទូត ឬខាងសេដ្ឋកិច្ច ហើយមានពិសោធន៍ច្រើនក្នុងការងារ ។

**មាត្រា ១៣៩.-  ថ្មី**

មុខងារសមាជិកក្រុមប្រឹក្សាធម្មនុញ្ញមាន វិសមិតភាព និងមុខងារសមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា សមាជិករាជរដ្ឋាភិបាល ចៅក្រមក្នុងតំណែង ការកាន់តំណែងណាមួយក្នុងមុខងារសាធារណៈ ប្រធាន ឬអនុប្រធានគណបក្សនយោបាយ ប្រធាន ឬអនុប្រធានសហជីព ។

**មាត្រា ១៤០.-  ថ្មី**

ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា តំណាងរាស្ត្រចំនួនមួយភាគដប់ ប្រធានព្រឹទ្ធសភា ឬសមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន អាចបញ្ជូនច្បាប់ដែលរដ្ឋសភាបានអនុម័តទៅឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងច្បាប់នោះត្រូវប្រកាសឱ្យប្រើ ។

បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹងប្រកាសអោយប្រើ ។ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសំរេចក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ យ៉ាងយូរថាតើច្បាប់ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាខាងលើស្រប ឬមិនស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ១៤១.-  ថ្មី**

ក្រោយពីច្បាប់ណាមួយ ត្រូវបានប្រកាសអោយប្រើ ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋ-មន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន តំណាងរាស្ត្រចំនួនមួយភាគដប់ ឬតុលាការអាចសុំអោយក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់នោះ ។

ប្រជារាស្ត្រមានសិទ្ធិប្តឹងអំពីធម្មនុញ្ញភាពនៃច្បាប់បាន តាមរយៈតំណាងរាស្ត្រ ឬប្រធានរដ្ឋសភា ឬសមាជិក-ព្រឹទ្ធសភា ឬប្រធានព្រឹទ្ធសភា ដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ ។

**មាត្រា ១៤២.-  ថ្មី  (មាត្រា ១២៣ ចាស់)**

បទប្បញ្ញត្តិក្នុងមាត្រាណា ដែលក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថា មិនស្របនឹងរដ្ឋធម្មនុញ្ញ មិនអាចយកទៅប្រកាសអោយប្រើ ឬយកទៅអនុវត្តបានឡើយ ។

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសំរេចបិទផ្លូវតវ៉ា ។

**មាត្រា ១៤៣.-  ថ្មី  (មាត្រា ១២៤ ចាស់)**

ព្រះមហាក្សត្រ ទ្រង់ពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ ចំពោះសេចក្តីស្នើទាំងឡាយ ដែលសុំធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញ ។

**មាត្រា ១៤៤.-  ថ្មី  (មាត្រា ១២៥ ចាស់)**

ច្បាប់រៀបចំអង្គការមួយនឹងកំណត់ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។

## ជំពូកទី ១៣ ថ្មី

## អំពី ការគ្រប់គ្រងរដ្ឋបាល

### មាត្រា ១៤៥.- ថ្មី (មាត្រា ១២៦ ចាស់)

ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ចែកជាខេត្ត និងក្រុង ។

ខេត្តចែកជាស្រុក ស្រុកចែកជាឃុំ ។

ក្រុងចែកជាខណ្ឌ ខណ្ឌចែកជាសង្កាត់ ។

### មាត្រា ១៤៦.- ថ្មី (មាត្រា ១២៧ ចាស់)

ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ និងសង្កាត់ ត្រូវគ្រប់គ្រងតាមល័ក្ខខ័ណ្ឌ ដែលមានចែងក្នុងច្បាប់រៀបចំអង្គការមួយ ។

## ជំពូកទី ១៤ ថ្មី

## អំពី សមាជជាតិ

### មាត្រា ១៤៧.- ថ្មី (មាត្រា ១២៨ ចាស់)

សមាជជាតិបើកអោយប្រជារាស្ត្រជ្រាបដោយផ្ទាល់ អំពីកិច្ចការផ្សេងៗ ដែលជាប្រយោជន៍ជាតិ និងលើកបញ្ហា - និងសំណូមពរជូនរដ្ឋអំណាចដោះស្រាយ ។

ប្រជារាស្ត្រខ្មែរទាំងពីរភេទ មានសិទ្ធិទៅចូលរួមក្នុងសមាជជាតិ ។

### មាត្រា ១៤៨.- ថ្មី (មាត្រា ១២៩ ចាស់)

សមាជជាតិ ប្រជុំមួយដងក្នុងមួយឆ្នាំ នៅដើមខែធ្នូ តាមការកោះអញ្ជើញរបស់នាយករដ្ឋមន្ត្រី ។

សមាជជាតិ ប្រព្រឹត្តទៅក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ ។

### មាត្រា ១៤៩.- ថ្មី

សមាជជាតិ អនុម័តសំណូមពរជូនព្រឹទ្ធសភា ជូនរដ្ឋសភា និងជូនរដ្ឋអំណាចពិចារណា ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជជាតិ នឹងត្រូវកំណត់ក្នុងច្បាប់មួយ ។

## ជំពូកទី ១៥ ថ្មី

## អំពី អានុភាព ការសើរើ និងវិសោធនកម្មរដ្ឋធម្មនុញ្ញ

### មាត្រា ១៥០.- ថ្មី (មាត្រា ១៣១ ចាស់)

រដ្ឋធម្មនុញ្ញនេះ ជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា ។

ច្បាប់ និងសេចក្តីសំរេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋ ត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត ។

**មាត្រា ១៥១.~ ថ្មី (មាត្រា ១៣២ ចាស់)**

ការផ្ដើមគំនិតសើរើ ឬការផ្ដើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ជាសិទ្ធិរបស់ព្រះមហាក្សត្រ របស់នាយករដ្ឋមន្ត្រី និងរបស់ប្រធានរដ្ឋសភា តាមសេចក្ដីស្នើរបស់តំណាងរាស្ត្រមួយភាគបួន នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវធ្វើឡើងដោយច្បាប់ធម្មនុញ្ញមួយ ដែលអនុម័តដោយរដ្ឋសភា តាមមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ១៥២.- ថ្មី (មាត្រា ១៣៣ ចាស់)**

ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវហាមឃាត់មិនអោយធ្វើនៅពេលប្រទេសជាតិឋិតក្នុងភាពអាសន្ន ដូចមានចែងក្នុងមាត្រា ៨៦ ។

**មាត្រា ១៥៣.- ថ្មី (មាត្រា ១៣៤ ចាស់)**

ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ មិនអាចធ្វើបានឡើយ កាលបើប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស និងរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ ។

## ជំពូកទី ១៦ ថ្មី
## អំពី អន្តរបញ្ញត្តិ

**មាត្រា ១៥៤.- ថ្មី**

រដ្ឋធម្មនុញ្ញនេះ ក្រោយពីបានទទួលការអនុម័ត ត្រូវបានប្រកាសអោយចូលជាធរមានភ្លាម ដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១៥៥.- ថ្មី (មាត្រា ១៣៦ ចាស់)**

ក្រោយពេលរដ្ឋធម្មនុញ្ញនេះ ចូលជាធរមាន សភាធម្មនុញ្ញត្រូវក្លាយទៅជារដ្ឋសភា ។

បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាត្រូវចូលជាធរមាន ក្រោយទទួលបានការអនុម័តពីរដ្ឋសភា ។

ក្នុងករណីដែលរដ្ឋសភា មិនទាន់ចាប់ដំណើរការបាន ប្រធាន អនុប្រធានទីមួយ និងអនុប្រធានទីពីរ នៃសភាធម្មនុញ្ញ នឹងចូលរួមបំពេញភារកិច្ចក្នុងក្រុមប្រឹក្សារាជសម្បត្តិ បើសភាពការណ៍ក្នុងប្រទេសទាមទារ ។

**មាត្រា ១៥៦.- ថ្មី**

ក្រោយរដ្ឋធម្មនុញ្ញនេះ ចូលជាធរមាន ព្រះមហាក្សត្រជ្រើសតាំងតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ១៣ថ្មី និង ១៤ ។

**មាត្រា ១៥៧.- ថ្មី**

នីតិកាលទី១ នៃព្រឹទ្ធសភាមានកំណត់ ៥ ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលព្រឹទ្ធសភាថ្មីចូលកាន់តំណែង ។

សំរាប់នីតិកាលទី១ នៃព្រឹទ្ធសភា :

-សមាជិកព្រឹទ្ធសភា មានចំនួនសរុប ហុកសិបមួយរូប ។

-ព្រះមហាក្សត្រទ្រង់តែងតាំងសមាជិកព្រឹទ្ធសភាពីររូប ព្រមទាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា ។

-សមាជិកដទៃទៀតនៃព្រឹទ្ធសភា ត្រូវបានតែងតាំងដោយព្រះមហាក្សត្រតាមសំណើរបស់ប្រធានព្រឹទ្ធសភា និងប្រធានរដ្ឋសភា ក្នុងចំណោមសមាជិកនៃគណបក្សដែលមានអាសនៈនៅក្នុងរដ្ឋសភា ។

-កិច្ចប្រជុំជាសមាជរដ្ឋសភា និងព្រឹទ្ធសភា ត្រូវដឹកនាំដោយសហប្រធាន ។

**មាត្រា ១៥៨.~ ថ្មី (មាត្រា ១៣៩ ចាស់)**

ច្បាប់ និងលិខិតបទដ្ឋានទាំងអស់នៅកម្ពុជា ដែលធានាការពារបាននូវទ្រព្យសម្បត្តិរដ្ឋ សិទ្ធិ សេរីភាព និងទ្រព្យសម្បត្តិត្រឹមត្រូវតាមច្បាប់របស់បុគ្គល និងដែលសមស្របនឹងប្រយោជន៍ជាតិ ត្រូវមានអានុភាពអនុវត្តន៍បន្តទៅមុខទៀត រហូតដល់មានអត្ថបទថ្មីមកកែប្រែ ឬលុបចោល លើកលែងតែបទប្បញ្ញត្តិណាដែលផ្ទុយនឹងស្មារតី នៃរដ្ឋធម្មនុញ្ញនេះ ។

រដ្ឋធម្មនុញ្ញនេះត្រូវបានសភាធម្មនុញ្ញអនុម័ត

នៅភ្នំពេញថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៣ នាសម័យប្រជុំ ពេញអង្គលើកទី២

*ភ្នំពេញ.ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៣*

**ប្រធាន**

**ហត្ថលេខា**

**សឺន សាន**

ច្បាប់ធម្មនុញ្ញនេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩ ក្នុងសម័យប្រជុំវិសាមញ្ញ នីតិកាលទី ២ ។

ភ្នំពេញថ្ងៃទី ០៦ ខែ មិនា ឆ្នាំ ១៩៩៩

**ប្រធានរដ្ឋសភា**

ហត្ថលេខា និងត្រា

**នរោត្តម រណឫទ្ធិ**

ឧបសម្ព័ន្ធ១

ទង់ជាតិ



# ភ្លេងជាតិ នគររាជ

១ សូមពពួកទេវតា រក្សា មហាក្សត្រយើង
ឱ្យ បានរុងរឿង ដោយជ័យមង្គល សិរីសួស្តី
យើងខ្ញុំព្រះអង្គ សូមជ្រក ក្រោមម្លប់ព្រះបារមី
នៃព្រះនរបតី វង្សក្សត្រាដែលសាងប្រាសាទថ្ម
គ្រប់គ្រងដែនខ្មែរ បុរាណថ្កើងថ្កាន ៗ

២ ប្រាសាទសិលា កំបាំងកណ្តាលព្រៃ
គួរអោយស្រមៃ នឹកដល់យសសក្តិ មហានគរ
ជាតិខ្មែរដូចថ្ម គង់វង្សនៅល្អ រឹងប៉ឹងជំហរ
យើងសង្ឃឹមពរ ភ័ព្វព្រេងសំណាងរបស់កម្ពុជា
មហារដ្ឋកើតមាន យូរអង្វែងហើយ ៗ

៣ គ្រប់វត្តអារាម ឮតែសូរស័ព្ទធម៌
សូត្រដោយអំណរ រំឭកគុណពុទ្ធសាសនា
ចូរយើងជាអ្នក ជឿជាក់ស្មោះស្ម័គ្រ តាមបែបដូនតា
គង់តែទេវតា នឹងជួយជ្រោមជ្រែងផ្គត់ផ្គង់ប្រយោជន៍ឱ្យ
ដល់ប្រទេសខ្មែរ ជាមហានគរ ៗ

ឧបសម្ព័ន្ធ៣

# សញ្ញាជាតិ



**ឧបសម្ព័ន្ធ៤**

# សច្ចាប្រណិធាន
# នៃ
# ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

**ខ្ញុំតាំងសច្ចាថានឹងប្រព្រឹត្តតាមរដ្ឋធម្មនុញ្ញ និងច្បាប់ទាំងឡាយ**
**នៃព្រះរាជាណាចក្រ**
**ហើយនឹងតាំងចិត្តធ្វើផលប្រយោជន៍ដល់រដ្ឋ**
**និងប្រជារាស្ត្រ ។**

**ឧបសម្ព័ន្ធទី ៥**

# សច្ចាប្រណិធាន

ទូលព្រះបង្គំ

យើងខ្ញុំ

ប្រធាន អនុប្រធាន និងសមាជិករដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា

សូមធ្វើសច្ចាប្រណិធាន

នៅចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រ ព្រះភ័ក្ត្រនៃសម្តេចព្រះសង្ឃរាជ

និងទេវតារក្សាស្វេតច្ឆត្រ

ដូចតទៅ :

ក្នុងពេលប្រតិបត្តិការ តាមមុខតំណែងខ្លួន និងក្នុងការបំពេញបេសកម្ម ដែលប្រជារាស្ត្រកម្ពុជា បានប្រគល់ជូនចំពោះទូលព្រះបង្គំ យើងខ្ញុំគ្រប់ៗរូប ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាគោរពរដ្ឋធម្មនុញ្ញ បំរើជានិច្ចទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគតនូវផលប្រយោជន៍ របស់ប្រជារាស្ត្រ ប្រជាជាតិ និងមាតុភូមិកម្ពុជា ។ ទូលព្រះបង្គំយើងខ្ញុំ សូមសច្ចាថា មិនកេង-ប្រវ័ញ្ចនូវផលប្រយោជន៍ជាតិ សំរាប់ផ្ទាល់ខ្លួន ឬសំរាប់គ្រួសារ ឬសំរាប់បក្សពួក ឬ សំរាប់ភាគីរៀងៗខ្លួនឡើយ ។

ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាប្តូរផ្តាច់ហ៊ានបូជាជីវិត ដើម្បីការពារជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគតនូវ :

-ឯករាជ្យភាពទាំងស្រុង នៃមាតុភូមិកម្ពុជា

-អធិបតេយ្យភាពជាតិបរិបូរណ៍

-បូរណភាពទឹកដីដ៏ត្រឹមត្រូវតាមច្បាប់ នៅក្នុងព្រំដែនដីគោក និងព្រំដែនសមុទ្រដែលកម្ពុជាធ្លាប់មានក្នុងជំនាន់ ឆ្នាំ ១៩៦៣ ដល់ ១៩៦៩

- ឯកភាពជាតិ ហើយមិនអនុញ្ញាតឱ្យមានការបែងចែក ឬការធ្វើអបគមន៍ណាមួយឡើយ ។

-ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញារក្សាទុកជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវអព្យាក្រឹត្យភាព និងភាពមិនចូលបក្សសម្ព័ន្ធសំរាប់កម្ពុជា ហើយមិនអនុញ្ញាតជាដាច់ខាតអោយជនណាក៏ដោយ ដែលចង់ជ្រៀតជ្រែកចូលក្នុងផ្ទៃក្នុងនៃកម្ពុជា ឬមកបង្គាប់បញ្ជាចំពោះគោលនយោបាយជាតិ និងអន្តរជាតិ របស់កម្ពុជាបានឡើយ ។ ទូលព្រះបង្គំ យើងខ្ញុំមិនបំរើជាដាច់ខាត នូវផលប្រយោជន៍បរទេស ហើយធ្វើអោយខូតខាតដល់ផលប្រយោជន៍ របស់ប្រជារាស្ត្រ ប្រជាជាតិ និងមាតុភូមិកម្ពុជាឡើយ ។

-ក្នុងការដោះស្រាយបញ្ហាទាំងឡាយ លើផ្ទៃរាបជាតិ និងអន្តរជាតិ ទូលព្រះបង្គំយើងខ្ញុំនឹងបំបាត់ចោលទាំងស្រុងនូវអំពើហឹង្សាគ្រប់បែបយ៉ាង ។

ប៉ុន្តែ ព្រះរាជាណាចក្រកម្ពុជា សូមរក្សាទុកនូវសិទ្ធិកាន់អាវុធ តស៊ូប្រឆាំងនឹងការរំលោភឈ្លានពានមកពីក្រៅ ដើម្បីការពារជាតិមាតុភូមិខ្លួន ។

ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាគោរពជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវលទ្ធិប្រជាធិបតេយ្យ សេរីនិយម

ដែលមានរបបសភា និងពហុបក្ស ព្រមទាំងមានការគោរពយ៉ាងម៉ឺងម៉ាត់ចំពោះសិទ្ធិមនុស្ស ដូចមានចែងក្នុងសេចក្តីប្រកាសជាសកល ស្តីអំពីសិទ្ធិមនុស្ស ។

ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាតស៊ូប្រឆាំង អំពើពុករលួយគ្រប់បែបយ៉ាង ប្រឆាំងអយុត្តិធម៌សង្គម ហើយ តស៊ូ ដើម្បីផ្សះផ្សារជាតិ ដើម្បីឯកភាពជាតិ ដើម្បីសន្តិភាពសង្គម និងសន្តិភាពជាតិ ដើម្បីភាពសម្បូរសប្បាយ នៃប្រជា រាស្ត្រកម្ពុជា និងដើម្បីភាពរុងរឿងថ្កើនថ្កាន នៃមាតុភូមិកម្ពុជាជាទីគោរពសក្ការៈ និងជាទីស្នេហានៃទូលព្រះបង្គំយើងខ្ញុំ គ្រប់រូប ។

**ឧបសម្ព័ន្ធ៦**

## សច្ចាប្រណិធាន

ទូលព្រះបង្គំ

យើងខ្ញុំ

នាយករដ្ឋមន្ត្រី និងសមាជិករាជរដ្ឋាភិបាល

សូមធ្វើសច្ចាប្រណិធាន

នៅចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រ

ព្រះភ័ក្ត្រនៃសម្តេចព្រះសង្ឃរាជ

និងទេវតារក្សាស្វេតច្ឆត្រ

ដូចតទៅ :

ក្នុងពេលប្រតិបត្តិការ តាមមុខតំណែងខ្លួន និងក្នុងការបំពេញបេសកម្ម ដែលប្រជារាស្ត្រកម្ពុជា បានប្រគល់ជូនចំពោះទូលព្រះបង្គំយើងខ្ញុំគ្រប់ៗរូប ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាគោរពរដ្ឋធម្មនុញ្ញ បំរើជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវផលប្រយោជន៍ របស់ប្រជារាស្ត្រ ប្រជាជាតិ និង មាតុភូមិកម្ពុជា ។ ទូលព្រះបង្គំយើងខ្ញុំ សូមសច្ចាថា មិនកេងប្រវ័ញ្ច នូវផលប្រយោជន៍ជាតិ សំរាប់ផ្ទាល់ខ្លួន ឬសំរាប់គ្រួសារ ឬសំរាប់បក្សពួក ឬសំរាប់ភាគី រៀងៗខ្លួនឡើយ ។

ទូលព្រះបង្គំយើងខ្ញុំសូមប្តេជ្ញា ប្តូរផ្តាច់ហ៊ានបូជាជីវិត ដើម្បីការពារជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវ

-ឯករាជ្យភាពទាំងស្រុង នៃមាតុភូមិកម្ពុជា

-អធិបតេយ្យភាពជាតិពេញបរិបូណ៌

-បូរណភាពទឹកដីដ៏ត្រឹមត្រូវតាមច្បាប់ នៅក្នុងដែនព្រំដែនដីគោក និងព្រំដែនសមុទ្រដែលកម្ពុជាធ្លាប់មានក្នុងជំនាន់ឆ្នាំ ១៩៦៣ ដល់ ១៩៦៩

-ឯកភាពជាតិ ហើយមិនអនុញ្ញាតឱ្យមានការបែងចែក ឬការធ្វើអបគមន៍ណាមួយឡើយ ។

ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញារក្សាទុកជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវអព្យាក្រឹត្យភាព និងភាពមិនចូលបក្សសម្ព័ន្ធ សំរាប់កម្ពុជា ហើយមិនអនុញ្ញាតជាដាច់ខាតឱ្យជនណាក៏ដោយ ដែលចង់ជ្រៀតជ្រែក ចូលក្នុងផ្ទៃក្នុងនៃកម្ពុជា ឬមកបង្គាប់បញ្ជាចំពោះគោលនយោបាយជាតិ និងអន្តរជាតិ របស់កម្ពុជាបានឡើយ ។ ទូលព្រះបង្គំយើងខ្ញុំ មិនបំរើជាដាច់ខាត នូវផលប្រយោជន៍បរទេស ហើយធ្វើឱ្យខូចខាតដល់ ផលប្រយោជន៍ របស់ ប្រជារាស្ត្រ ប្រជាជាតិ និងមាតុភូមិកម្ពុជាឡើយ ។

ក្នុងការដោះស្រាយបញ្ហាទាំងឡាយ លើផ្ទៃរាបជាតិ និងអន្តរជាតិ ទូលព្រះបង្គំយើងខ្ញុំនឹងបំបាត់ចោលទាំងស្រុងនូវអំពើហឹង្សាគ្រប់បែបយ៉ាង ។

ប៉ុន្តែ ព្រះរាជាណាចក្រកម្ពុជា សូមរក្សាទុកនូវសិទ្ធិកាន់អាវុធ តស៊ូប្រឆាំងនឹងការរំលោភឈ្លានពានមកពីក្រៅដើម្បីការពារជាតិមាតុភូមិខ្លួន ។

ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាគោរពជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវលទ្ធិប្រជាធិបតេយ្យសេរីនិយម ដែលមានរបបសភា និងពហុបក្ស ព្រមទាំងមានការគោរពយ៉ាងម៉ឺងម៉ាត់ចំពោះសិទ្ធិមនុស្ស ដូចមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស ។

ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាតស៊ូប្រឆាំង អំពើពុករលួយគ្រប់បែបយ៉ាង ប្រឆាំងអយុត្តិធម៌សង្គម ហើយតស៊ូ ដើម្បីផ្សះផ្សាជាតិ ដើម្បីឯកភាពជាតិ ដើម្បីសន្តិភាពសង្គម និងសន្តិភាពជាតិ ដើម្បីភាពសម្បូរសប្បាយ នៃប្រ ជារាស្ត្រកម្ពុជា និងដើម្បីភាពរុងរឿង ថ្កើងថ្កាន នៃមាតុភូមិកម្ពុជា ជាទីគោរពសក្ការៈ និងជាទីស្នេហានៃទូលព្រះ បង្គំយើងខ្ញុំគ្រប់រូប ។

**ឧបសម្ព័ន្ធ៧**

## សច្ចាប្រណិធាន

ទូលព្រះបង្គំ

យើងខ្ញុំ

ប្រធាន អនុប្រធាន និងសមាជិកព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

សូមធ្វើសច្ចាប្រណិធាន

នៅចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រ

ព្រះភ័ក្ត្រនៃសម្ដេចព្រះសង្ឃរាជ

និងទេវតារក្សាស្វេតច្ឆត្រ

ដូចតទៅ :

ក្នុងពេលប្រតិបត្តិការ តាមមុខតំណែងខ្លួន និងក្នុងការបំពេញបេសកម្ម ដែលប្រជារាស្ត្រកម្ពុជា បានប្រគល់ជូនចំពោះទូលព្រះបង្គំយើងខ្ញុំគ្រប់ៗរូប ទូលព្រះបង្គំយើងខ្ញុំសូមប្ដេជ្ញាគោរពរដ្ឋធម្មនុញ្ញ បំរើជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវផលប្រយោជន៍ របស់ប្រជារាស្ត្រ ប្រជាជាតិ និង មាតុភូមិកម្ពុជា ។ ទូលព្រះបង្គំយើងខ្ញុំ សូមសច្ចាថាមិនកេងប្រវ័ញ្ច នូវផលប្រយោជន៍ជាតិ សំរាប់ផ្ទាល់ខ្លួន ឬសំរាប់គ្រួសារ ឬសំរាប់បក្សពួក ឬសំរាប់ភាគី រៀងៗខ្លួនឡើយ ។

ទូលព្រះបង្គំយើងខ្ញុំសូមប្ដេជ្ញា ប្ដូរផ្ដាច់ហ៊ានបូជាជីវិត ដើម្បីការពារជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវ

-ឯករាជ្យភាពទាំងស្រុង នៃមាតុភូមិកម្ពុជា

-អធិបតេយ្យភាពជាតិពេញបរិបូណ៌

-បូរភាពទឹកដីដ៏ត្រឹមត្រូវតាមច្បាប់ នៅក្នុងព្រំដែនដីគោក និងព្រំដែនសមុទ្រដែលកម្ពុជាធ្លាប់មាន ក្នុងជំនាន់ឆ្នាំ១៩៦៣ ដល់ ១៩៦៩

-ឯកភាពជាតិ ហើយមិនអនុញ្ញាតឱ្យមានការបែងចែក ឬការធ្វើអបគមន៍ណាមួយឡើយ ។

ទូលព្រះបង្គំយើងខ្ញុំ សូមប្ដេជ្ញារក្សាទុកជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវអព្យាក្រឹត្យភាព និងភាពមិនចូលបក្សសម្ព័ន្ធ សំរាប់កម្ពុជា ហើយមិនអនុញ្ញាតជាដាច់ខាតឱ្យជនណាក៏ដោយ ដែលចង់ជ្រៀតជ្រែក ចូលក្នុងផ្ទៃក្នុងនៃកម្ពុជា ឬមកបង្គាប់បញ្ជាចំពោះគោលនយោបាយជាតិ និងអន្តរជាតិ របស់កម្ពុជាបានឡើយ ។ ទូលព្រះបង្គំយើងខ្ញុំ មិនបំរើជាដាច់ខាត នូវផលប្រយោជន៍បរទេស ហើយធ្វើឱ្យខូចខាតដល់ ផលប្រយោជន៍ របស់ ប្រជារាស្ត្រ ប្រជាជាតិ និងមាតុភូមិកម្ពុជាឡើយ ។

- ក្នុងការដោះស្រាយបញ្ហាទាំងឡាយ លើផ្ទៃរាបជាតិ និងអន្តរជាតិ ទូលព្រះបង្គំយើងខ្ញុំនឹងបំបាត់ចោលទាំងស្រុងនូវអំពើហឹង្សាគ្រប់បែបយ៉ាង ។

- ប៉ុន្តែ ព្រះរាជាណាចក្រកម្ពុជា សូមរក្សាទុកនូវសិទ្ធិកាន់អាវុធ តស៊ូប្រឆាំងនឹងការរំលោភឈ្លានពានមកពីក្រៅដើម្បីការពារជាតិមាតុភូមិខ្លួន ។

ទូលព្រះបង្គំយើងខ្ញុំ សូមប្ដេជ្ញាគោរពជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវលទ្ធិប្រជាធិបតេយ្យសេរីនិយមដែល ដែលមានរបបសភា និងពហុបក្ស ព្រមទាំងមានការគោរពយ៉ាងម៉ឺងម៉ាត់ចំពោះសិទ្ធិមនុស្ស ដូចមានចែងក្នុងសេចក្ដីប្រ-កាសជាសកលស្ដីអំពីសិទ្ធិមនុស្ស ។

ទូលព្រះបង្គំយើងខ្ញុំ សូមប្ដេជ្ញាតស៊ូប្រឆាំង អំពើពុករលួយគ្រប់បែបយ៉ាង ប្រឆាំងអយុត្តិធម៌សង្គម ហើយតស៊ូ ដើម្បីផ្សះផ្សាជាតិ ដើម្បីឯកភាពជាតិ ដើម្បីសន្តិភាពសង្គម និងសន្តិភាពជាតិ ដើម្បីភាពសម្បូរសប្បាយ នៃប្រជារាស្ត្រ កម្ពុជា និងដើម្បីភាពរុងរឿងថ្កើងថ្កាន នៃមាតុភូមិកម្ពុជាជាទីគោរពសក្ការៈ និងជាទីស្នេហានៃទូលព្រះបង្គំយើង ខ្ញុំគ្រប់រូប ។

# គណៈកម្មាធិការអចិន្ត្រៃយ៍រៀបរៀងរដ្ឋធម្មនុញ្ញ
# បានអនុម័តដោយសភាធម្មនុញ្ញនាសម័យប្រជុំពេញអង្គលើកទី ១
# ថ្ងៃទី ៣០ ខែ មិថុនា ១៩៩៣

១.ឯកឧត្តមសម្តេចប្រធានសភាធម្មនុញ្ញឬឯកឧត្តមអនុប្រធានសភាធម្មនុញ្ញ "ករណីសម្តេចប្រធានអវត្តមាន" ជាប្រធាន

| | |
|---|---|
| ២- ឯកឧត្តម ចែម ស្ងួន | ជាអនុប្រធាន |
| ៣- ឯកឧត្តមបណ្ឌិត តាវ សេងហួរ | ជាអ្នករាយការណ៍ |
| ៤- ឯកឧត្តម កាន់ ម៉ន | ជាសមាជិក |
| ៥- ឯកឧត្តម គាត ឈន់ | ជាសមាជិក |
| ៦- ឯកឧត្តម ឈួរ លាងហួត | ជាសមាជិក |
| ៧- ឯកឧត្តម ថោ ប៉េងលាត | ជាសមាជិក |
| ៨- ឯកឧត្តម សម រង្ស៊ី | ជាសមាជិក |
| ៩-អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរីរត្ន | ជាសមាជិក |
| ១០- ឯកឧត្តម សឺន ស៊ូប៊ែរ្តិ៍ | ជាសមាជិក |
| ១១- ឯកឧត្តម សោម ចាន់បុត្រ | ជាសមាជិក |
| ១២- ឯកឧត្តម អ៊ុន នឹង | ជាសមាជិក |
| ១៣- ឯកឧត្តម ឡូយ ស៊ីមឈាង | ជាសមាជិក |
| ១៤- ឯកឧត្តម ជាម យៀប | ជាសមាជិកបំរុង |
| ១៥- ឯកឧត្តម ប៉ុល ហំម | ជាសមាជិកបំរុង |
| ១៦- ឯកឧត្តម ពូរ សុធីរៈ | ជាសមាជិកបំរុង |
| ១៧- ឯកឧត្តម សរ សំអាត | ជាសមាជិកបំរុង |
| ១៨- ឯកឧត្តម អ៊ឹង គៀត | ជាសមាជិកបំរុង |
| ១៩- ឯកឧត្តម អ៊ុក វ៉ាប៊ុន | ជាសមាជិកបំរុង |
| ២០- ឯកឧត្តម អ៊ុំង ផន | ជាសមាជិកបំរុង |
| ២១- ឯកឧត្តម ឯក សំអុល | ជាសមាជិកបំរុង |
| ២២- ឯកឧត្តម សាយ បូរី | ជាអ្នកជំនាញការ |
| ២៣- ឯកឧត្តម ចាន់ សុខ | ជាអ្នកជំនាញការ |
| ២៤- ឯកឧត្តម ឈន អៀម | ជាអ្នកជំនាញការ |
| ២៥- ឯកឧត្តម ហេង វង្សប៊ុនឆាត | ជាអ្នកជំនាញការ |
| ២៦- ឯកឧត្តម ខៀវ វ៉ាជា | ជាអ្នកជំនាញការ |

**កំណត់សំគាល់** : យោងជំពូក ៧ ប្រការ១៨ ស្តីពីគណៈកម្មការ និងប្រធានគណៈកម្មការសភាធម្មនុញ្ញ

**ច្បាប់**

**ស្តីពី**

**មាត្រា ២៨ នៃរដ្ឋធម្មនុញ្ញ**

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា

អនុម័តថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៤

នាសម័យប្រជុំវិសាមញ្ញសម័យពិសេស

ភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៤

ប្រធានរដ្ឋសភាស្តីទី

ហត្ថលេខា

**ឡូយ ស៊ីមឈាង**

នស/រកម/០៧៩៤/០១

# ព្រះរាជក្រម

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

យោងតាមមាត្រា ១១ ជំពូកទី ២ ស្តីពី **ព្រះមហាក្សត្រ** នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រ**កម្ពុជា** ដែលត្រូវបានសភាធម្មនុញ្ញ អនុម័តនៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៣

**បង្កាប់**

**មាត្រា១ :** ប្រកាសឱ្យប្រើជាផ្លូវការ នូវច្បាប់ស្តីពីការកែប្រែមាត្រា ២៨នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាដែលរដ្ឋសភា បានអនុម័ត នៅថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៤ ។

**មាត្រា២ :** ព្រះរាជក្រមនេះចូលជាធរមានច្បាប់ ចាប់ពីពេលចុះហត្ថលេខានេះតទៅ ។

ធ្វើនៅព្រះរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៤

ក្នុងព្រះបរមនាថ និងតាមព្រះរាជចំណារ

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងត្រា

**ជា ស៊ីម**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ច្បាប់ធម្មនុញ្ញ
# ស្ដីពី
# វិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨
# ៣០ ៣៤ ៥១ ៩០ ៩១ ៩៣
# និងមាត្រាឆាំងឡាយ នៃជំពូកទី ៨
# ដល់
# ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ

ច្បាប់ធម្មនុញ្ញនេះ ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី ០៤ ខែ មិនា ឆ្នាំ ១៩៩៩ ក្នុងសម័យប្រជុំវិសាមញ្ញ នីតិកាលទី ២ ។

**ភ្នំពេញ ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ១៩៩៩**

**ប្រធានរដ្ឋសភា**
**ហត្ថលេខា និងត្រា**
**នរោត្តម រណឫទ្ធិ**

នស/រកម/០៣៩៩/០១

# ព្រះរាជក្រម

## យើង

## ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-ទ្រង់យល់សម័យប្រជុំវិសាមញ្ញពេញអង្គ នៃរដ្ឋសភានៅថ្ងៃទី ២-៣-៤ ខែ មីនា ឆ្នាំ ១៩៩៩

-យោងតាមសំណើរបស់ ប្រធានរដ្ឋសភា ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ១៩៩៩

## ត្រាស់បង្គាប់

**មាត្រា១ :** ប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩ ។

**មាត្រា២ :** ព្រះរាជក្រមនេះចូលជាធរមានច្បាប់ ចាប់ពីពេល ឡាយព្រះហស្តលេខានេះតទៅ ។

ព្រះរាជលញ្ឆករ

**នរោត្តម សីហនុ**

ធ្វើនៅថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**

# ច្បាប់រដ្ឋធម្មនុញ្ញ
# ស្តីពី
# វិសោធនកម្មមាត្រា ១៩ និង មាត្រា ២៩ នៃរដ្ឋធម្មនុញ្ញ

**មាត្រាតែមួយ :** មាត្រា១៩ និងមាត្រា ២៩ នៃរដ្ឋធម្មនុញ្ញត្រូវបានកែប្រែដូចតទៅ :

**មាត្រា ១៩ ថ្មី.-**

ព្រះមហាក្សត្រទ្រង់តែងតាំងនាយករដ្ឋមន្ត្រី និងទ្រង់តែងតាំងគណៈរដ្ឋមន្ត្រីតាមបែបបទដែលមានចែងក្នុង មាត្រា ១១៩ ថ្មី ។

**មាត្រា ២៩ ថ្មី.-**

ព្រះមហាក្សត្រទ្រង់បង្កើត និងប្រទានគ្រឿងឥស្សរិយយសជាតិ ។

ព្រះមហាក្សត្រទ្រង់សំរេចប្រទានឋានន្តរសក្តិ ឋានៈ យោធា និងស៊ីវិលតាមច្បាប់កំណត់ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០០១ នាសម័យ
ប្រជុំរដ្ឋសភា លើកទី ៦ នីតិកាលទី ២ ។
ភ្នំពេញ.ថ្ងៃទី ខែ កក្កដា ឆ្នាំ ២០០១

**នរោត្តម** **រណឫទ្ធិ**

# ព្រះរាជក្រម

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ៣ នៃរដ្ឋសភា នាថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ២០០៤
- បានទ្រង់យល់សម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ នៃព្រឹទ្ធសភា នាថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៤
- យោងតាមសំណើ ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៤ របស់ព្រឹទ្ធសភា សមាជិករដ្ឋសភា នីតិកាលទី ៣

## ប្រកាសឱ្យប្រើ

ច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានឱ្យយោបល់យល់ព្រម កាលពីថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

## ច្បាប់ធម្មនុញ្ញបន្ថែម
## សំដៅ
## ធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

**មាត្រា ១.-**

ច្បាប់ធម្មនុញ្ញនេះ មានគោលដៅធានាក្នុងគ្រប់កាលៈទេសៈនូវដំណើរការល្អប្រសើរនៃស្ថាប័នជាតិ ដោយគោរពទៅតាមគោលការណ៍ជាមូលដ្ឋាន នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស សមស្របតាមតំរូវការនៃភាពចាំបាច់ ។

**មាត្រា ២.-**

នៅដើមនីតិកាលថ្មីនីមួយៗ រដ្ឋសភា ក្រោមអធិបតីភាពព្រឹទ្ធសមាជិករដ្ឋសភា មុននឹងផ្តើមការងាររបស់ខ្លួន និងក្រោយពេលសំរេចអំពីសុពលភាពនៃអាណត្តិរបស់សមាជិកម្នាក់ៗ អាចចាប់ផ្តើមអនុម័ត អត្ថបទដែលមានចរិក ជារដ្ឋធម្មនុញ្ញ ឬច្បាប់ដើម្បីអនុវត្តបាននូវគោលដៅដូចមានចែងក្នុងមាត្រា ១ ។

អត្ថបទទាំងនេះ ក្រោយពីបានត្រូវទទួលការបោះឆ្នោតអនុម័តដោយរដ្ឋសភារួចហើយ ត្រូវតែបានទទួលជាបន្ទាន់នូវចំណាត់ការដោយរួសរាន់ពីសំណាក់ព្រឹទ្ធសមាជិករដ្ឋសភា តាមនីតិវិធីកំណត់សំរាប់ អត្ថបទទាំងនោះ រហូតដល់ពេលដែលត្រូវបានប្រកាសអោយចូលជាធរមាន ។

**មាត្រា ៣.-**

ក្នុងករណីដែលឃើញថា នីតិវិធីនៃមាត្រា ៨២ និង១១៩ថ្មី នៃរដ្ឋធម្មនុញ្ញ មិនអាចសំរេចបាន រដ្ឋសភា តាមសំណើរបស់គណបក្សដែលមានអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភា អាចដំណើរការការបោះឆ្នោតជាកញ្ចប់ ដើម្បី ជ្រើសតាំងប្រធាន អនុប្រធាន រដ្ឋសភា ក៏ដូចជា ប្រធាន និងអនុប្រធាន គណៈកម្មការក្នុងពេលជាមួយគ្នា និងការផ្តល់សេចក្តីទុកចិត្តចំពោះ រាជរដ្ឋាភិបាល ។

**មាត្រា ៤.-**

ការរៀបចំបញ្ជីរាយនាមបេក្ខជន ដើម្បីបោះឆ្នោតជ្រើសតាំង និងផ្តល់សេចក្តីទុកចិត្តត្រូវអនុវត្តដូចតទៅ :

- បញ្ជីរាយនាមបេក្ខជនប្រធាន អនុប្រធាននៃរដ្ឋសភា ក៏ដូចជា ប្រធាន និងអនុប្រធានគណៈកម្មការ ជំនាញទាំងអស់ នៃរដ្ឋសភា ត្រូវរៀបចំ និងស្នើដោយគណបក្សនយោបាយដែលព្រមព្រៀងគ្នា ដើម្បីបង្កើតរាជរដ្ឋាភិបាលចំរុះ ហើយត្រូវផ្ញើជូនព្រឹទ្ធសមាជិករដ្ឋសភា ។

- តាមសេចក្តីស្នើពីគណបក្សនយោបាយ ដែលមានចំនួនអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភា តាមរយៈព្រឹទ្ធសមាជិករដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបក្នុងចំណោមតំណាងរាស្ត្រ នៃគណបក្សនយោបាយដែលឈ្នះឆ្នោត អោយបង្កើតរាជរដ្ឋាភិបាល ។

វរជនដែលត្រូវបានចាត់តាំងនេះ ត្រូវរៀបចំផ្គូរផ្គងតំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាលរួចផ្ញើបញ្ជី រាយនាមសមាជិកទាំអស់នៃរាជរដ្ឋាភិបាលជូនព្រឹទ្ធសមាជិករដ្ឋសភា ។

- ព្រឹទ្ធសមាជិករដ្ឋសភា ត្រូវរៀបចំបញ្ជីរាយនាមជាកញ្ចប់មួយនូវបេក្ខជន ប្រធាន អនុប្រធាន នៃរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការ ជំនាញទាំងអស់នៃរដ្ឋសភា ព្រមទាំងបេក្ខជន នាយករដ្ឋមន្ត្រី និងសមាជិកទាំងអស់នៃរាជរដ្ឋាភិបាល ដើម្បីដាក់ជូនរដ្ឋសភាបោះឆ្នោត ។

**មាត្រា ៥.-**

នៅក្នុងដំណើរការនៃការបោះឆ្នោតជាកញ្ចប់ មិនអាចជជែកពិភាក្សាអ្វីឡើយ ហើយក៏មិនអាចមានការពន្យល់អំពីការបោះឆ្នោតនេះ ក្រោយការប្រកាសលទ្ធផល នៃការបោះឆ្នោតជាកញ្ចប់នេះដែរ ។

សមាជិករដ្ឋសភា ត្រូវធ្វើការបោះឆ្នោតដោយបញ្ជាក់ថាព្រម ឬមិនព្រមចំពោះបញ្ជីរាយនាមជាកញ្ចប់មួយ ដែលព្រឹទ្ធសមាជិករដ្ឋសភាបានដាក់ជូន ។ ការបោះឆ្នោតនេះត្រូវធ្វើឡើងដោយវិធីលើកដៃ ។

**មាត្រា ៦.-**

ការបោះឆ្នោតជាកញ្ចប់ខាងលើនេះ ត្រូវយកមតិភាគច្រើន ពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល ។

ក្នុងករណី ការបោះឆ្នោតជុំទីមួយមិនបានសំរេច នីតិវិធីដដែលនេះ នឹងត្រូវអនុវត្តចំពោះការបោះឆ្នោតជុំក្រោយៗទៀត ។

**មាត្រា ៧.-**

ច្បាប់ធម្មនុញ្ញបន្ថែមនេះ ត្រូវបានប្រកាសជាការប្រញាប់ និងយកមកអនុវត្តចាប់តាំងពីដើម នីតិកាល បច្ចុប្បន្ននេះទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤

**ក្នុងព្រះបរមនាម និងតាមព្រះរាជបន្ទូលបង្គាប់**

នរល.០៤.០៧.១១៧

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ញឹក ប៊ុនឆៃ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**ព្រឹទ្ធសមាជិក និងជាប្រធានអង្គប្រជុំរដ្ឋសភា**

**ហត្ថលេខា**

**ជា សុខ**

# ព្រះរាជក្រម

នស/រកម/០៣០៦/០០៦

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សំណើរបស់តំណាងរាស្ត្រចំនួនលើសពីមួយភាគបួននៃចំនួនតំណាងរាស្ត្រទាំងមូល
- បានទ្រង់យល់លិខិតលេខ ៨២ លស ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៦ របស់សម្តេចនាយករដ្ឋមន្ត្រី
- បានទ្រង់យល់លិខិតលេខ ០០១/០១/២០០៦ កបធ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០៦ របស់ក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជសារព្រះមហាក្សត្រចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៦
- បានទ្រង់យល់លិខិតលេខ ២៥៤ រស ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០០៦ របស់រដ្ឋសភា
- បានទ្រង់យល់លិខិតលេខ ០១៣/០៣០៦/ពស/នវ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០០៦ របស់ព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## ប្រកាសឱ្យប្រើ

ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ៨២ មាត្រា ៨៨ថ្មី មាត្រា៩០ថ្មី មាត្រា៩៨ មាត្រា១០៦ថ្មី មាត្រា១១១ថ្មី (មួយ) មាត្រា១១៤ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័ន-ជាតិ ដែលរដ្ឋសភាអនុម័តនៅថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភា លើកទី ៤ នីតិកាលទី ៣ និងដែល-

ព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់ដើម្បីពិនិត្យច្បាប់នេះឱ្យទាន់តាមការកំណត់របស់មាត្រា ១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់រដ្ឋធម្មនុញ្ញ
# ស្តីពី
# វិសោធនកម្ម
# មាត្រា៨២ មាត្រា៨៨ថ្មី មាត្រា៩០ថ្មី មាត្រា៩៨
# មាត្រា ១០៦ថ្មី មាត្រា ១១១ថ្មី (មួយ) មាត្រា១១៤ថ្មី នៃរដ្ឋធម្មនុញ្ញ
# និងមាត្រា ៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការ
# ជាប្រក្រតីនៃស្ថាប័នជាតិ

## មាត្រាតែមួយ.-

មាត្រា ៨២ មាត្រា ៨៨ ថ្មី មាត្រា ៩០ ថ្មី មាត្រា ៩៨ ថ្មី មាត្រា ១០៦ ថ្មី មាត្រា ១១១ ថ្មី (មួយ) មាត្រា ១១៤ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ត្រូវបានកែប្រែដូចតទៅ :

## មាត្រា ៨២.- ថ្មី

រដ្ឋសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្តើមការងាររបស់ខ្លួន រដ្ឋសភាត្រូវប្រកាសសុពលភាព នៃអាណត្តិរបស់សមាជិកនីមួយៗ ត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា នូវប្រធាន អនុប្រធាន រដ្ឋសភា និង សមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាត្រូវអនុម័តបទបញ្ជាផ្ទៃក្នុង ដោយមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

តំណាងរាស្ត្រទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី ៥ នៃរដ្ឋធម្មនុញ្ញ ។

## មាត្រា ៨៨.- ថ្មី(ពីរ)

ការប្រជុំរដ្ឋសភាត្រូវធ្វើជាសាធារណៈ ។

រដ្ឋសភាអាចប្រជុំជាសម្ងាត់បានតាមការស្នើសុំពីប្រធាន ឬ ពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ឬ ពីនាយករដ្ឋមន្ត្រី ។

ការប្រជុំរដ្ឋសភា នឹងយកជាការបានលុះត្រាតែមាន :

ក- កូរ៉ុមលើសពី ពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែល

តម្រូវឱ្យយកមតិភាគច្រើន ពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ខ- កូរ៉ុមលើសពីពាក់កណ្ដាល នៃចំនួនសមាជិករដ្ឋសភាទាំងមូលសម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ៩០.~ ថ្មី(ពីរ)**

រដ្ឋសភាជាអង្គការ ដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។

រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬលុបចោលពន្ធដារ ។

រដ្ឋសភាឱ្យសេចក្ដីយល់ព្រមចំពោះគណនីរដ្ឋបាល ។

រដ្ឋសភាអនុម័តច្បាប់ស្ដីពីការលើកលែងទោសជាទូទៅ ។

រដ្ឋសភាអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ ។

រដ្ឋសភាអនុម័តច្បាប់ស្ដីពីការប្រកាសសង្គ្រាម ។

ការអនុម័តខាងលើនេះប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាលតាមមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ៩៨.~ ថ្មី**

រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលពីតំណែងដោយអនុម័តញត្តិបន្ទោស តាមសំឡេងឆ្នោតភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវបានលើកឡើងជូនរដ្ឋសភាដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន ។

**មាត្រា ១០៦.~ ថ្មី (មួយ)**

ព្រឹទ្ធសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោតតាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្ដើមការងាររបស់ខ្លួន ព្រឹទ្ធសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា នូវប្រធាន អនុប្រធានព្រឹទ្ធសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់ព្រឹទ្ធសភាដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

សមាជិកព្រឹទ្ធសភាទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី ៧ នៃរដ្ឋធម្មនុញ្ញ ។

**មាត្រា ១១១.~ ថ្មី (ពីរ)**

ការប្រជុំព្រឹទ្ធសភាត្រូវធ្វើជាសាធារណៈ ។

ព្រឹទ្ធសភាអាចប្រជុំជាសម្ងាត់បានតាមការស្នើសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬពីប្រធានរដ្ឋសភា ។

ការប្រជុំព្រឹទ្ធសភានឹងយកជាការបាន លុះត្រាតែមាន :

ក- កូរ៉ុមលើសពី ពីរភាគបី នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ខ- កូរ៉ុមលើសពីពាក់កណ្តាលនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូលសម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដោយប្រៀប ឬយកមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ចំនួនសំឡេងដែលតម្រូវសម្រាប់រដ្ឋសភាអនុម័តយល់ព្រម ហើយដែលមានកំណត់ក្នុងរដ្ឋធម្មនុញ្ញត្រូវយកមកប្រើសម្រាប់ព្រឹទ្ធសភាផងដែរ ។

**មាត្រា ១១៤.~ ថ្មី (មួយ)**

ព្រឹទ្ធសភាបង្កើតគណៈកម្មការផ្សេងៗ ដែលចាំបាច់ ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃព្រឹទ្ធសភានឹងកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា ។ បទបញ្ជាផ្ទៃក្នុងនេះត្រូវអនុម័តយល់ព្រម ដោយសំឡេងភាគច្រើនដាច់ខាត នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

**មាត្រា ៦.~ ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែម**

ការបោះឆ្នោតជាកញ្ចប់ខាងលើនេះ ត្រូវយកតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ក្នុងករណីការបោះឆ្នោតជុំទីមួយមិនបានសម្រេច នីតិវិធីដដែលនេះនឹងត្រូវអនុវត្តចំពោះការបោះឆ្នោតជុំក្រោយៗទៀត ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០០៦

ពរល.០៦០៣.១២៤

**ព្រះហស្ថលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ហត្ថលេខា**

**សុខ អាន**

លេខ : ១១៣ ច.ល

**ដើម្បីចម្លងចែក**

**រាជធានីភ្នំពេញ ថ្ងៃទី ខែ មីនា ឆ្នាំ ២០០៦**

**ហត្ថលេខា**

**ឈាង តាន់**